# ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩

## បង្ក្រាបទីតាំងម៉ាស្សា ឃាត់ខ្លួនជនជាតិចិន ១២នាក់ លួចលាក់បំរើសេវាផ្លូវភេទ នៅខណ្ឌពោធិ៍សែនជ័យ

https://www.dap-news.com/2019/05/01/ ByID:113 Posted on 01 May 2019 | 08:47

**ភ្នំពេញ៖** នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង៥ ល្ងាច កម្លាំងអន្តោប្រវេសន៍ សហការរដ្ឋបាលខណ្ឌពោធិ៍សែនជ័យ ដឹកនាំដោយលោកអភិបាលខណ្ឌ ដោយមានការសម្របសម្រួល ពីលោកព្រះរាជអាជ្ញាអម សាលាដំបូងរាជធានីភ្នំពេញ ចុះត្រួតពិនិត្យ ទីតាំងម៉ាស្សាឃីហោ អ៊ី ហុងយាន ផ្ទះលេខ៤J និង14J ផ្លូវលេខ១១៣ ភូមិព្រៃទា ១ សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ ពិនិត្យឃើញ ជនជាតិចិន ចំនួន១២នាក់ (ស្រី១០នាក់) ដកហូតលិខិតឆ្លងដែនចំនួន ៥ក្បាល ទូរសព្ទ័១២គ្រឿង និងស្រោមអនាម័យមួយចំនួនធំ (ទីតាំងខាងលើពុំមាន លិខិតអនុញ្ញាតទេ ស្លាកឃីហោជាអក្សរចិន) ដែលគ្រប់គ្រងដោយឈ្មោះ ភីង អ៊ី ភេទស្រី អាយុ៥០ឆ្នាំ ជនជាតិចិន ។

យោងតាម របាយការណ៍របស់គណៈបញ្ជាការ ឯកភាពរដ្ឋបាលខណ្ឌពោធិ៍សែនជ័យ ដែលមជ្ឈមណ្ឌលព័ត៌មាន ដើមអម្ពិលទទួលបាននៅថ្ងៃទី១ ខែឧសភា នេះថា ជនជាតិចិន ដែលសមត្ថកិច្ចបង្ក្រាប ចំនួន១២នាក់ ៖

១.ឈ្មោះ LEI TING ភេទស្រី អាយុ២៩ឆ្នាំ ជនជាតិចិន

២.ឈ្មោះ ZENG CHUN HUA ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិចិន

៣.ឈ្មោះ SHU XINGXI ភេទស្រី អាយុ២៨ឆ្នាំ ជនជាតិចិន

៤.ឈ្មោះ LUO YAN YANG ភេទស្រី អាយុ២៩ឆ្នាំ ជនជាតិចិន

៥.ឈ្មោះ LIN NIAN ភេទស្រី អាយុ២៩ឆ្នាំ ជនជាតិចិន

៦.ឈ្មោះ GUO MEINA ភេទស្រី អាយុ៣១ឆ្នាំ ជនជាតិចិន

៧.ឈ្មោះ XIAO GUANGHUA ភេទស្រី អាយុ២៩ឆ្នាំ ជនជាតិចិន

៨.ឈ្មោះ XU PIN YU ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិចិន

៩.ឈ្មោះ ZHOU YONGLIN ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិចិន

១០.ឈ្មោះ TSAI YAO TENG ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិចិនតៃវ៉ាន់ បុគ្គលិកខារ៉ាអូខេ

១១.ឈ្មោះ WEI LIUYING ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិចិន អ្នកទេសចរ

១២.ឈ្មោះ CHEN FANG ភេទស្រី អាយុ៣០ឆ្នាំ ជនជាតិចិន ជនជាតិចិនទាំង ១២នាក់នេះ មានមុខរបរជាអ្នកម៉ាស្សា នៅទីតាំងកើតហេតុ ។

ក្រោយមកកម្លាំងការិយាល័យ បានធ្វើការសាកសួរ ជនជាតិខាងលើ បានសារភាពថាពិតជាមានសេវាម៉ាស្សា និងការរួមភេទជាមួយភ្ញៀវមែន ។ ជនជាតិចិនទាំង ១២នាក់ត្រូវបានសមត្ថកិច្ច រៀបចំឯកសារដើម្បី ចាត់ការតាមនិតិវិធីច្បាប់ ៕

## យោធាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ប្តេជ្ញារក្សាទំនាក់ទំនងល្អរវាងព្រំដែនប្រទេសទាំងពីរ និងរួមគ្នាបង្ក្រាបបទល្មើសតាមព្រំដែន

http://www.freshnewsasia.com/index.php/ 2019-05-01

**(ត្រាត-ថៃ)៖** លោកឧត្តមសេនីយ៍ទោ ច័ន្ទ រដ្ឋា មេបញ្ជាការរងយោធភូមិភាគទី៥ ទទួលបន្ទុកការងារព្រំដែន បានអញ្ជើញជួបពិភាក្សាជាមួយភាគីថៃ នៅទីបញ្ជាការយោធាខេត្តត្រាត ដែលដឹកនាំដោយលោកវរសេនីយ៍ ប្រាក់ជួប គិរីវង់ នៅល្ងាចថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩។ នៅក្នុងកិច្ចពិភាក្សានេះ យោធាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ បានផ្តោតសំខាន់ទៅលើកិច្ចការ ការងារសន្តិសុខព្រំដែន ការបង្ក្រាបបទល្មើសតាមព្រំដែន និងការទំនាក់ទំនងល្អរវាងភាគីកម្ពុជា និងភាគីថៃ។

ក្នុងឱកាសនោះ លោកឧត្តមសេនីយ៍ទោ ច័ន្ទ រដ្ឋា បានស្នើឲ្យភាគីថៃ មេត្តាយោគយល់ និងអធ្យាស្រ័យឲ្យបានខ្ពស់ ក្នុងការបង្ក្រាបប្រជាពលរដ្ឋខ្មែរ ដែលចូលទៅខុសច្បាប់ ឬកាប់ឈើនៅក្នុងទឹកដីថៃ ធ្វើយ៉ាងណាកុំឲ្យមានការបាញ់សម្លាប់ដូចកាលថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩កន្លងទៅ និងពេលមុនបន្តទៀត។

គួរជម្រាបថា កិច្ចពិភាក្សានេះបានប្រព្រឹត្តទៅដោយរលូន និងរីករាយបំផុត ដែលបង្ហាញឲ្យឃើញនៅចំណងមេត្រីភាព និងការទំនាក់ទំនងល្អ រវាងព្រំដែនទាំងពីរកម្ពុជា និងថៃ ស្របទៅតាមអនុសាសន៍របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បង្កើតបានជាព្រំដែនមួយ ដែលមានសុខសន្តិភាព និងការអភិវឌ្ឍ៕

## គ្រួសារមួយនៅខេត្តពោធិ៍សាត់រៀបរាប់អំពីការលំបាកបន្ទាប់ពីទាហានថៃបាញ់កូនស្លាប់ពេលលបកាប់ឈើក្នុងដីថៃ

https://www.rfa.org/khmer/news/ ដោយ សុ ជីវី 2019-05-01

ម្តាយយុវជនម្នាក់រស់នៅខេត្តពោធិ៍សាត់ ដែលទាហានថៃបាញ់ស្លាប់នៅពេលលួចចូលទៅកាប់ឈើក្នុងដីថៃ កាលពីថ្ងៃទី២៤ មេសា សម្តែងការសោកស្តាយនឹកអាណិតកូនស្លាប់នៅក្នុងព្រៃម្នាក់ឯង ដោយមិនបានយកសពមកធ្វើបុណ្យតាមប្រពៃណីពុទ្ធសាសនា ដោយសារមិនមានលទ្ធភាពទៅយកកូនត្រឡប់មកធ្វើបុណ្យនៅឯស្រុកកំណើត។ អ្នកស្រីលើកឡើងថា ប្រសិនបើគ្រួសារមានជីវភាពធូរធារនិងមានការងារធ្វើបានប្រាក់ខែសមរម្យនៅក្នុងស្រុកគឺកូនរបស់ខ្លួននឹងមិនទាន់ស្លាប់នោះទេ។

ម្តាយយុវជនដែលទាហានថៃបាញ់ស្លាប់ លោកស្រី ហាន នេត ប្រាប់អាស៊ីសេរីថា លោកស្រីគ្មានអ្វីជាទីពឹងទៀតទេ ព្រោះសព្វថ្ងៃរស់នៅជាស្ត្រីមេម៉ាយ ពុំមានដីធ្វើស្រែ និងគ្មានមុខរបរចិញ្ចឹមជីវិត ហើយរំពឹងកូន២នាក់ ដើម្បីជួយមើលថែនៅពេលដែលខ្លួនចាស់ជរា ក៏ប៉ុន្តែអ្វីៗ បានបាត់បង់មួយរំពេចដែលខុសពីក្តីស្រមៃ ដោយសារតែជីវភាពក្រីក្រ។ ស្ត្រីវ័យ ៦១ឆ្នាំរូបនេះបន្តថា កូនប្រុសរបស់គាត់ បានចេញពីផ្ទះប្រមាណ ១០ឆ្នាំ ទៅរស់នៅតាមព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តពោធិ៍សាត់ គឺតាំងពីប្តីរបស់លោកស្រីមិនទាន់ស្លាប់ ហើយកូនទើបតែត្រឡប់មកផ្ទះវិញនៅមុនបុណ្យចូលឆ្នាំខ្មែរប្រមាណ ៣ថ្ងៃ។ លោកស្រីបន្ថែមថា កូនបានមករស់នៅជុំជាមួយអ្នកស្រីមិនទាន់បាត់នឹកកូនផង ក៏ស្រាប់តែចប់បុណ្យចូលឆ្នាំបាន ៣ថ្ងៃ កូនក៏សុំលោកស្រីចេញទៅរកកាប់ឈើក្នុងទឹកដីថៃជាមួយកូនអ្នកស្រុកក្បែរខាង ដើម្បីរកប្រាក់ដោះស្រាយជីវភាពប្រចាំថ្ងៃ។ អ្នកស្រីថា ក្រោយមកប៉ូលិសស្រុកក្រវាញបានប្រាប់ថា កូនលោកស្រីត្រូវបានទាហានថៃបាញ់ស្លាប់នៅក្នុងព្រៃនៅប្រទេសថៃ៖ «ខ្ញុំរាល់នេះគ្មានអីទេមានតែ ២នាក់ចៅអាយុ ១២ឆ្នាំ ខ្ញុំសល់កូនពៅនឹងមួយឥឡូវបាត់ទៀតហើយ វាទៅជាមួយពួកម៉ាកវា គេវត់មកផ្ទះវិញអស់ហើយ នៅតែវាមួយ និងអ្នករបួសម្នាក់។ ខ្ញុំសូមឱ្យអាជ្ញាធរជួយខ្ញុំផង។ ខ្ញុំគ្មានទីពឹងអីទេ ព្រោះអីខ្ញុំក្រខ្ញុំអត់មានអីសោះ ហើយខ្ញុំអត់ស្គាល់អ្នកណាទេ»។ លោកស្រីបន្តថា ប្រសិនបើអ្នកស្រីមានជីវភាពសមរម្យដូចអ្នកទីក្រុង គឺមិនបណ្តោយឱ្យកូនទៅកាប់ឈើបែបនេះទេ ព្រោះដឹងថា ការឆ្លងដែនប្រថុយគ្រោះថ្នាក់ដល់អាយុជីវិត។ ក៏ប៉ុន្តែមិនដឹងធ្វើយ៉ាងណាជួយកូនបាន បើអ្នកស្រីរស់អាស្រ័យ

ទៅលើការស៊ីឈ្នួលគេ បានប្រាក់ប្រមាណពី ៥ពាន់ទៅ១ម៉ឺនរៀល ក្នុងមួយថ្ងៃនោះ។ អ្នកស្រីថា ប្រាក់ចំណូលដែលស៊ីឈ្នួលបាន មួយចំនួនសម្រាប់ជួយចៅប្រុសម្នាក់អាយុ ១២ឆ្នាំទៅរៀនឱ្យចេះដឹង កុំឱ្យលំបាកដូចកូនៗ របស់ខ្លួនទៅថ្ងៃក្រោយ និងប្រាក់មួយចំនួនទៀតសម្រាប់ដោះស្រាយជីវភាពប្រចាំថ្ងៃ និងទិញថ្នាំលេបផ្ទាល់ខ្លួន។

ឪពុកមាជនរងគ្រោះ លោក ងាន់ ឌុម ថ្លែងថា គ្រួសារលោកក្រីក្រមិនមានប្រាក់ជួយដល់បងស្រីរបស់ខ្លួននោះទេ គឺបានត្រឹមតែអាណិតស្រណោះក្មួយ ដែលស្លាប់នៅក្នុងព្រៃ ហើយសាកសពមិនដឹងនៅឯណា។ រីឯបងស្រីរស់នៅមេម៉ាយម្នាក់ឯងទៀត ព្រោះកូនស្រីម្នាក់ ដែលនៅមានជីវិត មានគ្រួសារ និងមានកូនតូចជីវភាពក្រីក្រ។ លោកបន្តថា កាលដែលក្មួយប្រុសនៅមានជីវិត គឺគ្រួសារបងស្រីមានជីវភាពខ្វះទៅហើយ ទម្រាំតែដល់ពេលចាស់ជរា មិនដឹងលំបាកយ៉ាងណានោះទេ៖ «ក្មួយហើយពិបាកចិត្តវាពិបាកពេកហើយ តែមិនដឹងទៅពឹងអ្នកណាឱ្យជួយបានបើមិនស្គាល់គេ។ តែបើនៅក្នុងស្រុកភូមិចម្ងាយត្រឹម ១០គីឡូម៉ែត្រអី យើងអាចទៅយកមកបាន តែនេះចម្ងាយរាប់គីឡូម៉ែត្រ ហើយទៅពឹងអ្នកណានៅព្រំដែនអត់ស្គាល់អ្នកណាមួយផង។ ពីម្សិលមិញប៉ូលិសនិយាយប្រាប់ដែរថា សាកសពគេយកមកដល់ដីខ្មែរហើយ ខ្ញុំក៏សួរថា នៅឯណា គេថាមិនដឹងនៅកន្លែងណាប្រាកដផង។ ខ្ញុំវាពិបាកពេកហើយ មិនដឹងគិតយ៉ាងម៉េចទៅទាក់ទងអ្នកណា?»។ លោកបន្តគិតត្រឹមថ្ងៃទី៣០ មេសា ខាងសាច់ញាតិមិនទាន់ដឹងថា សាកសពលោក មៅ មុំ នៅកន្លែងណានៅឡើយ ហើយក៏គ្មានលទ្ធភាពទៅយកសពមកធ្វើបុណ្យបានដែរ ព្រោះគ្មានប្រាក់។

មេភូមិព្រៃក២ លោក ទិត្យ សុន ប្រាប់អាស៊ីសេរីថា អាជ្ញាធរមូលដ្ឋានបានត្រឹមតែអាណិតស្រណោះក្រុមគ្រួសារនៃសព ដោយមិនមានលទ្ធភាពទៅយកសពជនរងគ្រោះមកធ្វើបុណ្យនៅស្រុកកំណើតបានទេ ព្រោះគ្មានមធ្យោបាយដឹកជញ្ជូន ស្របពេលដែលចម្ងាយផ្លូវទៅព្រំដែនថៃដល់ទៅ ១០០គីឡូម៉ែត្រឯណោះ។ លោកបន្តថា ជនរងគ្រោះ គឺលោក មៅ មុំ ស្លាប់ក្នុងដីថៃ និងពលរដ្ឋក្នុងភូមិម្នាក់ទៀតរងរបួស ដោយសារទាហានថៃបាញ់កាលពីថ្ងៃទី២៤ មេសា។ គិតត្រឹមរសៀលថ្ងៃទី៣០ មេសា ទាំងសាកសព និងអ្នករបួសនោះ គេមិនទាន់បញ្ជូនមកដល់ស្រុកកំណើតនៅឡើយទេ។ លោកថា ប្រជាពលរដ្ឋនៅក្នុងភូមិដែលលោកគ្រប់គ្រង ឆ្លងដែនទៅកាប់ឈើនៅប្រទេសថៃមានប្រហែល ៣០នាក់ ដោយពួកគេចេញទៅកាប់ឈើប្រមាណ ១សប្តាហ៍ ត្រឡប់មកផ្ទះម្តង និងលក់ឈើបានប្រាក់ជាង ១លានរៀលក្នុងម្នាក់។ លោកបន្ថែមថា មូលហេតុដែលពួកគេទៅកាប់ឈើ ដោយសារជីវភាពក្រីក្រ ហើយនៅរដូវប្រាំង ក្នុងភូមិគ្មានការងារធ្វើ ទើបជំរុញឱ្យយុវជនមួយចំនួន នាំគ្នាឆ្លងដែនចូលទៅដីថៃ៖ «គឺថា គ្រួសារនេះវាពិបាកវេទនាបណ្ដោយ។ មិនដឹងរៀបរាប់យ៉ាងម៉េចត្រូវទេ។ បើផ្ទះប្រក់ស្បូវ ហើយគាត់នៅ ២នាក់ចៅអាយុ ១២ឆ្នាំទេ ហើយសព្វថ្ងៃ បានអ្នកជិតខាងគេឃើញអាណិត ក៏ផ្តល់ថវិកា និងអង្ករបន្តិចបន្តួចជួយគាត់ តែមិនបានគ្រប់គ្រាន់ទេ។ ពេលស្លាប់កូនហើយ គាត់ដូចថា គិតតែពីយំ មិនដឹងគិតថាម៉េច រកអ្នកណាទីពឹងអត់បាន គឺមានមេភូមិ និងខាងឃុំប៉ុណ្ណឹងដោយមិនដឹងទៅពឹងអ្នកទៀតទេ ហើយគាត់នៅតែទឹកភ្នែករហូត។ យំស្រែកឱ្យញាតិជិតខាងជួយ ហើយឱ្យគេជួយយ៉ាងម៉េចបាន»។ លោកបន្តថា ម្ដាយជនរងគ្រោះមានការស្លុតចិត្តយ៉ាងខ្លាំង បន្ទាប់ពីប៉ូលិសស្រុកក្រវាញបានប្រាប់ថាកូនប្រុសត្រូវទាហានថៃបាញ់ស្លាប់ កាលពីថ្ងៃទី២៤ មេសា នៅក្នុងព្រៃនោះ។

មន្ត្រីអង្កេតផ្នែកសិទ្ធិមនុស្ស អង្គការ លីកាដូ (Licadho) ប្រចាំខេត្តពោធិ៍សាត់ លោក កែម គិមស្រ៊ន់ ចាត់ទុកបញ្ហានេះជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរមកលើពលរដ្ឋខ្មែរ ព្រោះសមត្ថកិច្ចថៃអាចចាប់ពួកគាត់ផ្តន្ទាទោសតាមច្បាប់ ដោយមិនត្រូវបាញ់សម្លាប់បែបនេះទេ។ លោកបន្តថា រដ្ឋាភិបាលកម្ពុជាត្រូវទាមទារទៅភាគីថៃ ឱ្យទទួលខុសត្រូវចំពោះការស្លាប់នេះ៖ «ហើយបើសិនជាអាជ្ញាធរយើងមិនព្រមទប់ស្កាត់មិនព្រមដេញដោលគ្នាជាមួយភាគីថៃសោះ ហើយបណ្តោយឱ្យតែពលរដ្ឋខ្មែរចូលដីថៃគេបាញ់ស្លាប់ដូច្នេះ វាហាក់បីដូចជាស្លាប់ជីវិតមនុស្សមួយមិនមានអ្នកណាទទួលខុសត្រូវអ៊ីចឹង។ ហើយអង្គការ លីកាដូ យើងមានតែការជំរុញនិងស្នើឱ្យកម្ពុជាយើងទេមានវិធានការទប់ស្កាត់ឬអប់រំទប់ស្កាត់ឱ្យពលរដ្ឋយើងឱ្យគាត់បានយល់ដឹងបញ្ហាឆ្លងដែនទៅប្រទេសថៃនោះ»។ មន្ត្រីសង្គមស៊ីវិលរូបនេះបន្តទៀតថា បញ្ហានេះអាជ្ញាធរពាក់ព័ន្ធក៏ត្រូវទៅដឹកសាកសពជនរងគ្រោះមកឱ្យសាច់ញាតិ ដើម្បីពួកគាត់យកទៅបុណ្យតាមព្រះ

ពុទ្ធសាសនាដែរ ព្រោះជាអាជ្ញាធរដែនដីមើលការខុសត្រូវពលរដ្ឋ ទទួលប្រាក់ខែពីរដ្ឋ ដែលប្រជាពលរដ្ឋបានបង់ពន្ធជូនរដ្ឋនោះ។ លោកបន្តថា ចាប់តាំងពីឆ្នាំ២០១៨ មក គឺនេះជាករណីទី២ ក្នុងខេត្តពោធិ៍សាត់ ដែលទាហានថៃបាញ់ស្លាប់ពលរដ្ឋខ្មែរដែលឆ្លងដែនទៅកាប់ឈើក្រញូងក្នុងទឹកដីថៃ។

អាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងការបរទេស លោក កេត សុផាន់ និងអភិបាលខេត្តកោះកុង អ្នកស្រី មិថុនា ភូថង បានទេនៅថ្ងៃទី៣០ មេសា ដើម្បីសុំអត្ថាធិប្បាយជុំវិញការស្នើសុំជំនួយពីគ្រួសារសពឱ្យសមត្ថកិច្ចទៅយកសពជនរងគ្រោះ ដោយទូរស័ព្ទពុំមានអ្នកទទួល។ ទោះជាយ៉ាងណាសាច់ញាតិនៅតែចង់បានសាកសពជនរងគ្រោះយកមកធ្វើបុណ្យនៅឯស្រុកកំណើត ដើម្បីឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធសពទៅកាន់សុគតិភព៕

## ពលករខ្មែរនៅថៃប្រមាណ៥០នាក់ប្រារព្ធទិវាពលកម្មអន្តរជាតិនៅទីក្រុងបាងកក

https://www.rfa.org/khmer/news/ ដោយ អាស៊ីសេរី 2019-05-01

ពលករខ្មែរធ្វើការងារនៅប្រទេសថៃប្រមាណ៥០នាក់នៅព្រឹកថ្ងៃទី១ ឧសភា បាននាំគ្នាចូលរួមប្រារព្ធទិវាពលកម្មអន្តរជាតិជាមួយពលករមកពីប្រទេសដទៃទៀតនៅទីក្រុងបាងកក។

តំណាងពលករខ្មែរម្នាក់ដែលបានចូលរួមក្នុងពិធីនេះ លោក រិន មករា ប្រាប់អាស៊ីសេរីនៅក្រោយបញ្ចប់កម្មវិធីថា ពិធីនេះបានផ្ដល់ចំណេះដឹងផ្នែកការសិទ្ធិពលករ ដែលធ្វើឱ្យអ្នកចូលមានភាពក្លាហាន និងហ៊ានតវ៉ាទាមទារសិទ្ធិសេរីភាពរបស់ខ្លួន ប្រសិនបើមានការរំលោភសិទ្ធិក្នុងពេលបំពេញការងារមកលើពួកគេ ពីសំណាក់ថៅកែថៃបាន និងដោយមិនមានការភ័យខ្លាច៖ «គឺធ្វើឱ្យពលករខ្មែរនៅប្រទេសថៃមានសិទ្ធិស្មើភាពគ្នាដូចជនជាតិថៃដែរ ពេលមានបញ្ហាដូចជាការរំលោភបំពានពេលថៅកែមិនបើកលុយប្រាក់ខែ និងបញ្ហាគ្រោះថ្នាក់ផ្សេងៗពេលបំពេញការងារជាដើម គឺខាងអង្គការសង្គមស៊ីវិលគេចុះមកជួយ ព្រោះធ្លាប់មានជាច្រើនករណីហើយដែលមានបញ្ហា ហើយអង្គការមកជួយពលករខ្មែររហូត»។ លោកបន្តថា ពិធីផ្ដួចផ្ដើមដោយអង្គការសង្គមស៊ីវិលផ្នែកការងារសិទ្ធិពលកររបស់ថៃ ដោយមានអ្នកចូលរួមប្រមាណ៣ពាន់នាក់(៣.០០០)រួមមានពលករខ្មែរ ភូមា ថៃ និងលាវដែលធ្វើការងារនៅប្រទេសថៃ។ លោកបន្ថែមថា ពលករខ្លះបានឡើងសម្ដែងមតិនៅលើវេទិកាអំពីសិទ្ធិសេរីភាពរបស់ខ្លួនដែលបានជួបប្រទះ ដោយមានកាន់ទង់ជាតិតំណាងឱ្យប្រទេសរៀងៗខ្លួន និងមានដើរហែជុំវិញទីកន្លែងរៀបចំពិធីនៅទីក្រុងបាងកក។ លោកថា ពិធីនេះជាលើកទី២ហើយពលករខ្មែរបានចូលរួមប្រារព្ធទិវាសិទ្ធការងារអន្តរជាតិនៅប្រទេសថៃ ដែលឆ្នាំកន្លងទៅមានពលករខ្មែរប្រមាណ២០នាក់ចូលរួម៕

## ទិវាពលកម្មអន្តរជាតិ ១ ឧសភា ក្លាយទៅជាទិវាកម្សាន្ត ដ៏សប្បាយរីករាយសម្រាប់ពលករ

http://nokorwatnews.com/archives/ 01-05-2019

កាលពីសម័យមុន មានការរំលោភបំពានទៅលើពលករ កម្មករ បង្កឲ្យមានការធ្វើបាតុកម្ម កូដកម្មជាច្រើនកើនឡើងនៅជុំវិញពិភពលោក ពិសេសគឺនៅថ្ងៃទី១ ខែឧសភា ដែលជាទិវាពលកម្មអន្តរជាតិ ។ ប៉ុន្តែនៅក្នុងឱកាសទិវាពលកម្មអន្តរជាតិឆ្នាំ២០១៩នេះ បានក្លាយទៅជាថ្ងៃ នៃដំណើរកម្សាន្ត យ៉ាងសប្បាយរីករាយរបស់ ក្រុមពលករកម្មករទៅវិញ។ ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ ទិវាពលកម្មអន្តរជាតិ កើតឡើងដំបូងនៅអាមេរិក នាឆ្នាំ១៨៨៦ ក្នុងទីក្រុឧស្សាហកម្ម Chicago ។ នៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៨៨៦ ដោយសារតែតម្រូវការរបស់ពលករ មិនបានបំពេញគ្រប់គ្រាន់ ក្រុមពលករ កម្មករនៅទូទាំងអាមេរិក បាននាំគ្នា ធ្វើកូដកម្មនៅទូទាំងអាមេរិក ទាមទារបំពេញផលប្រយោជន៍របស់ពលករ ។ ដំបូង កូដកម្មនៅទីក្រុង Chicago ដោយមានកម្មករ ជាង៤ម៉ឺននាក់ ចូលរួម ។ នៅក្នុងថ្ងៃនេះដែរ នៅទូទាំងអាមេរិក មានការធ្វើកូដកម្មដល់ទៅ៥ពាន់កន្លែង ក្នុងរយៈពេល៨ម៉ោង ថ្ងៃទី១ ខែឧសភា ឆ្នាំ១៨៨៦ ។ ក្រៅពីអាមេរិក ក៏នៅមានប្រទេសជាច្រើន បាននាំគ្នាធ្វើកូដកម្មផងដែរ ។

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៨៨៩ គឺ៣ ឆ្នាំ ក្រោយមហាកូដកម្មនោះ នៅទីក្រុងជីកាហ្គោ មានមហាសន្និបាទអន្តរជាតិធ្វើឡើងនៅទីក្រុងប៉ារីស ប្រទេសបារាំង ហើយបានកំណត់យកថ្ងៃទី១ ខែឧសភា ធ្វើជាទិវាពលកម្មអន្តរជាតិ ។ ទិវាពលកម្មអន្តរជាតិ១ ឧសភា ត្រូវបានធ្វើឡើងនៅប្រទេសជាច្រើនជុំវិញពិភពលោក ដោយមានសកម្មភាពផ្សេងពីគ្នា ។ ប្រទេសខ្លះ មានបានឈប់សម្រាកជាច្រើនថ្ងៃ និងប្រទេសខ្លះទៀត នាំគ្នាដង្ហែក្បួនបាតុកម្ម ទាមទារ សិទ្ធិ និងផលប្រយោជន៍ពលកម្ម។

នៅប្រទេសចិន ក្នុងឱកាសនៃទិវាពលកម្មអន្តរជាតិឆ្នាំនេះ គឺជាពេលវេលាដំណើរកម្សាន្តជាទ្រង់ទ្រាយធំបំផុត ដោយមានការធ្វើដំណើរនៅទូទាំងប្រទេស ដល់ទៅ១៦០លាន ដើងទាំងរថយន្ត ក្រុង និងយន្តហោះ ។ ការធ្វើដំណើរកម្សាន្តច្រើន បែបនេះ គឺដោយសារតែនៅក្នុងឆ្នាំនេះ បានឈប់សម្រាកក្នុងឱកាសទិវាពលកម្មអន្តរជាតិដល់ទៅ៤ថ្ងៃ ចាប់ពីថ្ងៃទី១ ខែឧសភា ដល់ថ្ងៃទី៤ ខែឧសភា។ ក្នុងរយៈពេល១ម៉ោង ក្រោយការប្រកាសឈប់សម្រាក់៤ថ្ងៃ ចំនួនពលរដ្ឋ ស្វែងរក Tour កម្សាន្តនៅលើ CTrip កើនឡើងដល់ទៅ៥០ភាគរយ ។ អ្នកទេសចរណ៍មកពីជាង ៦១០ទីក្រុងទាំងក្នុង និងក្រៅប្រទេស បាន កក់ Tour កម្សាន្ត តាមរយៈ Ctrip ដោយក្រុមហ៊ុននេះ បាននាំភ្ញៀវធ្វើដំណើរទៅកាន់ ៩០០កន្លែង នៅ៩០ប្រទេស ជុំវិញពិភពលោក។ ភាគច្រើនអ្នកទេសចរណ៍ ជាយុវជន ពីអាយុ២០ឆ្នាំឡើង ។ ជាមួយគ្នានេះ ក្រុមហ៊ុនដឹកអ្នកដំណើរតាមផ្លូវដែករបស់ចិន ក៏បាន បង្កើនជើងរថភ្លើងបន្ថែមទៀត ។ តាមគម្រោង អ្នកធ្វើដំណើរតាមផ្លូវដែលមានដល់ទៅ៦៩លាននាក់ ចាប់ពីថ្ងៃទី៣០ដល់ថ្ងៃទី ៤ខែឧសភា កើន១១ភាគរយ ប្រៀបធៀប និងឆ្នាំ២០១៨។ ក្នុងពេលដែលចិនប្រារព្ធទិវាពលកម្មអន្តរជាតិជាថ្ងៃសប្បាយរីករាយ ជាថ្ងៃធ្វើដំណើរកម្សាន្តជាច្រើន ។ ចំណែកប្រទេសខ្លះទៀត បានឈប់សម្រាកតែមួយថ្ងៃប៉ុណ្ណោះ គឺនៅថ្ងៃទី១ ខែឧសភា ។

នៅប្រទេសអាល្លឺម៉ង់ យប់ថ្ងៃទី៣០ ខែមេសា ពលរដ្ឋមួយចំនួនធំមិនបានដេកនោះឡើយដោយធ្វើពិធីជប់លៀងនៅខាងក្រៅរហូតដល់ថ្ងៃទី១ ខែឧសភា។ ប្រទេសជាច្រើនផ្សេងទៀតនៅតំបន់អឺរ៉ុប ដូចជាបារាំង អ៊ីតាលី អេស្ប៉ាញ ស្លូវ៉ាគី... គឺមានពិធីជប់លៀងដូចគ្នា៕

# ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩

## នគរបាលឃាត់ពលរដ្ឋជាង ១០០ នាក់ អប់រំ ក្រោយពួកគេព្យាយាមឆ្លងដែនខុសច្បាប់

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 01 May 2019 | 14:18 ICT

**បន្ទាយមានជ័យ:** អាជ្ញាធរខេត្តបន្ទាយមានជ័យ បានឃាត់ដំណើរពលករខ្មែរប្រមាណជាង ១០០ នាក់ ដែលព្យាយាមឆ្លងដែនចូលទឹកដីថៃ ដោយមិនមានឯកសារត្រឹមត្រូវជាបន្តបន្ទាប់តាមច្រករបៀងតូចៗ ដើម្បីយកមកអប់រំ ខណៈសង្គមស៊ីវិលមើលឃើញថា ការឃាត់យកមកអប់រំ ដើម្បីឲ្យពួកគាត់ឈប់ឆ្លងដែន គឺមិនមែនជាគោលនយោបាយមួយដែលមានប្រសិទ្ធភាពនោះទេ។

តាមរបាយការណ៍របស់អគ្គស្នងការនគរបាលជាតិ បានឲ្យដឹងថា កាលពីយប់ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៩ ពលករខ្មែរមួយក្រុមមានគ្នា ១១៤ នាក់ មកពី ១១ ខេត្តទូទាំងប្រទេស ក្នុងនោះមានស្រី ៤៨ នាក់ និងកុមារ ៩ នាក់ បម្រុងឆ្លងដែនខុសច្បាប់តាមច្រករបៀងក្នុងភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ តែក្រោយមកត្រូវបានកម្លាំងនគរបាលការពារព្រំដែនគោកលេខ ៨១៥ ឈរជើងក្នុង ភូមិសាស្ត្រ ស្រុកម៉ាឡៃ ឃាត់ដំណើរពួកគេមិនឱ្យឆ្លងដែនចូលទៅក្នុងប្រទេស ថៃ នោះឡើយ បន្ទាប់ពីកម្លាំងនគរបាលការពារព្រំដែនបានត្រួតពិនិត្យឃើញថា ពួកគេទាំងនោះ បម្រុងឆ្លងដែនតាមរយៈការចាត់ចែងរបស់មេខ្យល់ ដោយគ្មានលិខិតឯកសារស្របច្បាប់ចូលក្នុងប្រទេស ថៃ នោះឡើយ។

លោក បេន សំអាត អធិការស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យថ្លែងថា កាលពីយប់ថ្ងៃ ២៩ គឺកម្លាំងការពារព្រំដែនបានចុះប្រមែប្រមូលពួកគាត់បាន ១១៤ នាក់ យកមកអប់រំណែនាំហើយ ហើយកាលពីម្សិលមិញបានឃាត់ពល

រដ្ឋប្រមាណ ២០ នាក់ទៀត ដែលពួកគាត់បានព្យាយាមឆ្លងដែនខុសច្បាប់។ លោកថ្លែងថា៖ «ការឆ្លងដែនទាំងប្រថុយប្រថានចូលក្នុងប្រទេសថៃខុសច្បាប់នេះ ពួកគាត់ប្រឈមបញ្ហាច្រើន ណាមួយអាចត្រូវបានទាហានថៃចាប់ ឬបាញ់អីទៅ ដែលគ្រោះថ្នាក់ដល់អាយុជីវិត។ មិនត្រឹមតែប៉ុណ្ណោះ ពួកគាត់ក៏អាចប្រឈមចាញ់បោកការជួញដូរពីសំណាក់ក្រុមមេខ្យល់ផងដែរ ទើបពួកយើងចុះរារាំង និងឃាត់ដំណើរពួកគាត់យកមកអប់រំ»។ លោក សំអាត ថ្លែងថា ពលរដ្ឋទាំងនោះ ត្រូវបានដោះលែងឲ្យត្រឡប់ទៅផ្ទះសំបែងវិញ ក្រោយពីបានអប់រំដល់ពួកគេហើយ។ តាមការសង្កេតបទល្មើសឆ្លងដែនខុសច្បាប់នៅដើមឆ្នាំនេះ គឺមានការថយចុះជាងឆ្នាំមុន»។ តាមរបាយការណ៍ដដែលបានឲ្យដឹងថា ពលករខ្មែរទាំង ១១៤ នាក់នោះ មកពីខេត្តពោធិ៍សាត់ ១២ នាក់ ខេត្តកំពត ម្នាក់ ខេត្តបាត់ដំបង ១៩ នាក់ ខេត្តព្រៃវែង ២៤ នាក់ ខេត្តបន្ទាយមានជ័យ ២៦ នាក់ ខេត្តកំពង់ធំ ម្នាក់ ខេត្តសៀមរាប ១០ នាក់ ខេត្តឧត្តរមានជ័យ ៣ នាក់ ខេត្តស្វាយរៀង ២ នាក់ ខេត្តកំពង់ចាម ៨ នាក់ និងខេត្តត្បូងឃ្មុំម្នាក់។

លោក ស៊ុំ ចាន់គា មន្ត្រីសម្របសម្រួលអង្គការអាដហុកប្រចាំខេត្តបន្ទាយមានជ័យ យល់ថា ការឃាត់ដំណើរពលរដ្ឋ ដោយគ្រាន់តែយកមកអប់រំ ដើម្បីឲ្យពួកគាត់ឈប់ឆ្លងដែនខុសច្បាប់នោះ គឺមិនមែនជាគោលនយោបាយត្រឹមត្រូវ ដែលមានប្រសិទ្ធភាពនោះទេ។ វាគ្រាន់ តែអាចរារាំងបានមួយពេល ហើយជាគោលការណ៍ពលរដ្ឋទាំងនោះ នៅបន្តលួចឆ្លងដែនដោយខុសច្បាប់ដដែល។ លោកថា៖ «ឃាត់អប់រំអី វាមិនជាប់ ព្រោះមនុស្សត្រូវការស៊ី ត្រូវការរស់នៅ ចិញ្ចឹមជីវិត ដោយពឹងទៅលើអាហារ តើការឃាត់គាត់ រារាំងគាត់ហ្នឹង មានអ្វីជួយគាត់នៅ? អ៊ីចឹង គួរតែធ្វើយ៉ាងម៉េចឲ្យពួកគាត់មានការងារធ្វើ មានប្រាក់ខែ និងជីវភាពសមរម្យ មានការធានាផ្នែកសុខភាពដល់ពួកគាត់ មានទីផ្សារអីល្អ បើប្រៀបធៀបទៅប្រទេសជិតខាងយើងដូចជាថៃ វៀតណាមអី។ បើមានតែប៉ុណ្ណឹងអី គាត់មានទៅចំណាកស្រុកអី»។

តាមរបាយការណ៍ស្តីពីលទ្ធផលការងារ ២០១៨ របស់ក្រសួងមហាផ្ទៃ ពលករខ្មែរធ្វើការនៅបរទេសចំនួន ៣២ ៨៨៥ នាក់ ត្រូវបានបញ្ជូនត្រឡប់មកវិញនិង ២២១ នាក់ ស្លាប់ក្នុងអំឡុងពេលទេសន្តរប្រវេសន៍៕

## សពពលរដ្ឋខ្មែរ ដែលត្រូវទាហានថៃបាញ់ស្លាប់ ពេលឆ្លងដែនទៅកាប់ឈើគ្រញូង ត្រូវបានដឹកមកកាន់កម្ពុជា

https://www.khmerload.com/news/ ៤៥ នាទីមុន 08:44 May 03, 2019

(ពោធិ៍សាត់)៖ សពពលរដ្ឋខ្មែរម្នាក់ ដែលត្រូវទាហានថៃបាញ់ស្លាប់ ពេលឆ្លងដែនទៅកាប់ឈើគ្រញូង នៅប្រទេសថៃ កាលពីសប្តាហ៍មុននោះ ត្រូវបានកម្លាំងយោធភូមិភាគទី៥ ស្នើសុំភាគីថៃ ដឹកមកកាន់កម្ពុជា នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩នេះ។ នេះបើតាមការអះអាងរបស់ លោក ចាន់ រដ្ឋា មេបញ្ជាការរងយោធភូមិភាគីទី៥។

សូមបញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរ២នាក់ ដែលឆ្លងចូលទឹកដីថៃដោយខុសច្បាប់ ដើម្បីកាប់ឈើគ្រញូង នៅភូមិថានសេង ឃុំឡែមកាត់ ស្រុកមឿង ខេត្តត្រាត ប្រទេសថៃ ត្រូវបានទាហានថៃ បាញ់ស្លាប់ម្នាក់នៅនឹងកន្លែង និងរបួសធ្ងន់ម្នាក់ នៅរសៀល ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩។

ជនរងគ្រោះដែលថៃបាញ់ស្លាប់មានឈ្មោះ ម៉ៅ មុំ ភេទប្រុស អាយុ២៦ឆ្នាំ រស់នៅភូមិព្រៃកពី ឃុំសំរោង ស្រុកក្រវាញ ខេត្តពោធិ៍សាត់ ត្រូវគ្រាប់កាំភ្លើងត្រង់ចំណុចបោះដៃផុតធ្លុះចូលចុងដង្ហើម។ ចំណែកអ្នករងរបួសធ្ងន់មានឈ្មោះ អាន រិត ភេទប្រុស អាយុ២៤ឆ្នាំ រស់នៅភូមិឃុំជាមួយគ្នា ត្រូវរបួស៣កន្លែងរួមមានត្រង់ប្រអប់ដៃស្តាំ ភ្លៅស្តាំ និងប្រអប់ជើងស្តាំ។ សពជងរងគ្រោះត្រូវបានថៃបញ្ជូនទៅខេត្តច័ន្ទបុរី ដើម្បីធ្វើកោសល្យវិច្ច័យ ចំណែកអ្នករងគ្រោះត្រូវបានបញ្ជូនទៅព្យាបាល នៅមន្ទីរពេទ្យខេត្តត្រាត៕

## ចុះធ្វើអធិការកិច្ចត្រួតពិនិត្យពលករបរទេស នៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ

https://www.facebook.com/ Department of Immigration - GDI 02-05-2019

កំពង់ស្ពឺ៖ កម្លាំងស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ ផែនការងារអន្តោប្រវេសន៍ សហការជាមួយកម្លាំងអគ្គនាយកដ្ឋានអន្តោប្រវេសន៍, មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នាថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យពលករបរទេសចំនួន ០៤រោងចក្រ ស្ថិតនៅក្នុងភូមិសាស្ត្រក្រុងច្បារមន ខេត្តកំពង់ស្ពឺ។ ទីតាំងទាំង ០៤រោងចក្រនេះ មាន៖

១.ឈ្មោះ SHUI YAT (CAMBODIA) CO.,LTD រោងចក្រផលិតកាបូប មានទីតាំស្ថិតនៅភូមិបូរីកម្មករ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ, ២.ឈ្មោះ SHUN SHUI SHING INDUSTRIAL (CAMBODIA) CO.,LTD រោងចក្រផលិតកាបូប មានទីតាំស្ថិតនៅភូមិបូរីកម្មករ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ, ៣.ឈ្មោះ S-YAUN (CAMBODIA) រោងចក្រផលិតសំលៀកបំពាក់ មានទីតាំស្ថិតនៅភូមិក្រាំងពលទេព សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ និង៤.ឈ្មោះ WUA TAI (CAMBODIA) GARMENT CO.,LTD រោងចក្រផលិតសំលៀកបំពាក់ មានទីតាំស្ថិតនៅភូមិត្រពាំងលើក សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

ក្នុងការត្រួតពិនិត្យរោងចក្រទាំង ០៤កន្លែង បានប្រើប្រាស់ពលករសរុបចំនួន ៤៨២៦នាក់ ស្រី ៤០១៣នាក់ (ពលករខ្មែរសរុបចំនួន ៤៧៦០នាក់ ស្រី ៣៩៨៤នាក់ និងពលករបរទេសសរុបចំនួន ៦៦នាក់ ស្រី ២៩នាក់ សញ្ជាតិចិន) បានពិនិត្យលិខិតឆ្លងដែនច្បាប់ដើមចំនួន ៥១នាក់ មិនបានពិនិត្យលិខិតឆ្លងដែនច្បាប់ដើមចំនួន ១៥នាក់ មូលហេតុទៅលេងក្រៅប្រទេស ១៤នាក់ និងពន្យាទិដ្ឋាការ ២នាក់ ប្រើប្រាស់ទិដ្ឋាការប្រភេទ E មានប័ណ្ណការងារឆ្នាំ ២០១៩ ចំនួន ៦៦នាក់៕

## ពលករក្រៅប្រទេសនឹងក្លាយជាបន្ទុក បើមិនមានចំណេះជំនាញជាប់នឹងខ្លួន ពេលត្រឡប់មកវិញ

https://thmeythmey.com/ 03, May 2019 , 9:29 am ដោយ: ថ្មីៗ

ភ្នំពេញ៖ លោក គី សេរីវឌ្ឍន៍ អ្នកជំនាញសេដ្ឋកិច្ចអះអាងថា ការចេញទៅធ្វើការនៅក្រៅប្រទេសរបស់ពលករខ្មែរសព្វថ្ងៃ ជាជម្រើសមួយល្អ ខណៈផលិតកម្ម និងការវិនិយោគក្នុងស្រុកនៅមានចំនួនតិចមិនអាចផ្តល់ការងារគ្រប់គ្រាន់។ បើតាមតួលេខពីធនាគារជាតិនៃកម្ពុជា ពលករខ្មែរបានផ្ញើរថវិកាតាមប្រព័ន្ធធនាគារប្រមាណ ១១០០លានដុល្លារចូលស្រុកកំណើតវិញកាលពីឆ្នាំ២០១៨ ដែលកើនឡើងប្រមាណ១០០លានដុល្លារ។ តែបើការអះអាងពីក្រសួងការងារ ថវិកាផ្ញើមកស្រុករបស់ពលករមានចំនួនច្រើនជាងនេះ។ ថវិកាទាំងនេះបានជួយបង្កើនប្រាក់ចំណូលសម្រាប់ពលរដ្ឋខ្មែរ និងធ្វើឲ្យមានលំហូរចាយវាយក្នុងស្រុកកាន់តែខ្លាំង។ តែបញ្ហាគឺនៅពេលពួកគាត់ត្រឡប់មកប្រទេសកំណើតវិញ។ បើពួកគាត់មិនបាននាំចំណេះជំនាញពេលត្រឡប់មកកម្ពុជាវិញនោះទេ នោះនឹងក្លាយជាបន្ទុកលំបាកជាមិនខាន។

ពលករខ្មែរនៅក្រៅប្រទេសមានចំនួនប្រមាណ១,២លាននាក់ ដោយនៅប្រទេថៃច្រើនជាងគេ ១,១លាននាក់ ប្រទេសកូរ៉េប្រហែល៥ម៉ឺននាក់ និងប្រទេសផ្សេងៗទៀតដូចជា ម៉ាឡេស៊ី ជប៉ុនជាដើម។ ពលករខ្មែរដែលចេញទៅក្រៅប្រទេស មាននៅប្រទេសថៃក្នុងចំនួនលើសលុប តែជាទូទៅធ្វើការគ្មានជំនាញ ដូចជាធ្វើការនៅការដ្ឋានសំណង់ សេវាកម្មផ្សេង និងកសិកម្ម ដកដំឡូង កាច់ពោត ចៀរជ័រកៅស៊ូ នេសាទ ជាដើម។ តែនៅកូរ៉េ និងជប៉ុន ពលករខ្មែរធ្វើការគ្រាន់បើជាងពលករនៅថៃ និងម៉ាឡេស៊ី ដោយទទួលប្រាក់ឈ្នួលខ្ពស់ ហើយពួកគេភាគច្រើនមានការអប់រំខ្ពស់ជាងពេលនៅខ្មែរ ដែលអាចរៀនពីរបៀបរបបធ្វើការពីក្រៅ និងចាប់យកចំណេះជំនាញបានក្នុងកម្រិតណាមួយប្រសើរជាង។ តែយ៉ាងណាក៏ដោយ ពលករខ្មែរនៅកូរ៉េ ទោះធ្វើការនៅផ្នែកឧស្សាហកម្ម ក៏ក្នុងនាមជាពលករជំនាញកម្រិតទាប ពោលគឺប្រើកម្លាំងពលកម្មលើសលុប។

ឆ្លើយតបនឹងសំណួរដែលថា អាចជាបញ្ហាសម្រាប់រយៈពេលវែងទេ នៅពេលពលករទាំងនោះវិលត្រឡប់មកស្រុកកំណើតវិញ លោក គី សេរីវឌ្ឍន៍ មានចម្លើយក្នុងន័យពីរ គឺមិនមែនបញ្ហាទេ បើពលករទាំងនោះនាំយកចំណេះជំនាញមកវិញ តែបើគ្មានជំនាញ នោះនឹងក្លាយជាបន្ទុក។ លោកថ្លែងដូច្នេះថា«ខ្ញុំគិតថាដូចជាមិនមានបញ្ហាអ្វីធ្ងន់ធ្ងរទេ នៅពេលដែលពួកគាត់ចេញទៅ ទីមួយបានស្គាល់របៀបរបបធ្វើការ ឧស្សាហកម្មធុនស្រាល និងមធ្យម ដូចនេះពេលត្រឡប់មកវិញ គួបផ្សំជាមួយនឹងកម្ពុជាលូតលាស់វិស័យឧស្សាហកម្មជាបន្តបន្ទាប់ ដូច្នេះជំនាញដែលពលករធ្វើការនៅស្រុកគេ អាចយកមកធ្វើការនៅកម្ពុជា សមល្មមនឹងការងាររបស់គាត់»។ លោកបន្តថា៖«មួយទៀតលំហូរចំណេះដឹង ខ្ញុំឃើញពលករយើងដែលរៀនសូត្របានថ្នាក់វិទ្យាល័យ ហើយទៅធ្វើការនៅកូរ៉េចិញ្ចឹមជ្រូកនៅទីនោះពេលចប់អាណត្តិមកវិញ ហើយសល់លុយខ្លះ បានបើកកសិដ្ឋានចិញ្ចឹមជ្រូកបែបកូរ៉េនៅស្រុក គាត់ទទួលបានជោគជ័យ»។ អ្នកសេដ្ឋកិច្ចរូបនេះ បញ្ជាក់ដូច្នេះទៀតថា៖«តែបើគាត់មិនបានស្រូបយកចំណេះដឹងទាំងអស់នោះមកវិញទេ ពួកគាត់នឹងប្រៀបបានកាកសំណល់ដែលហូរត្រឡប់មកវិញហើយ ព្រោះថានៅពេលត្រឡប់មកវិញត្រូវចាំចាយលុយហើយព្រោះកម្លាំងក៏ចុះខ្សោយ»។ លោកជំរុញឲ្យរដ្ឋាភិបាលចាប់អារម្មណ៍ខ្លាំងការអប់រំនៅទីជនបទ ដែលខ្វះគុណភាព និងរៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជន ដើម្បីទាក់ការវិនិយោគ បង្កើតការងារក្នុងស្រុក៕

## ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩

### ខ្លាំងប៉ះខ្លាំង! ផ្អើលពេញផ្ទះសំណាក់ ស្ទើ អង្គរ ទាំងកណ្ដាលយប់ ខណៈនគរបាលប្រឆាំងជួញដូរ និងការពារអនីតិជនចុះបង្ក្រាបមានភាពមិនប្រក្រតីកើនឡើង

http://nokorwatnews.com/archives/ 05-05-2019

ខេត្តកណ្តាល៖ ប្រជាពលរដ្ឋភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ បានភ្ញាក់ផ្អើលទាំងយប់ ខណៈឃើញកម្លាំងនគរបាលយ៉ាងច្រើនកុះករ ទៅឡើងពទ្ធ័ផ្ទះសំណាក់ ស្ទើ អង្គរ បង្ក្រាបបទល្មើសអន្តរការី បានប៉ះសំដីគ្នាជាមួយម្ចាស់ទីតាំង ប្រឆាំងមិនឲ្យឆែកឆេរ ព្រោះមិនមានអំពើពេស្យាចារ្យនៅទីនេះ រហូតដល់មានតំណាងអយ្យការ ចុះមកសម្របសម្រួល ក៏នៅតែតឹងសរសៃក ល្អក់កករជាក់គ្នា ប៉ិះតែកើតឡើងនូវអំពើហិង្សា ធ្វើឲ្យអ្នកភូមិលាន់មាត់ថា "ខ្លាំងប៉ះខ្លាំង ផ្កាយប៉ះលោកខែ មានខ្សែដូចគ្នា" អីចឹងហើយ ។ ចុងក្រោយកម្លាំងសមត្ថកិច្ចព្រមដកថយ ត្រឹមធ្វើកំណត់ហេតុឆែកឆេរបន្ទប់ចំនួន១០ និងនាំខ្លួនមនុស្សប្រុសស្រី៣នាក់ ជាភ្ញៀវមកស្នងការប៉ូលីសដើម្បីសួរនាំប៉ុណ្ណោះ ។

ហេតុការណ៍នេះ បានកើតឡើង ចាប់ពីម៉ោងជាង១៩យប់ ថ្ងៃទី០៣ រហូតដល់ម៉ោងជាង១ រំលងអធ្រាត្រឈានចូលថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៩ ចំណុចផ្ទះសំណាក់ស្ទើ អង្គរស្ថិតនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ។ បើតាមមន្ត្រីអាជ្ញាធរមូលដ្ឋាននិយាយថា ប្រតិបត្តិការបង្ក្រាបករណីជួញដូរផ្លូវភេទនៅក្នុងផ្ទះសំណាក់ ស្ទើ អង្គរ ធ្វើឡើង ដោយកម្លាំងសមត្ថកិច្ចនគរបាលប្រឆាំងបទល្មើសជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល ដឹកនាំដោយលោកវរសេនីយ៍ រស់ សារិន ប្រធានការិយាល័យ សហការជាមួយអង្គការមេត្រីភាព និងមានការសម្របសម្រួលនីតិវិធីពីសំណាក់លោកឯក ស៊ុនស្ទើ ព្រះរាជអាជ្ញារង សាលាដំបូងខេត្តកណ្តាល ។

បើតាមសាក្សីនិយាយថា កម្លាំងនគរបាលមិនតិចពី៥០នាក់ មធ្យោបាយមានរថយន្ត ម៉ូតូ និងកាំភ្លើង គ្រប់ដៃ បានឡោមពទ្ធ័ផ្ទះសំណាក់ ស្ទើ អង្គរ ឆែកឆេរតាមបន្ទប់ពេលនោះ គេឃើញឃាត់ខ្លួនមនុស្ស៣នាក់ (ស្រីម្នាក់) វាយខ្នោះ និងចាប់គ្រៀកស្ត្រីម្នាក់ ដែលគេស្គាល់ថា ជាម្ចាស់ផ្ទះសំណាក់ ស្រាប់តែកើតមានប្រតិកម្មភ្លាមៗ រារាំងមិនឲ្យឆែកឆេរ និងឃាត់ខ្លួនមនុស្ស ព្រោះមិនឃើញមានដីកាពីតុលាការហើយចោទប្រកាន់ថា ផ្ទះសំណាក់បង្កើតបទល្មើសពេស្យាចារ្យ ដែលការពិតមានតែភ្ញៀវមកជួលបន្ទប់ដេក ។ សាក្សីបន្តទៀតថា ដោយកម្លាំងសមត្ថកិច្ចនៅតែអនុ

វត្ត វិធានការរបស់ខ្លួន ដោយអះអាងថា ផ្ទះសំណាក់នេះមានបទល្មើស"អន្តរការី" ស្តុបនារីបម្រើផ្លូវភេទបានបន្ត ផែកធេរតាមបន្ទប់ឯម្ចាស់ផ្ទះសំណាក់ ក៏មិនណយដៃរបានទូរសព្ទ័ហៅបងប្អូន ដែលគេដឹងថាសុទ្ធតែខ្សែរគយ និង តុលាការបានប្រឆាំងតវ៉ាមិនឲ្យផែកធេរដោយសំអាងថាផ្ទះសំណាក់នេះមិនបានប្រព្រិត្តិអ្វីឲ្យខុសច្បាប់ទើបឈានដល់ ការប៉ះសំដីគ្នាខ្លាំងៗភ្ញាក់ផ្អើលដល់ប្រជាពលរដ្ឋជិតខាងដេកពួនលែងបានមិនតែប៉ុណ្ណោះផ្ទុះកក្រើកដល់ព្រះឥន្ទ(ព្រះ រាជអាជ្ញា)ទាំងយប់ចាត់ព្រះរាជអាជ្ញារងម្នាក់គឺលោកឯក ស៊ុនរស្មីមកសម្របសម្រួល ។ សាក្សីរៀបរាប់ឲ្យដឹងទៀតថា នៅពេល ដែលមានវត្តមានលោកព្រះរាជអាជ្ញារងរឿងរ៉ាវកាន់តែផ្ទុះឡើងខ្លាំងគឺមេប៉ូលីសលោករស់ សារិន និងព្រះរាជ អាជ្ញារងគងសំដីគ្នាបញ្ហាការអនុវត្តនីតិវិធី ដោយសំអាងច្បាប់រៀងៗខ្លួនម្ខាងថាមានបទល្មើសពាក់ពន្ធ័ម្ចាស់ទីតាំងឯ ម្ខាងទៀតថា មិនមានពាក់ពន្ធ័ម្ចាស់ទីតាំងតែយ៉ាងណាខាងសមត្ថកិច្ចនៅតែសំអាងថា មានបទល្មើសអន្តរការីបញ្ជាក់ ថាម្ចាស់ទីតាំងមានការពាក់ពន្ធ័(ស្តុបស្រីពេស្យាចារ្យបម្រើផ្លូវភេទ)ឯម្ចាស់ទីតាំងបដិសេធន៍ហើយអះអាងថា និង សមត្ថកិច្ច ដែលចុះមកមួលបង្កាច់គ្មានការពិតនេះ ។

លោកឯក ស៊ុនរស្មី អ្នកសម្របសម្រួលនីតិវិធីបានឲ្យដឹងថា ដើម្បីមានតម្លាភាពលោក ក៏បានតម្រូវឲ្យសមត្ថ កិច្ចសួរនាំអ្នកពាក់ពន្ធ័ជាបឋមនៅកន្លែងដើម្បីរកការពិតចៀសវាងការយល់ច្រឡំដោយគ្រាន់តែការឆ្លើយដាក់អ្នកនេះ អ្នកនោះ ដោយគ្មានភស្តុតាង ។ ក្រោយមានការសម្របសម្រួលនីតិវិធីមនុស្ស៣នាក់ (ស្រីម្នាក់) ដែលសមត្ថកិច្ច អះអាងថាមានការទំនាក់ទំនងគ្នាអំពើបទល្មើសអន្តរការីត្រូវបានដោះខ្នោះពីដៃវិញដើម្បីឲ្យទៅឆ្លើយបំភ្លឺនៅ ការិយាល័យប៉ូលិស ក្រៅពីនេះ មិនមានការដេកហូតអ្វីឡើយ ។

មជ្ឈដ្ឋានជាច្រើន ដែលបានតាមដានរឿងនេះ បាននិយាយថា ប្រតិបត្តិការបង្រ្កាបបទល្មើសពេស្យាចារ្យនៅ ផ្ទះសំណាក់ រស្មី អង្គរ គឺខ្លាំងប៉ះខ្លាំងផ្កាយប៉ះលោកខែហើយចាំមើល នឹងវិវត្តយ៉ាងណា ។

គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាលអាជ្ញាធរ មានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវតែអនុត្ត ដើម្បីសេចក្តីសុខរបស់ប្រជាពលរដ្ឋ ៕ ធ ដា

## កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនយោគ ឯកជន ចុះត្រួតពិនិតចនួន ៣០កន្លែង និងចែកចេញជា ០៦ក្រុម ក្នុងរាជធានីភ្នំពេញ

https://www.facebook.com/ Cambodia Migrant Labour Group – CMLG 05-05-2019

កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនយោគឯកជន នាថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៩ បានចុះត្រួតពិនិតចនួន ៣០កន្លែង និងចែកចេញជា ០៦ក្រុម ក្នុងរាជធានីភ្នំពេញ។ ក្នុងការចុះត្រួតពិនិត្យគោលដៅទាំង ៣០កន្លែង រួមមាន ១- រោងចក្រ សាន ស៊ូ ខ្លូស៊ីង សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ១), ២- រោងចក្រ អូន រ៉ូ រ៉ា សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ២), ៣- ក្រុមហ៊ុន ហូតា ហ្វ៊ូត វែរ សកម្មភាពអាជីវកម្ម ផលិតស្បែកជើង (ខណ្ឌពោធិ៍សែនជ័យ២), ៤- រោងចក្រ UAST APPREL សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ២), ៥- ក្រុមហ៊ុន CAMBODIA ANGKOR AIR សកម្មភាពអាជីវកម្ម សេវាដឹកជញ្ជូន (ខណ្ឌចំការមន), ៦- ក្រុមហ៊ុន JIN SAN LIN INTERNATIONAL សកម្មភាពអាជីវកម្ម លក់គ្រឿងសំណង់ (ខណ្ឌច្បារអំពៅ), ៧- ក្រុមហ៊ុន S L HI TECH សកម្មភាពអាជីវកម្ម សំណង់ (ខណ្ឌច្បារអំពៅ), ៨- ក្រុមហ៊ុន S C G សកម្មភាពអាជីវកម្ម លាយបេតុង (ខណ្ឌច្បារអំពៅ), ៩- វិទ្យាស្ថានអន្តរទ្វីប អាមេរិកាំង សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌទួលគោក), ១០- ក្រុមហ៊ុន ដា ហ៊្វ ហេង សកម្មភាពអាជីវកម្ម ចែកចាយស្រាបៀរ (ខណ្ឌឫស្សីកែវ), ១១- រោងចក្រ វីក ខេម ឧបតើរសិន សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌឫស្សីកែវ), ១២- រោងចក្រ បាយ័ន ហ្គាមិន សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌឫស្សីកែវ), ១៣- រោងចក្រ ហ៊្គន យ៉ាង សកម្មភាពអាជីវកម្ម ផលិតស្លាកសញ្ញាសម្លៀកបំពាក់ (ខណ្ឌពោធិ៍សែនជ័យ១), ១៤- ក្រុមហ៊ុន LIFU M & E សកម្មភាពអាជីវកម្ម អាហរ័ណនីហរ័ណ (ខណ្ឌពោធិ៍សែនជ័យ២), ១៥- រោងចក្រ DAYUP GLOBAL សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍

សែនជ័យ២), ១៦- ភោជនីយដ្ឋាន ឡុង គី សកម្មភាពអាជីវកម្ម ភោជនីយដ្ឋាន (ខណ្ឌទួលគោក), ១៧- ក្រុមហ៊ុន CHINA CONTACT ION សកម្មភាពអាជីវកម្ម សំណង់ (ខណ្ឌច្បារអំពៅ), ១៨- ការដ្ឋានសំណង់ TK PARBURY PROPERTY សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌទួលគោក), ១៩- ក្រុមហ៊ុន MCC20 សកម្មភាពអាជីវកម្ម សំណង់ (ខណ្ឌចំការមន), ២០- ភោជនីយដ្ឋាន ឌីនសាំ សកម្មភាពអាជីវកម្ម ភោជនីយដ្ឋាន (ខណ្ឌច្បារអំពៅ), ២១- ក្រុមហ៊ុន វុទ្ធី ឌីហ្សាញ សកម្មភាពអាជីវកម្ម លក់គ្រឿងដែក (ខណ្ឌច្បារអំពៅ), ២២- មន្ទីរពេទ្យ ខេម៉ា សកម្មភាពអាជីវកម្ម ព្យាបាលជំងឺ (ខណ្ឌទួលគោក), ២៣- ក្រុមហ៊ុន ORIENTAL សកម្មភាពអាជីវកម្ម សំណង់ (ខណ្ឌទួលគោក), ២៤- រោងចក្រ CAMBODIA TEXTILES WORLD សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ២), ២៥- ក្រុមហ៊ុន ចិន ហេង រចនាដែកស្មិត សកម្មភាពអាជីវកម្ម លក់គ្រឿងដែក (ខណ្ឌច្បារអំពៅ), ២៦- រោងចក្រ វេស្តហ្វីស ស្រេដ សកម្មភាពអាជីវកម្ម ខាអំបោះ (ខណ្ឌពោធិ៍សែនជ័យ១), ២៧- រោងចក្រ Y.L LABELS សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ១), ២៨- ហាងខាវ៉ាអូខេ សូល សកម្មភាពអាជីវកម្ម ខារ៉ាអូខេ (ខណ្ឌចំការមន), ២៩- រោងចក្រ វ៉ា លីក ហ្សុងហេង សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌឫស្សីកែវ) និង៣០- ក្រុមហ៊ុនខ្មែរ ហ្វូត សកម្មភាពអាជីវកម្ម លក់អង្ករ (ខណ្ឌច្បារអំពៅ) បានប្រើប្រាស់ពលករខ្មែរសរុបចំនួន ៨៧១១នាក់ ស្រី ៧០៦៧នាក់, ប្រើប្រាស់ពលករបរទេសសរុបចំនួន ២២១នាក់ ស្រី ៦៩នាក់ និងប្រើប្រាស់ទិដ្ឋាការ E ចំនួន ២១៨ មាន ១២ សញ្ជាតិ រួមមាន ចិន១០៤នាក់ ស្រី៣៣នាក់, ជប៉ុន ០១នាក់, ហ្វីលីពីន៣០នាក់ ស្រី ២១នាក់, អាមេរិក ០២នាក់, វៀតណាម ៧២នាក់ ស្រី ១២នាក់, អូស្ត្រាលី ០២នាក់, ស៊ុយអែត ០១នាក់, ឥណ្ឌា ០១នាក់ ស្រី ០១នាក់, ថៃ ០៣នាក់ ស្រី ០២នាក់, កូរ៉េ ០៣នាក់, ស្រីលង្កា ០១នាក់ និងបង់ក្លាដេស ០១នាក់ មានសៀវភៅការងារ និងប័ណ្ណការងារចំនួន ២០១ នាក់, គ្មានប័ណ្ណការងារចំនួន ២០ ជនជាតិចិន ១៧នាក់ និងជនជាតិវៀតណាមចំនួន ០៣នាក់ មានប័ណ្ណទទួលស្គាល់អន្តោប្រវេសន៍ (ខណ្ឌចំការមន)៕

## កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនយោគឯកជន ចុះត្រួតពិនិត្យការដ្ឋានសំណង់ចំនួន ០២កន្លែង ស្ថិតនៅសង្កាត់០៤ ក្រុងព្រះសីហនុ

https://www.facebook.com/ Cambodia Migrant Labour Group – CMLG 03-05-2019

ខេត្តព្រះសីហនុ៖ កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនិយោគឯកជន នាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ បានចុះត្រួតពិនិត្យការដ្ឋានសំណង់ចំនួន ០២កន្លែង ស្ថិតនៅសង្កាត់០៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ ការដ្ឋានសំណង់ទាំង០២កន្លែងនេះ មាន ១-ការដ្ឋានសំណង់ ក្រុមហ៊ុន ខេមបូឌានស៊ានជុនអ៊ិនធើណេសិន ខនស្រ្តាក់សិន មានពលករបរទេសសរុប ១៧ នាក់ សញ្ជាតិចិន ១៧នាក់ គ្មានបណ្ណ័ការងារ ១៧នាក់ និង២-ការដ្ឋានសំណង់ CHUANREN CONSTRUCTION DECORATION មានពលករបរទេសសរុប ២៨ នាក់ ស្រី ០១នាក់ សញ្ជាតិចិន ២៨នាក់ មានបណ្ណ័ការងារ ០៨នាក់ និងគ្មានបណ្ណ័ការងារ ២០នាក់៕

## អាជ្ញាធរ ថៃ បញ្ជូន ពលករ ខ្មែរ ឆ្លង ដែន ខុសច្បាប់ ០៨ នាក់ ឲ្យ មក កម្ពុជា វិញ

https://www.facebook.com/ Cambodia Migrant Labour Group – CMLG 06-05-2019

បាត់ដំបង ៖ អាជ្ញាធរថៃ នាវេលាម៉ោង០៩ និង៣០នាទី ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ បានចាប់បញ្ជូនពលករខ្មែរខុសច្បាប់ ចំនួន០៨នាក់ ស្រី០៣នាក់ មកប្រគល់ឲ្យកម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ។ ក្នុងចំណោមពលករខ្មែរទាំង០៨នាក់ នោះមានមកពីខេត្តកំពង់ធំ០១នាក់,ខេត្តព្រៃវែង០១នាក់, ខេត្តត្បូងឃ្មុំ០១ នាក់ ,ខេត្តសៀមរាប០២នាក់, ខេត្តប៉ៃលិន០៣នាក់ ។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំ និងអប់រំហើយប៉ុស្តិ៍បានអនុញ្ញាតឲ្យពួកគាត់ត្រឡប់ទៅលំនៅដ្ឋានវិញរៀងៗខ្លួន ៕

## អ្នកទោស៣នាក់ត្រូវបានអាជ្ញាធរថៃដោះលែង

https://kohsantepheapdaily.com.kh/article/ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៩ ម៉ោង ១៧:១៤ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ ក្រុមអាជ្ញាធរថៃបានធ្វើការដោះលែងអ្នកទោសខ្មែរចំនួន៣នាក់ឱ្យមានសេរីភាព និង បញ្ជូនមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជាតាមមាត់ច្រកទ្វារអន្តរជាតិជាំ កាលពីវេលាម៉ោង៤និង៣០នាទីល្ងាចថ្ងៃទី៤ ឧសភា ២០១៩ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ពលរដ្ឋខ្មែរទាំង៣នាក់ខាងលើដែលក្រុមអាជ្ញាធរថៃដោះលែងរួមមាន៖

១-ឈ្មោះចាន់ យៀ ភេទប្រុស អាយុ៣០ឆ្នាំ រស់នៅភូមិ១០៥ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ត្រូវអាជ្ញាធរថៃចាប់ខ្លួនកាលពីថ្ងៃទី៨ ឧសភា ២០១៧ ជាប់ចោទពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់។

២-ឈ្មោះវន រ័ត្ននី ភេទប្រុស អាយុ១៦ឆ្នាំ រស់នៅភូមិចារ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ត្រូវអាជ្ញាធរថៃចាប់ខ្លួនថ្ងៃទី៨ មីនា ២០១៩ ជាប់ចោទពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់។

៣- ឈ្មោះហ៊ីង ម៉ៅ ភេទប្រុស អាយុ១៥ឆ្នាំ រស់នៅភូមិតេជោបុស្ស៊ូ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ត្រូវអាជ្ញាធរថៃចាប់ខ្លួនថ្ងៃទី៤ កុម្ភៈ ២០១៩ ជាប់ចោទពីបទឆ្លងដែនដើរដាក់អន្ទាក់សត្វព្រៃ ។

អ្នកទាំង៣នាក់បានជាប់គុកនៅខេត្តស៊ីសាកេត ប្រទេសថៃ ដោយចូលតាមច្រកអូរស្វាយ ភូមិសាស្ត្រខ្មែរភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ទល់មុខភូមិសាស្ត្រថៃភូមិឃុំស្នឹងចាន់ ស្រុកឃុនហាន ខេត្តស៊ីសាកេត។ តាមប្រភពពីមន្ត្រីដែលបម្រើការនៅមាត់ច្រកទ្វារអន្តរជាតិជាំបានឱ្យដឹងថា អ្នកទោសខ្មែរទាំង៣នាក់ ដែលក្រុមអាជ្ញាធរថៃធ្វើការដោះលែង ហើយបាននាំខ្លួនយកមកប្រគល់ឱ្យកម្ពុជានោះសមត្ថកិច្ចបានធ្វើការអប់រំ និងធ្វើកិច្ចសន្យា រួចឱ្យវិលត្រឡប់ទៅលំនៅឋានជួបជុំគ្រុមគ្រួសារ ក្នុងថ្ងៃដដែលផងដែរ៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០៣នាក់ មកឲ្យកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration – GDI 03-05-2019

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិចាំយាម នាវេលាម៉ោង ១៥និង២០នាទី ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែន ខុសច្បាប់ ពីភាគីថៃចំនួន ០៣នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## កម្លាំងនគរបាលប៉ុស្តិ៍ ទទួលពលករខ្មែរខុសច្បាប់ ០៨នាក់ ពីភាគីថៃ

https://www.facebook.com/ General Department of Immigration – GDI 05-05-2019

បាត់ដំបង៖ កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី នាវេលាម៉ោង១១ និង ៣០នាទី ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៩ បានទទួលពលករខ្មែរខុសច្បាប់ចំនួន ០៨នាក់ ស្រី ០៥នាក់ ក្មេង ០១នាក់ ពីអាជ្ញាធរថៃ។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំ នឹងណែនាំ ហើយបានអនុញ្ញាតឲ្យពួកគាត់ ត្រឡប់ទៅលំនៅដ្ឋានវិញរៀងខ្លួន៕

## ថៃបញ្ជូនពលរដ្ឋខ្មែរ ០២នាក់ ឲ្យមកកម្ពុជាវិញ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/ General Department of Immigration – GDI 05-05-2019

ឧត្តរមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៩ បានទទួលពលរដ្ឋខ្មែរ ០២នាក់ ពីខាងភាគីថៃ ពីបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃដែលចេញតាមច្រកភ្នំខ្មោច ខេត្តព្រះវិហារ៕

## ព្រោះតែជីវភាពគ្រួសារក្មេងប្រុសម្នាក់ត្រូវសមត្ថកិច្ចថៃចាប់

https://www.facebook.com/Matemohachun/ សារព័ត៌មាន មតិមហាជន mmc-news 06-05-2019

ឧត្តរមានជ័យ៖ ព្រោះតែជីភាពគ្រួសារបុរសម្នាក់បង្ខំចិត្តលួចចូលទឹកដីថៃដោយខុសច្បាប់ប៉ុន្តែថៃជន្យអាក្រក់រឿងរ៉ាវអកុសលធ្លាក់លើកូនប្រុស ត្រូវសមត្ថកិច្ចថៃចាប់ខ្លួនខកខានការរៀនសូត្រអំពាវនាវអាជ្ញាធរនិងសមត្ថកិច្ចកម្ពុជាជួយដើម្បីត្រឡប់មកសិក្សាវិញ។ ក្មេងប្រុសខាងលើអាយុ14ឆ្នាំមានទីលំនៅភូមិចំការចេកសង្កាត់អូរស្មាច់ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ក្មេងប្រុសរូបនេះត្រូវសមត្ថកិច្ចថៃចាប់កាលពីម៉ោងជាង4រសៀលថ្ងៃទី5 ឧសភា 2019 នៅចំនប់អាង15 ក្នុងខេត្តសុរិន ប្រទេសថៃ ។ ករណីនេះគ្រួសារក្មេងរងគ្រោះកំពុងជង្គោយរកអាជ្ញាធរនិងសមត្ថកិច្ចកម្ពុជាជួយធ្វើយ៉ាងណាដើម្បីឲ្យបានត្រឡប់មកសិក្សាដូចដើមវិ ញ៕ ដោយ.....ការចេញចូលឆ្លងដែនខុសច្បាប់ដោយលួចលាក់ព្រោះតែជីវភាពអត់ឃ្លាន ដើម្បីផ្គត់ផ្គង់គ្រួសារត្រូវបានបង្ខំចិត្តចូលទៅកាប់ឈើ ជីកគល់ក្រញ៉ូងយកមកលក់បានលុយបន្តិចបន្តួចសំរាប់កូនរៀន តែពេលនេះត្រូវបានទាហ៊ានថៃចាប់កូនប្រុសអាយុ14ឆ្នាំ ដែលកំពុងតែសិក្សានៅឡើយ មូលហេតុដោយសារឡើងយកបាយទៅអោយឪពុកមិនទាន់បានយកទៅដល់ឪពុកផង ត្រូវទាហ៊ានថៃដេញចាប់បានកូនដែលយកបាយទៅអោយ ចំណែកឪពុកនិងនាក់ផ្សេងបានរត់រួចបន្សល់ទុកកូនប្រុសដែលនៅក្មេងខ្ចីមិនដឹងភូមិសាស្ត្រក៏ត្រូវគេចាប់បាន តាមសេចក្តីរាយការណ៍ពីមន្ត្រីយោធារ និងមន្ត្រីមានសមត្ថកិច្ចការពារនៅតាមក្រវ៉ាត់ព្រំដែនបានហាមឃាត់ពលរដ្ឋជារឿយៗ និងបានឃាមល្បាតយ៉ាងតឹងរឹង នៅតែមានពលរដ្ឋមួយចំនួនតូចលួចចូលកាប់ឈើក្នុងទឹកដីថៃដោយខុសច្បាប់ ដើម្បីបានមកលក់អោយពួកឈ្មួញ៕ ដោយចំណាន

# ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩

## អតីតកម្មករទូកនេសាទមកពីខេត្តបាត់ដំបងប្រឹងប្រែងលុបចំបាត់ការជួញដូរមនុស្សតាមរយៈការសរសេរសៀវភៅ

https://khmer.voanews.com/ 04 ឧសភា 2019 សឿន វឌ្ឍនា

វ៉ាស៊ីនតោន៖ បុរសសក់វែងប្រាំពីរនាក់កំពុងជួយគ្នាទាញសំណាញ់ពីក្នុងទឹកសមុទ្រឡើងលើទូកនេសាទពណ៌ខៀវ ដែលមានទង់ជាតិម៉ាឡេស៊ីនៅពីលើ និងបុរសទឹកមុខស្មើម្នាក់ សក់វែងប្រះស្មា ពាក់ខ្សែកបន្តោងរូបព្រះពុទ្ធជាមួយស្នាមសាក់រូបផ្កានៅដើមដៃខាងឆ្វេង គឺជារូបនៅលើគម្របសៀវភៅនិពន្ធដោយលោក ព្រំ វណ្ណៈអានន្ទ ហៅ វណ្ណៈ និងអ្នកស្រី Jocelyn Pederick។ សៀវភៅដែលនិពន្ធឡើងផ្អែកលើរឿងពិតរបស់លោក វណ្ណៈ ស្តីពីទាសភាពសម័យទំនើបដែលលោកធ្លាប់ឆ្លងកាត់នេះមានចំណងជើងថា «The Dead Eye and The Deep Blue Sea» ឬ «ពិភពអន្ធការនៅលើមហាសមុទ្រដ៏ធំល្វឹងល្វើយ»។ គិតត្រឹមឆ្នាំ ២០១៩ គឺមានរយៈពេលប្រាំបួនឆ្នាំមកហើយ ដែលលោក វណ្ណៈ បានគេចផុតពីការធ្វើជាទាសករនៅលើទូកនេសាទ និងចម្ការដូងប្រេង។ ប៉ុន្តែការចងចាំដ៏ឈឺចាប់ ដែលលោកបានជួបប្រទះអំឡុងពេលដែលលោកត្រូវបានគេលក់ឲ្យធ្វើជាទាសករកាលពី ១៣ ឆ្នាំមុន នៅតែលងបន្លាចលោកជានិច្ច។ នៅពេលនឹកឃើញរឿងអកុសលនេះម្តងៗ លោកជ្រើសរើសយកការធ្វើកិច្ចការផ្ទះ និងគូររូបដើម្បីបន្លប់ខ្លួនឯង។

លោក វណ្ណៈ បានប្រាប់ VOA ថា៖ «បាទ! គឺអត់មានបំភ្លេចបានទេ គឺខ្ញុំនៅចងចាំជានិច្ច គឺភ្លេចអត់បានទេ។ ជួនណាខ្ញុំធ្វើការកំប៉ិកកំប៉ុកនៅផ្ទះ ហើយនិងគូររូប។ ពេលគូររូបទៅវាអាចរំសាយនូវអារម្មណ៍ ការគិតទាំងអស់ហ្នឹង»។

**ជីវិតនៅលើទូកនេសាទ៖**

កាលពីឆ្នាំ ២០០៦ ដោយចង់រកប្រាក់ឲ្យបានគ្រប់គ្រាន់សម្រាប់ឲ្យប្រពន្ធសម្រាលកូន លោក វណ្ណៈ បានសម្រេចចិត្តចាកចេញពីស្រុកកំណើតនៅខេត្តបាត់ដំបង ទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់។ ជាអកុសលលោកត្រូវបានឈ្មួញជួញដូរមនុស្ស លក់ឲ្យទៅធ្វើការជាទាសករនៅលើទូកនេសាទ អស់រយៈពេលបីឆ្នាំ ប្រាំពីរខែ ដែលសឹងតែស្មើនឹងរបបកុម្មុយនិស្តខ្មែរក្រហម។ លោក វណ្ណៈ បានឲ្យដឹងថា នៅលើទូកនេសាទដែលលោកធ្វើការគេប្រើប្រាស់ភាសាថៃ ហើយកម្មករនៅលើទូកនោះមានជនជាតិខ្មែរ ថៃ និងមីយ៉ាន់ម៉ា។ កម្មករទាំងអស់ត្រូវបានចែកចេញជាពីរប្រភេទ ទីមួយគឺ កម្មករដែលទទួលបានប្រាក់ខែ និងអាចត្រឡប់ឡើងគោកជួបជុំគ្រួសារវិញ និងប្រភេទទីពីរគឺ កម្មករដែលត្រូវបានគេលក់ឲ្យធ្វើជាទាសករ ដែលមិនអាចទទួលបានប្រាក់ខែ និងសេរីភាពនោះទេ។ លោក វណ្ណៈ ស្ថិតក្នុងប្រភេទទីពីរ។ លោក វណ្ណៈ បាននិយាយថា៖ «អ្នកដែលចុះទៅ ដូចថាគេមានលុយបង់ពន្ធអ៊ីចឹង គេបានប្រាក់ខែ ហើយគេឡើងមកវិញ។ ដូចពួកខ្ញុំអ្នកលក់ គេយកទៅលក់អ៊ីចឹងអត់បានប្រាក់ខែទេ»។ លោក វណ្ណៈ បន្ថែមថា នៅលើទូកនោះ ថៅកែផ្តល់អាហារមួយថ្ងៃពីរ ឬបីពេលដល់កម្មករ ប៉ុន្តែភាគច្រើនសុទ្ធតែជាត្រី ឬគ្រឿងសមុទ្រ។ យូរៗម្តង កម្មករទទួលបានអាហារជាសាច់មាន់ ឬសាច់ជ្រូកជាដើម។ ការហូបចុកមិនមែនជាបញ្ហាចោទនោះទេសម្រាប់លោក វណ្ណៈ អ្វីដែលជាបញ្ហានោះគឺការបង្ខំឲ្យធ្វើការហួសកម្លាំង សម្រាកមិនគ្រប់គ្រាន់ និងការប្រើអំពើហិង្សាពីសំណាក់ថៅកែ និងអ្នកមើលការខុសត្រូវលើទូកទៅលើកម្មករ និងអំពើហិង្សារវាងកម្មករ និងកម្មករ។ លោក វណ្ណៈ បាននិយាយថា៖ «ប្រើអំពើហិង្សា ដូចថាគេប្រើយើង ប្រើវាយធ្វើបាបយើងដូចថាអ្នកណាល្ងង់ គេវាយធ្វើបាប។ និយាយរួមនៅលើទូក វាពោរពេញដោយការឈ្លោះគ្នា វាយដំ ជួនណាកាប់សម្លាប់គ្នាទៅវិញទៅមក ឈ្លោះគ្នា។ ធ្វើការជាមួយគ្នាអត់សូវត្រូវគ្នា មួយខ្លាំងជាងមួយខ្សោយជាង វាអត់សូវត្រូវគ្នា ឈ្លោះតែគ្នា»។ លោកបន្ថែមថា ពេលណាកម្មករណាម្នាក់ធ្លាក់ខ្លួនឈឺ ថៅកែចាំឃ្លាំមើលរយៈពេលពីរបីថ្ងៃ។ បើពីរបីថ្ងៃហើយកម្មករនោះនៅតែឈឺធ្វើការមិនកើត គ្នីគ្នារបស់ថៅកែ សម្លាប់កម្មករនោះចោល ឬទម្លាក់ចូលសមុទ្រតែម្តង។

លោក វណ្ណៈ បញ្ជាក់ទៀតថា កម្មករមានគ្នាច្រើនជាងគ្នីគ្នារបស់ថៅកែ ប៉ុន្តែពួកគេមិនអាចរួមគ្នាតដៃបានទេដោយសារតែថៅកែដាក់កម្មករដែលមានជាតិសាសន៍ខុសៗគ្នាឲ្យនៅជាមួយគ្នា។ ដូច្នេះក ម្មករមិនអាចនិយាយស្តាប់គ្នាយល់ ឬបបួលគ្នាធ្វើអ្វីមួយស្រុះគ្នាបានទេ។ ដើម្បីគេចពីការធ្វើបាបរបស់ថៅកែ និងអ្នកមើលការខុសត្រូវ លោក វណ្ណៈ បានឲ្យដឹងថា លោកត្រូវខិតខំធ្វើការបន្ថែម ដូចជាបោសសម្អាតទូក ឬស្រោចទឹកទូក នៅពេលថ្ងៃក្តៅ ដើម្បីកុំឲ្យទូកប្រេះជាដើម។ មិនតែប៉ុណ្ណោះ ដើម្បីកុំឲ្យកម្មករដទៃធ្វើបាប លោកខំរក្សាទំនាក់ទំនងល្អជាមួយពួកគេ តាមរយៈការសាក់រូបឲ្យពួកគេជាដើម។ លោកប្រើថ្នាំដុសធ្មេញ លាយជាមួយធ្យូង ធ្វើជាទឹកថ្នាំដើម្បីសាក់រូប។

**សត្វសេះសមុទ្រជារូបិយប័ណ្ណ**

កម្មករលើទូកខ្លះប្រើប្រាស់គ្រឿងញៀនដែលថៅកែចែកឲ្យ និងទិញពីទូកតូចៗដែលមកសាងត្រី។ កម្មករមិនប្រើលុយសម្រាប់ការទិញដូរនោះទេ។ នៅទីនោះគេប្រើសត្វសេះសមុទ្រក្រៀមជារូបិយប័ណ្ណ។ លោក វណ្ណៈ បានឲ្យដឹងថា គេប្រើសេះសមុទ្រដូរយកគ្រឿងញៀនប្រភេទយ៉ាម៉ា ស្រា បារី នំ ឬទឹកក្រូចជាដើម។ សេះសមុទ្រប្រាំពីរអាចដូរបានស្រាមួយដប សេះសមុទ្រប្រាំអាចដូរបានបារីមួយកញ្ចប់ ហើយសេះសមុទ្របួនអាចដូរបាននំមួយកញ្ចប់ ឬទឹកក្រូចមួយដប។ លោក និងកម្មករផ្សេងទៀត តែងលួចលាក់សេះសមុទ្រតូចៗទុកដើម្បីដូរស្រា ឬបារី ប៉ុន្តែបើសេះសមុទ្រណារាងធំ ត្រូវឲ្យទៅថៅកែ ពេលខ្លះឲ្យតែថៅកែឃើញកម្មករណារកបានសេះសមុទ្រ ថៅកែមកយកតែម្តង។ សត្វសេះសមុទ្រត្រូវបានឈ្មួញទិញ ដើម្បីកែច្នៃធ្វើជាថ្នាំបុរាណ។

**ចុះទឹកក្រពើ ឡើងលើខ្លា**

ដោយទ្រាំទ្រនឹងការធ្វើការហួសកម្លាំង សម្រាកមិនគ្រប់គ្រាន់ និងការធ្វើទារុណកម្មលើរាងកាយមិនបានលោក វណ្ណៈ បានសម្រេចចិត្តគេចខ្លួនពីទូកនេសាទដោយលោតចូលសមុទ្រ និងតោងប៊ីដុងទឹកត្រីជាជំនួយ ដើម្បីហែលទៅកាន់ដីគោកប្រទេសម៉ាឡេស៊ី ដែលមានចម្ងាយប្រមាណបីបួនគីឡូម៉ែត្រពីទូក។ លោក វណ្ណៈ បញ្ជាក់ថា លោក

បានលោតចូលទឹកសមុទ្រនៅពាក់កណ្តាលអាធ្រាត្រជាមួយកម្មករថៃម្នាក់ទៀត ហើយពេលនោះទឹកសមុទ្រមិនសូវជាត្រជាក់ខ្លាំងទេ។ ដៃម្ខាងរបស់លោកចងជាប់នឹងប៊ីដុងទឹកត្រី ឯដៃម្ខាងទៀតចងជាប់នឹងកាំបិតដេរមង ដើម្បីទុកការពារខ្លួនពីត្រីឆ្លាម។ ដោយមានទឹករលកជាជំនួយ លោកបានចំណាយពេលហែលទៅច្រាំងប្រមាណ ២០ នាទីតែប៉ុណ្ណោះ។ ពិតណាស់ថា លោកត្រូវបានប៉ូលិសម៉ាឡេស៊ីជួយសង្គ្រោះ ប៉ុន្តែប៉ូលិសនោះក៏បានលក់លោកបន្ត ឲ្យទៅធ្វើជាកម្មករនៅចម្ការដូងប្រេង នៅតំបន់ដាច់ស្រយាលមួយក្នុងប្រទេសម៉ាឡេស៊ី។ លោកត្រូវបានបញ្ជូនទៅមន្ទីរពេទ្យក្រោយពីរងរបួសដោយសារកម្មករមីយ៉ាន់ម៉ាម្នាក់បានកាប់លោកមួយកាំបិត នៅពេលលោកចូលទៅជួយលើកកម្មករខ្មែរម្នាក់ទៀតឈ្មោះ ជាវ៉ា ដែលដេកដួលនៅដី ក្រោយពីត្រូវកម្មករមីយ៉ាន់ម៉ាដដែលនោះកាប់ពីរកាំបិតរួចមក។ បន្ទាប់មកលោកក៏ត្រូវបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជួយសង្គ្រោះ នឹងត្រូវបានគេបញ្ជូនឲ្យមកជួបជុំគ្រួសារនៅកម្ពុជាវិញនៅក្នុងខែឧសភា ឆ្នាំ ២០១០។ នៅពេលដែលលោកបានជួបជាមួយភរិយារបស់លោក ហើយសួរថាតើភរិយារបស់លោកគិតយ៉ាងណា នៅពេលដែលលោកមិនបានទាក់ទងមកផ្ទះអស់រយៈពេលជាងបួនឆ្នាំមកនោះ ភរិយារបស់លោក វណ្ណៈបានឆ្លើយថា គាត់ស្មានតែលោក វណ្ណៈបានស្លាប់បាត់ទៅហើយ។

**ដំណើរមកកាន់សហរដ្ឋអាមេរិកដើម្បីផ្សព្វផ្សាយសៀវភៅ**

ក្រោមការឧបត្ថម្ភ និងជ្រោមជ្រែងពីសំណាក់រោងពុម្ព Seven Stories Press ដែលជាអ្នកបោះពុម្ពសៀវភៅនេះ លោក វណ្ណៈ និងអ្នកស្រី Pederick នឹងធ្វើដំណើរមកដល់សហរដ្ឋអាមេរិកនៅថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១៩ ដើម្បីផ្សព្វផ្សាយសៀវភៅ «The Dead Eye and The Deep Blue Sea» ឬ «ពិភពអន្ធការនៅលើមហាសមុទ្រដ៏ធំល្វឹងល្វើយ»។ អ្នកស្រី Pederick សហនិពន្ធសៀវភៅនេះបាននិយាយថា៖ «រោងពុម្ព Seven Stories បានផ្តល់ឱកាសឲ្យខ្ញុំ និងវណ្ណៈ ធ្វើដំណើរទៅសហរដ្ឋអាមេរិក ដើម្បីឲ្យ វណ្ណៈ អាចប្រាប់មនុស្សនៅទីនោះ អំពីរឿងរបស់គាត់ ចែករំលែកបទពិសោធន៍ដែលគាត់បានជួបប្រទះ និងផ្សព្វផ្សាយសៀវភៅទៅកាន់ពលរដ្ឋអាមេរិក។ យើងសង្ឃឹមថា ពួកគេនឹងចាប់អារម្មណ៍ពីរឿងរបស់ វណ្ណៈ ក៏ដូចជាទិញសៀវភៅរបស់ពួកយើង។លើសពីនេះ យើងចង់ឲ្យពួកគេបានដឹងឮពីរឿងកម្មករធ្វើការលើទូកនៅតំបន់អាស៊ីអាគ្នេយ៍»។ លោក វណ្ណៈ និងអ្នកស្រី Pederick នឹងធ្វើដំណើរទៅកាន់ទីក្រុង New York ចាប់ពីថ្ងៃទី ៧ ដល់ ១២ ឧសភា រដ្ឋធានី Washington ពីថ្ងៃទី ១២ ដល់ ១៧ ឧសភា និងទីក្រុង Los Angeles ពីថ្ងៃទី ១៨ ដល់ ២១ ឧសភា។ អ្នកស្រី Pederick បានឲ្យដឹងថា សៀវភៅ«The Dead Eye and The Deep Blue Sea» ត្រូវបានសាកលវិទ្យាល័យ University of California, Los Angeles បញ្ចូលទៅក្នុងកម្មវិធីសិក្សាក្នុងមុខវិជ្ជាសិល្បៈ និងចិត្តវិទ្យា។ ដូច្នេះការធ្វើដំណើរទៅកាន់ទីក្រុង Los Angeles រដ្ឋ California នឹងផ្តល់ឱកាសឲ្យលោក វណ្ណៈ បានជួបពិភាក្សាផ្ទាល់ជាមួយនិស្សិត ដែលសិក្សាមុខវិជ្ជានោះ។ អ្នកស្រី Pederick បញ្ជាក់ថាសៀវភៅនេះ មានលក្ខណៈពិសេសប្លែកពីសៀវភៅដទៃ។ អ្នកស្រីថា៖ «មិនដែលមានសៀវភៅនិពន្ធឡើងបែបនេះទេ ជាពិសេសគឺការនិពន្ធចេញពីទស្សនៈរបស់ជនរងគ្រោះ ដែលអ្នករស់រានមានជីវិត និងភ្ជាប់ជាមួយរូបភាពពិស្តារគូរដោយជនរងគ្រោះផ្ទាល់។ ដូច្នេះ នេះគឺជារឿងមួយដែលប្លែកពីគេ ហើយកន្លងមក យើងទទួលបានមតិសាទរពីសំណាក់អ្នកអានយ៉ាងច្រើន»។ ថ្វីត្បិតតែសៀវភៅ «The Dead Eye and The Deep Blue Sea» ឬ «ពិភពអន្ធការនៅលើមហាសមុទ្រដ៏ធំល្វឹងល្វើយ» ចេញផ្សាយជាភាសាអង់គ្លេស លោក វណ្ណៈ សង្ឃឹមថា ពលរដ្ឋខ្មែរក៏អាចមើលសៀវភៅនេះយល់តាមរយៈរូបភាពពិស្តារដែលលោកបានគូរ និងបញ្ចូលទៅក្នុងសៀវភៅ។

យោងតាមអ្នកស្រី Pederick លោក វណ្ណៈ ចំណាយពេលជិត ៤ ឆ្នាំដើម្បីគូររូបទាំងអស់នៅក្នុងសៀវភៅនេះ ហើយសរុបមកការងារនិពន្ធសៀវភៅទម្រាំបានចេញផ្សាយគឺត្រូវចំណាយពេលសរុបប្រមាណ ៦ឆ្នាំ។ អ្នកនិពន្ធរូបនេះសង្ឃឹមថា នឹងអាចរកប្រាក់បានពីការលក់សៀវភៅ ឬរកបានដៃគូរក្នុងប្រទេសកម្ពុជា ដើម្បីបកប្រែសៀវភៅនេះជាភាសាខ្មែរ ក្នុងពេលឆាប់ៗខាងមុខ។

**កិច្ចប្រឹងប្រែងកែប្រែវិស័យជួញដូរមនុស្ស**

នៅឆ្នាំ ២០១២ លោក វណ្ណៈ បានទទួលរង្វាន់ «វីរជនផ្នែកជួញដូរមនុស្ស» ពីក្រសួងការបរទេសអាមេរិក ហើយរង្វាន់នោះត្រូវបានអតីតរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក និងជាបេក្ខជនប្រធានាធិបតីក្នុងការបោះឆ្នោតអាមេរិកឆ្នាំ២០១៦ លោកស្រី Hillary Clinton ប្រគល់ជូនលោកដោយផ្ទាល់ដៃ។ លោក វណ្ណៈ ចង់បន្តកិច្ចប្រឹងប្រែងធ្វើឲ្យប្រសើរឡើងក្នុងវិស័យជួញដូរមនុស្សនេះបន្តទៀត។ ហើយលោកសង្ឃឹមថា សៀវភៅដែលលោកនិពន្ធនេះអាចជួយលោកសម្រេចបំណងនេះបាន។ សម្រាប់លោក វណ្ណៈ សារសំខាន់បំផុតតាមរយៈសៀវភៅនេះ គឺលោកចង់ឲ្យប្រជាជនខ្មែរ ក៏ដូចជាពលរដ្ឋសាសន៍ដទៃ បានដឹងពីគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកដោយខុសច្បាប់ ល្បិចកលរបស់ឈ្មួញជួញដូរមនុស្ស និងបទពិសោធន៍លំបាកវេទនាពេលក្លាយខ្លួនជាទាសករ។ លោកសង្ឃឹមថា រឿងរ៉ាវរបស់លោកនឹងធ្វើឲ្យអ្នកដែលមានបំណងចង់ធ្វើចំណាកស្រុកដោយខុសច្បាប់ពិចារណាឲ្យបានល្អិតល្អន់ឡើងវិញ និងបោះបង់គំនិតនោះចោលតែម្តង។ លោកមិនចង់ឲ្យនរណាម្នាក់មានវាសនាដូចលោកឡើយ។ នាថ្ងៃអនាគតលោក វណ្ណៈ មានបំណងក្លាយខ្លួនជាអ្នកសារព័ត៌មានមួយរូប ដែលធ្វើការផ្តោតលើវិស័យជួញដូរមនុស្ស និងការឆ្លងដែនខុសច្បាប់ជាដើម។

**ជីវិតក្នុងពេលបច្ចុប្បន្ន**

បើតាមលោក វណ្ណៈ សព្វថ្ងៃនេះ ជីវភាពគ្រួសាររបស់លោកមិនទាន់ធូរជារទេ ដោយសារតែលោកគ្មានការងារពេញម៉ោង ក្រៅពីការគូររូបលក់ឲ្យអង្គការមួយចំនួន ដែលគេបានបញ្ជាទិញ។ ភរិយារបស់លោកជាស្ត្រីមេផ្ទះ ជួយមើលការខុសត្រូវកូនពីរនាក់ ដែលម្នាក់រៀនថ្នាក់ទី ៦ និងម្នាក់ទៀតរៀនថ្នាក់ទី ៣។ លោក វណ្ណៈ បញ្ជាក់ថា ចំពោះកិច្ចការសរសេរសៀវភៅនេះ លោកដំបូងឡើយទទួលបានប្រាក់ ៦ពាន់ដុល្លារ ពីរោងពុម្ព ហើយនឹងការសន្យារបស់រោងពុម្ព ថានឹងប្រគល់ជូនលោកនូវទឹកប្រាក់ចំនួន ១០% ភាគរយនៃចំនួនប្រាក់បានមកពីការលក់សៀវភៅនៅថ្ងៃខាងមុខ។ ចាប់ពីឆ្នាំ ២០១០ ជាឆ្នាំដែលលោករួចផុតពីទាសភាពសម័យទំនើបនោះមក លោកមិនចង់ ហើយក៏មិនដែលធ្វើដំណើរទៅប្រទេសថៃ និងម៉ាឡេស៊ីឡើយ។ មិនតែប៉ុណ្ណោះ លោកចង់ឲ្យកូនទាំងពីរប្រុសមួយស្រីមួយរបស់លោករៀនឲ្យបានខ្ពង់ខ្ពស់ ដើម្បីរកការងារធ្វើត្រឹមត្រូវ និងដាច់ខាតមិនឲ្យពួកគេឆ្លងដែនខុសច្បាប់ឡើយ៕

## ពលរដ្ឋស្នើឱ្យសមត្ថកិច្ចស៊ើបរកមេក្លោង ដែលបញ្ជូនពលរដ្ឋខ្មែរឱ្យចូលទៅកាប់ឈើក្រញូង នៅទឹកដីថៃ ខណៈមានពលរដ្ឋរងគ្រោះជាបន្តបន្ទាប់

https://www.chnchannel.com/article/ អត្ថបទដោយ Asmatt កាលបរិច្ឆេទ ថ្ងៃទី 6 ខែ ឧសភា ឆ្នាំ 2019

**ឧត្តរមានជ័យ ៖** មានសេចក្តីរាយការណ៍ពីសមត្ថកិច្ចថា មានពលរដ្ឋខ្មែរចូលទៅកាប់ឈើក្រញូងចំនួន៤នាក់ ត្រូវបានកងទាហានឈុតខ្មៅថៃចាប់បានម្នាក់ រត់រួច៣នាក់ នៅចំណុចអាង១៥ ចូលតាមច្រកភ្នំតាថង កាលពីវេលាម៉ោង៤ និង ៣០នាទីល្ងាចថ្ងៃអាទិត្យ ទី០៥ ខែឧសភា ឆ្នាំ ២០១៩ ម្សិលមិញនេះ ។ ជនរងគ្រោះដែលទាហានឈុតខ្មៅថៃ ចាប់នោះ មានឈ្មោះ សយ សុភ័ក្រ អាយុ១៤ឆ្នាំរស់នៅភូមិចំការចេក សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ។ តើបញ្ហានេះអាជ្ញាធរ មានសមត្ថកិច្ចជំនាញគួរមាន វិធានទប់ស្កាត់ យ៉ាងណាដែរ ? ចំពោះបញ្ហាដដែលៗ ដែលពលរដ្ឋចេះតែឆ្លងដែនទៅ កាប់ឈើក្រញូង ជារាងរាល់ថ្ងៃ នៅទឹកដីថៃនោះ?។

រំលឹក! កាលពីថ្ងៃទី២៤មេសា ឆ្នាំ២០១៩កន្លងទៅ ទាហានឈុតខ្មៅថៃ បាញ់សំលាប់ពលរដ្ឋខ្មែរបានម្នាក់និងកន្លែង និងបាញ់អោយរបួសធ្ងន់ម្នាក់ទៀត នៅទល់មុខច្រកផ្លូវ៥៦ ស្ថិតនៅភូមិ ថាសេន ឃុំឡែមក្លាត ស្រុក មឿង ខេត្តត្រាក ប្រទេសថៃ។

ពលរដ្ឋស្នើឱ្យសមត្ថកិច្ច រកមេក្លោង និងមេឈ្មួញ ដែលបញ្ជូនពលរដ្ឋខ្មែរឱ្យចូលទៅកាប់ឈើក្រញូងនៅទឹកដីថៃឱ្យឃើញហើយចាត់វិធានការតាមច្បាប់ ខណៈមានពលរដ្ឋខ្មែររងគ្រោះជាបន្តបន្ទាប់៕ ប៊ុនរិទ្ធី

# ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩

## លោក សុខសុវណ្ណ វឌ្ឍនាសាប៊ុង៖ ក្រសួងការងារគួរបង្កើតការងារក្នុងស្រុកដើម្បីកាត់បន្ថយការចំណាកស្រុក

http://km.rfi.fr/cambodia/ ដោយ អ៊ឹង ប៊ុនថន 07/05/2019

*ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្ដល់យោបល់បានបើកកិច្ចប្រជុំជាមួយក្រសួងការងារនៅថ្ងៃអង្គារនេះ ដោយសមាជិកប្រឹក្សានេះមកពីគណបក្សខ្មែរក្រោកបានយកបញ្ហាមួយចំនួនរួមមាន ពលករចំណាកស្រុក កង្វះការងារជូនពលរដ្ឋ និងប្រសិទ្ធភាពនៃការប្រើ ប័ណ្ណ បសស។ បើតាម លោក សុខសុវណ្ណ វឌ្ឍនាសាប៊ុង ក្រសួងការងារគួរបង្កើតការងារក្នុងស្រុកឲ្យបានច្រើន ជាជាងបង្កើនការបញ្ជូនពលករចេញក្រៅប្រទេស។*

លោក សុខសុវណ្ណ វឌ្ឍនាសាប៊ុង បានប្រាប់វិទ្យុបារាំងអន្តរជាតិRFIថា បញ្ហាចំបងដែលបានលើកឡើងដូចជាបញ្ហាពលករចំណាកស្រុកដែលមានចំនួនច្រើនជាហេតុនាំឲ្យបាត់បង់ចលករពលកម្មក្នុងសង្គម «ពិសេសគឺចំណាកស្រុកទៅប្រទេសថៃ» ។ តាមក្រសួងការងារ ពលករខ្មែរចំណាកស្រុកទៅថៃមានចំនួនជាង១លាន១សែននាក់ ខណៈប្រាក់ឈ្នួលទាបបំផុតទទួលបាន៣០០ដុល្លារក្នុងមួយខែ។ ប៉ុន្តែប្រធានគណបក្សខ្មែរក្រោក បានជំរុញទៅក្រសួងការងារឲ្យបង្កើតការងារក្នុងស្រុកនិងពង្រីកការបណ្ដុះបណ្ដាលជំនាញដល់ពលរដ្ឋខ្មែរឲ្យធ្វើការងារក្នុងស្រុកជាជាងខិតខំបញ្ជូនពលករចេញក្រៅប្រទេសកាន់តែច្រើន។

បើទោះជាពលករចំណាកអាចរកប្រាក់ចំណូលមកវិញបានប្រមាណ២ពាន់លានដុល្លារក្នុងមួយឆ្នាំក៏ដោយ តែលោក សុខសុវណ្ណ វឌ្ឍនាសាប៊ុង បានលើកឡើងថាប្រទេសដែលទទួលពលករខ្មែរទាំងនោះក៏បានប្រាក់ចំណេញយ៉ាងក្រាស់ក្រែលពី អាជីវកម្មរបស់ពួកគេដែរ។ ដូចនេះរដ្ឋាភិបាលកម្ពុជាគួរតែបង្កើនការងារក្នុងស្រុកឲ្យបានច្រើនដើម្បីបង្កើនការរីកចម្រើននៃសេដ្ឋកិច្ចថែមទៀត។

ចំណែក ប្រសិទ្ធភាពនៃការប្រើប័ណ្ណ បសស វិញ លោក សុខសុវណ្ណ វឌ្ឍនាសាប៊ុង បានលើកឡើងពីការរើសអើងរបស់គ្រូពេទ្យមួយចំនួនចំពោះអ្នកដែលប្រើប្រាស់បណ្ណនេះ ហើយជំរុញឲ្យក្រសួងការងារមានវិធានការដាក់ស្ដែង។ ប៉ុន្តែខាងក្រសួងបានលើកហេតុផលថា ដោយសារតែអ្នកប្រើប្រាស់បណ្ណ បសស សម្រុកនាំគ្នាទៅរកពេទ្យល្បីឈ្មោះច្រើនពេកទើបធ្វើឲ្យសេវាកម្មយឺតយ៉ាវ។

បើតាមរបាយការណ៍បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ២០១៨ កម្មករនិយោជិត២០០នាក់បានស្លាប់ ខណៈអ្នករងរបួសមានជាង៣មុឺន៤ពាន់នាក់(៣៤,៦០៨) ដោយសារគ្រោះថ្នាក់ការងារ។ ប៉ុន្តែតួលេខអ្នកស្លាប់ និងការចំណាយសំណងហានិភ័យការងារក្នុងឆ្នាំ២០១៨ បានថយចុះចំនួន ១៩.៤៥% បើធៀបនឹងឆ្នាំ២០១៧ ដែលមានអ្នកស្លាប់២២២នាក់ ក្នុងចំណោមអ្នករងគ្រោះថ្នាក់៤មុឺន៧ពាន់នាក់ (៤៧,៤៩៦ នាក់)៕

## កម្ពុជា-អ៊ីតាលី ឯកភាពរក្សាទីភ្នាក់ងារចំនួន០៨ ឲ្យបន្តផ្តល់សេវាសុំកូនអន្តរប្រទេស រយៈពេល៣ឆ្នាំបន្តទៀត

http://www.freshnewsasia.com/ 2019-05-07

**(ភ្នំពេញ)៖** កម្ពុជា-អ៊ីតាលី បានសម្រេច និងឯកភាពបន្តរក្សាចំនួនទីភ្នាក់ងារចំនួន០៨ដដែល ស្របតាមកិច្ចព្រមព្រៀង ស្តីពីការកំណត់ចំនួនទីភ្នាក់ងារសុំកូនអន្តរប្រទេស ត្រូវបានអនុញ្ញាតឲ្យផ្តល់សេវានៅកម្ពុជា ដែលបានចុះហត្ថលេខា នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ ដោយ រដ្ឋមន្ត្រី វង សូត គឺនៅមានសុពលភាពដោយស្វ័យប្រវត្តិ សម្រាប់រយៈពេល៣ឆ្នាំទៀត។ ការសម្រេចនេះ បានធ្វើឡើងនៅក្នុងជំនួបពិភាក្សាការងាររវាង លោក នឹម ថូត រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជួបជាមួយ លោក Gianni Bardini សមាជិកកណ្តាលនៃប្រទេសអ៊ីតាលី និងជាតំណាងក្រសួង

កិច្ច ការបរទេស អ៊ីតាលី និងលោកស្រី Martina តំណាងស្ថានទូតប្រទេសអ៊ីតាលី នៅរសៀលថ្ងៃទី០៧ ខែឧសភា ឆ្នាំ ២០១៩ នាទីស្តីការក្រសួងសង្គមកិច្ច។

នៅក្នុងឱកាសនោះ លោក នឹម ផូត រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច បានថ្លែងអំណរគុណចំពោះការអញ្ជើញចូលរួមរបស់គណៈប្រតិភូអ៊ីតាលីតំណាងដោយលោក GIANNI BARDINI សមាជិកគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស នៃប្រទេសអ៊ីតាលី តំណាងឲ្យអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃប្រទេសអ៊ីតាលី។ **នៅក្នុងជំនួបនារសៀលនោះបន្ថែមពីការឯកភាពគ្នាលើការបន្តរក្សាទីភ្នាក់ងារចំនួន០៨ ឲ្យផ្តល់សេវាសុំកូនអន្តរប្រទេសនៅកម្ពុជា រយៈពេល៣ឆ្នាំបន្តទៀត ភាគីទាំងពីរបានឯកភាព និងសម្រេចលើចំណុចមួយចំនួនរួមមាន៖**

១ ៖ ភាគីកម្ពុជា បានស្នើសុំចែកចំនួនទីភ្នាក់ងារទាំង០៨ ជា០២ក្រុម មួយក្រុមមានចំនួន០៤ទីភ្នាក់ងារ ដែលត្រូវបានបែងចែកដោយអាជ្ញាធរអន្តរប្រទេសនៃកម្ពុជា ត្រង់ចំណុចនេះភាគីអ៊ីតាលីបានយល់ព្រម។ ទីភ្នាក់ងារនីមួយៗមានសិទ្ធិ និងកាតព្វកិច្ចដូចគ្នា ក្នុងការទទួលខុសត្រូវ ចំពោះមុខច្បាប់ពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេសរបស់ប្រទេសកម្ពុជា និងអ៊ីតាលី។

២៖ ភាគីទាំង២បានឯកភាព ក្រោយការចុះហត្ថលេខាលើកំណត់ហេតុនេះរួចរាល់ ភាគីទាំង២ នឹងរាយការណ៍ជូនអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃប្រទេសកម្ពុជា និងអ៊ីតាលី មកពីលទ្ធផលនៃការពិភាក្សា និងចាប់ផ្តើមរៀបចំឯកសារពាក់ព័ន្ធ ជាពិសេសគោលការណ៍ណែនាំខ្លី សម្រាប់ណែនាំដល់ទីភ្នាក់ងារ ដែលត្រូវបានទទួលស្គាល់ដើម្បីដំណើរការនីតិវិធីសុំកូនអន្តរប្រទេស ស្របតាមច្បាប់សុំកូនអន្តរប្រទេសនៃប្រទេសកម្ពុជា។

៣៖ ទោះបីកិច្ចព្រមព្រៀង បន្តដោយស្វ័យប្រវត្តិ៣ឆ្នាំម្តងក៏ដោយ ក៏ភាគីទាំងពីរចាំបាច់កំណត់ពេលវេលា ទីកន្លែងដើម្បីជួបពិភាក្សាវាយតម្លៃលទ្ធផលបណ្តាឆ្នាំកន្លងមក នៃកិច្ចសហប្រតិបត្តិការ និងលើកទិសដៅសម្រាប់៣ឆ្នាំបន្តទៀត។

នៅក្នុងឱកាសនោះ លោក GIANNI BARDINI សមាជិកគណៈកម្មាធិការអាជ្ញាធរកណ្តាល សុំកូនអន្តរប្រទេសនៃប្រទេសអ៊ីតាលី ក៏បានសម្តែងការអរគុណដល់ភាគីកម្ពុជា ដែលតែងតែចូលរួមសហការជាបន្តបន្ទាប់ជាមួយភាគីអ៊ីតាលី នៅក្នុងការផ្តល់សេវាសុំកូនអន្តរប្រទេសនៅកម្ពុជាកន្លងមក។ លោកបានបង្ហាញជំហរថា នឹងបន្តកិច្ចសហប្រតិការមួយនេះ ឲ្យកាន់តែល្អប្រសើរបន្ថែមទៀត នឹងសន្យាថា មិនឲ្យមានការសុំកូនអន្តរប្រទេស ដោយខុសច្បាប់នៅកម្ពុជាឡើយ៕

## កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនិយោគឯកជន បានចុះត្រួតពិនិត្យចំនួន ១៦កន្លែង និងចែកចេញជា ០៥ក្រុម ក្នុងរាជធានីភ្នំពេញ

https://www.facebook.com/ General-Department-of-Immigration 07-05-2019

កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនិយោគឯកជន នាថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ បានចុះត្រួតពិនិត្យចំនួន ១៦កន្លែង និងចែកចេញជា ០៥ក្រុម ក្នុងរាជធានីភ្នំពេញ។ ក្នុងរាជធានីភ្នំពេញបានចុះត្រួតពិនិត្យគោលដៅចំនួន ១៦កន្លែង រួមមាន ១- រោងចក្រ INTERNATIONAL សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ១), ២- ក្រុមហ៊ុន OEZER សកម្មភាពអាជីវកម្ម ផលិតទ្វារបង្អួច (ខណ្ឌច្បារអំពៅ), ៣- រោងចក្រ សាលាវេស្ទើនអន្តរជាតិ សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌទួលគោក), ៤- ភោជនីយដ្ឋានអាហារសមុទ្រ សៀវមី សកម្មភាពអាជីវកម្ម ភោជនីយដ្ឋាន (ខណ្ឌទួលគោក), ៥- ក្រុមហ៊ុន រូ ស៊ីងហ្គាមែន សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌឫស្សីកែវ), ៦- រោងចក្រ YUAN XI GARMENT សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ១), ៧- រោងចក្រ វ៉ាយ អូលែត សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌសែនសុខ), ៨- ក្រុមហ៊ុនសម្បត្តិមានហេង សកម្មភាពអាជីវកម្ម លាយបេតុង (ខណ្ឌច្បារអំពៅ), ៩- សាលារៀន ប៉ែលធីអន្តរជាតិ សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌច្បារអំពៅ), ១០- សិប្បកម្ម HONG F PIASTIC សកម្មភាពអាជីវកម្ម ផលិតប្លាស្ទិច (ខណ្ឌច្បារ

អំពៅ), ១១- ក្រុមហ៊ុន ASIA CONCRETE សកម្មភាពអាជីវកម្ម លាយបេតុង (ខណ្ឌឫស្សីកែវ), ១២- រោងចក្រ យីង យី អ៊ិនដាសស្រ្ទី សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ១), ១៣- ក្រុមហ៊ុន បុរីមង្គលភ្នំពេញ សកម្មភាពអាជីវកម្ម សំណង់ (ខណ្ឌច្បារអំពៅ), ១៤- សាកលវិទ្យាល័យ PARA GON សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌទួលគោក), ១៥- ក្រុមហ៊ុន NOBLE សកម្មភាពអាជីវកម្ម សំណង់ (ខណ្ឌទួលគោក), ១៦- ក្រុមហ៊ុន វេស្ទើន សាខាទី២ សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌទួលគោក) បានប្រើប្រាស់ពលករខ្មែរសរុបចំនួន ៦៩៨៨នាក់ ស្រី ៦២៥៨នាក់, ប្រើប្រាស់ពលករបរទេសសរុបចំនួន ១៩០នាក់ ស្រី ៧១នាក់, ប្រើប្រាស់ទិដ្ឋាការ E ចំនួន ១៩០ មាន ២០សញ្ជាតិ អាមេរិក ០៩នាក់ ស្រី ០១នាក់, ហ្វីលីពីន ៣៧នាក់ ស្រី ២៥នាក់, ម៉ាឡេស៊ី ០៤នាក់ ស្រី ០២នាក់, អ៊ីតាលី ០១នាក់, រុស្ស៊ី ០១នាក់, ទួកមែន ០២នាក់, កាហ្សាស្ថាន ០២នាក់, ថៃ ០១នាក់ ស្រី ០១នាក់, ស៊ីមី ០១ នាក់, តួគី ០៦នាក់ ស្រី ០១នាក់, ក្រិច ០១នាក់ ស្រី ០១នាក់, អង់គ្លេស ០៣នាក់ ស្រី ០១នាក់, ហ្គីជី ០១នាក់, កូរ៉េ ០៣ នាក់, ចិន ១០០នាក់ ស្រី ៣៣នាក់, វៀតណាម ០៦នាក់ ស្រី ០៣នាក់, តៃវ៉ាន់ ០៨នាក់, មីយ៉ាន់ម៉ា ០២នាក់ ស្រី ០២នាក់, សិង្ហបុរី ០១នាក់ ស្រី ០១នាក់, អ៊ីស្រាអែល ០១នាក់ មានសៀវភៅការងារ និងប័ណ្ណការងារចំនួន ១៨៦ នាក់, គ្មានប័ណ្ណការងារចំនួន ០៤នាក់៕

## ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩

### កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនិយោគឯកជន បានចុះត្រួតពិនិត្យចំនួន ១០កន្លែង និងចែកចេញជា ០៤ក្រុម ក្នុងរាជធានីភ្នំពេញ

https://www.facebook.com/ General-Department-of-Immigration 08-05-2019

កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនិយោគឯកជន នាថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៩ បានចុះត្រួតពិនិត្យគោលដៅចំនួន ១០កន្លែង ក្នុងរាជធានីភ្នំពេញ មាន ០៤ក្រុម។ ក្នុងការត្រួតពិនិត្យគោលដៅចំនួន ១០កន្លែង មាន ១- រោងចក្រ SIGMA TEXTILES កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ១), ២- ឃ្លាំង YOSHIDA ឃ្លាំង (ខណ្ឌពោធិ៍សែនជ័យ១), ៣- រោងចក្រ សាន់តិច ភីធីអ៊ី កាត់ដេរ (ខណ្ឌទួលគោក), ៤- ក្រុមហ៊ុន NAGA WORLD កាស៊ីណូ (ខណ្ឌចំការមន), ៥- រោងចក្រ BEANTY SILD កាត់ដេរ (ខណ្ឌសែនសុខ), ៦- រោងចក្រ TRAY APPAREL កាត់ដេរ (ខណ្ឌសែនសុខ), ៧- ភោជនីយដ្ឋាន ព្យុងយ៉ាង អ៊ុនហាស៊ូ ភោជនីយដ្ឋាន (ខណ្ឌទួលគោក), ៨- ធនាគារ T B B ធនាគារ (ខណ្ឌទួលគោក), ៩- រោងចក្រ ឌី ឡាក់ស៍ INTERNATIONAL ផលិតកាបូប (ខណ្ឌពោធិ៍សែនជ័យ១) និង១០- សាលា មេជីង INTERNATIONAL អប់រំ (ខណ្ឌទួលគោក)។

ការត្រួតពិនិត្យគោលដៅទាំងនេះ បានប្រើប្រាស់ពលករខ្មែរសរុបចំនួន ២៤៦០៨នាក់ ស្រី ១៧៧៤៦នាក់, ប្រើប្រាស់ពលករបរទេសសរុបចំនួន ៨៥៧នាក់ ស្រី ៣៤៧នាក់, ប្រើប្រាស់ទិដ្ឋាការ E ចំនួន ៨៥៧, មាន ៣៤ សញ្ជាតិ រួមមាន កាណាដា ០១នាក់ ស្រី ០១នាក់, កូរ៉េ ០៣នាក់ ស្រី ០៣នាក់, ចិន ២៦១នាក់ ស្រី ១១២នាក់, តៃវ៉ាន់ ០២នាក់ ស្រី ០១នាក់, ថៃ ៣៤នាក់ ស្រី ១៨នាក់, តួគី ០២នាក់, នីហ្សេរីយ៉ា ០២នាក់, នេប៉ាល ១៣នាក់ ស្រី ០៥នាក់, ប៉័ទុយហ្គាល់ ០២នាក់ ស្រី ០១នាក់, ប៉ូឡូញ ០១នាក់, បែលហ្សិក ០១នាក់, បារាំង ០៣នាក់ ស្រី ០១នាក់ , ម៉ាឡេស៊ី ២១៦នាក់ ស្រី ៨៦នាក់, មីយ៉ាន់ម៉ា ០៣នាក់ ស្រី ០១នាក់, រុស្ស៊ី ០៣នាក់ ស្រី ០២នាក់, រ៉ូម៉ានី ០៤នាក់, វៀតណាម ២១នាក់ ស្រី ១០នាក់, សិង្ហបុរី ១៤នាក់, ស្រី ០២នាក់, ស៊ីរីណាម៉េ ០១នាក់, ហុងគ្រី ០១នាក់, ហូឡង់ ០១នាក់, ហ្គាណា ០១នាក់, ហ្វីលីពីន ១៨៣នាក់ ស្រី ៧៨នាក់, អង់គ្លេស ០៥នាក់ ស្រី ០១នាក់, ឥណ្ឌា ១២នាក់ ស្រី ០១នាក់, ឥណ្ឌូនេស៊ី ២៤នាក់ ស្រី ០៩នាក់, អ៊ីរ៉ង់ ០១នាក់, អ៊ុយកាន់ដា ០១នាក់, អាមេរិក ០៧នាក់, អាហ្វ្រិកខាងត្បូង ០២នាក់ ស្រី ០១នាក់, អាល្លឺម៉ង់ ០១នាក់, អូស្ត្រាលី ០៤នាក់, អេស្ប៉ាញ ០២នាក់, កូរ៉េខាងជើង ១៨នាក់

ស្រី ១៦នាក់ មានសៀវភៅការងារ និងប័ណ្ណការងារចំនួន ៨៣៩នាក់ និងគ្មានប័ណ្ណការងារចំនួន ១៨នាក់ ជនជាតិកូរ៉េខាងជើង (ខណ្ឌទួលគោក )៕

## កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនយោគឯកជន បានចុះត្រួតពិនិត្យសរុប ១៦គោលដៅ ក្នុងខេត្តចំនួន ០៦

https://www.facebook.com/ General-Department-of-Immigration 09-05-2019

កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនយោគឯកជន នាថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ បានចុះត្រួតពិនិត្យសរុប ១៦គោលដៅ ក្នុងខេត្តចំនួន ០៦ មានខេត្តព្រះសីហនុ, កំពង់ស្ពឺ , កំពង់ចាម, ប៉ៃលិន, សៀមរាប និងពោធិ៍សាត់។

ក្នុងការត្រួតពិនិត្យគោលដៅចំនួន ១៦កន្លែង មាន ១. ការដ្ឋានសំណង់ រចនា និងសំណង់អន្តរជាតិហ្វានថាង មានទីតាំងស្ថិតនៅសង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ, ២. ក្រុមហ៊ុន Meridian Fashion (Cambodia), ៣. ក្រុមហ៊ុន លី វៃ យីនស័រ, ៤. ក្រុមហ៊ុន ថុង ខាង មានទីតាំងស្ថិតនៅភូមិធ្លក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ, ៥. ឥណ្ឋាលក់ម៉ុង, ៦. សាលាអន្តជាតិ សិស្សអាស៊ាន មានទីតាំងស្ថិតនៅភូមិតាំងក្រង់ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម, ៧. សណ្ឋារគារ ហេង ស៊ីវណ្ណ, ៨. SUPER RICH THE BEST CASINO មានទីតាំងស្ថិតនៅភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន, ៩. មន្ទីរពេទ្យអន្តរជាតិ រស្មីអង្គរ, ១០. សណ្ឋាគារ ហុង កុង ជិន ប៉ារ, ១១. ក្រុមហ៊ុន ViVo, ១២. ហាង ទំនិញថៃផ្តាច់មុខ លក់ដុំ និងរាយ, ១៣. ភោជនីយដ្ឋានចិន ស៊ូស៊ាងយាន, ១៤. SOWARAE Souvenir, ១៥. Sky Angkor Airline មានទីតាំងស្ថិតនៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាម ខេត្តសៀមរាប និង១៦. ក្រុមហ៊ុន (Cambodian power Grid Co .LTD ) មានទីតាំងស្ថិតនៅភូមិអូរថ្កូវ សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្ត ពោធិ៍សាត់។

ការត្រួតពិនិត្យគោលដៅទាំងនេះ បានប្រើប្រាស់ពលករសរុបចំនួន ១៦៦២នាក់ ស្រី ១១២៣នាក់ (ពលករខ្មែរ ១៥២៧នាក់ ស្រី ១១០៤នាក់ និងពលករបរទេសសរុបចំនួន ១៣៥នាក់ ស្រី ១៩នាក់) រួមមាន ០៧សញ្ជាតិ ចិន ៩៣នាក់ ស្រី ១៣នាក់, ឥណ្ឌា ០១នាក់, NGA ០១នាក់, កូរ៉េ ១០នាក់ ស្រី ០៥នាក់, ឥណ្ឌូនេស៊ី ១៩នាក់, ហ្វីលីពីន ០៦នាក់ និងអូបេគីស្ថាន ០១នាក់ ប្រើប្រាស់ទិដ្ឋាការប្រភេទ E ១៣៥នាក់, មានប័ណ្ណការងារ(២០១៩) សរុបចំនួន ១២២នាក់, មានបង្កាន់ដៃ(២០១៩) សរុបចំនួន ០៦នាក់, គ្មានប័ណ្ណការងារសរុបចំនួន ០៧នាក់ (ប៉ៃលិន ០៦នាក់ និងសៀមរាប ០១នាក់)៕

# ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩

## កម្ពុជា-ហ្វីលីពីន បន្តអនុវត្តកិច្ចសហប្រតិបត្តិការជួយពលករ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៩ ម៉ោង ១៤:៤១ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជា និងហ្វីលីពីនបានសន្យាបន្តអនុវត្តកិច្ចសហប្រតិបត្តិការជួយពលករទៅវិញទៅមកតាមរយៈកិច្ចព្រមព្រៀងទ្វេភាគីដែលបានចុះអនុស្សារណៈយោគយល់គ្នាកន្លងមក ។ ក្នុងជំនួបពិភាក្សាការងារទ្វេភាគីរវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយលោក Christopher B.MONTERO ឯកអគ្គរដ្ឋទូតសាធារណរដ្ឋហ្វីលីពីនប្រចាំកម្ពុជា ភាគីទាំងពីរបានបន្តអនុវត្តនូវសេចក្តីថ្លែងការរួមដែលបានចុះហត្ថលេខាព្រមព្រៀមគ្នាពីការធ្វើកិច្ចសហប្រតិបត្តិការជួយពលករទៅវិញទៅម កាលពីខែធ្នូ ឆ្នាំ២០១៧កន្លងមក ។

ក្នុងជំនួបនាព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងការងារលោកអ៊ិត សំហេង បានលើកឡើងថា តាមស្មារតីកិច្ចសហប្រតិបត្តិការទ្វេភាគីមួយនេះបានផ្តល់សេវាដល់ពលករទាំងក្នុង និងក្រៅប្រទេសអាចប្រើប្រាស់បានតាមរយៈស្ថានទូតដែលមានទីតាំងនៅប្រទេសណាមួយ ។ ក្នុងឱកាសនោះដែរលោករដ្ឋមន្ត្រីក៏បានស្នើដល់ឯកឧត្តមអគ្គរដ្ឋទូតហ្វីលីពីន សូមជួយផ្សព្វផ្សាយ និងជូនដំណឹងដល់ពលករហ្វីលីពីន ដែលកំពុងធ្វើការនៅក្នុងប្រទេសកម្ពុជា មានចំនួនប្រមាណ៣៥០០នាក់ ដោយក្នុងនោះមានពលករខ្លះមិនទាន់បានចុះបញ្ជីធ្វើប័ណ្ណការងារនៅឡើយ ដូច្នេះសូមចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួង ដើម្បីទទួលបានប័ណ្ណការងារ និងភាពស្របច្បាប់ព្រមទាំងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនទៀតដូចជា ពលករកម្ពុជាដែរ ។

ក្នុងជំនួបនោះដែរលោករដ្ឋមន្ត្រីបានលើកឡើងថា កម្ពុជា និងហ្វីលីពីនមិនទាន់មានកិច្ចសហប្រតិបត្តិការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅឡើយនោះទេ ។ លោករដ្ឋមន្ត្រីចង់ឲ្យមានកិច្ចសហប្រតិបត្តិការផ្នែកបណ្តុះបណ្តាលបច្ចេកទេសនេះទទួលស្គាល់ជំនាញពីគ្នាទៅវិញទៅមក ដើម្បីទទួលបាននូវអត្ថប្រយោជន៍ជាច្រើនថែមទៀត ។ រដ្ឋមន្ត្រីក្រសួងការងារក៏លើកឡើងថា «ពេលវេលាពិតជាលឿនណាស់សម្រាប់ឯកអគ្គរដ្ឋទូតហ្វីលីពីនក្នុងការបំពេញបេសកម្មដ៏មានអត្ថន័យមួយនេះ នៅលើទឹកដីកម្ពុជា ។ ព្រោះថា កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរចាប់ពីដើមរៀងមកដល់ពេលនេះមានភាពល្អប្រសើរទាំងកិច្ចសហប្រតិបត្តិការលើកផ្នែកនយោបាយ សេដ្ឋកិច្ច និងទេសចរណ៍» ។

លោកបន្ថែមថា កិច្ចសហប្រតិបត្តិការនេះបានធ្វើឲ្យអ្នកវិនិយោគហ្វីលីពីនអញ្ជើញមកវិនិ យោគនៅកម្ពុជាកាន់តែច្រើនបន្ថែមទៀត ខណៈមានជើងហោះហើរត្រង់រវាងប្រទេសទាំងពីរ ។ នៅក្នុងជំនួបនោះដែរឯកអគ្គរដ្ឋទូតសាធារណរដ្ឋហ្វីលីពីនបញ្ចប់អាណត្តិនៅកម្ពុជាបានឯកភាពនូវការលើកឡើងរបស់លោក អ៊ិត សំហេង ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការរវាងប្រ ទេសទាំងពីរ ពិសេសក្នុងការជួយពលករដែលកំពុងបម្រើការងារនៅបណ្តាប្រទេសមួយចំនួន ។ លោកក៏បានលើកឡើងថា ប្រទេសហ្វីលីពីនក៏បានកំពុងបញ្ហាទេសន្តប្រវេសន៍របស់ពលករកម្ពុជាស្វែងរកការងារដូចពលករកម្ពុជាផងដែរ ៕

## រាជរដ្ឋាភិបាល ថា ពលករខ្មែរនៅក្រៅប្រទេស មិនមែនស្ថិតក្នុងភាព ជាទាសករទេ

https://www.dap-news.com/ ByID:115 Posted on 09 May 2019 | 15:00

ភ្នំពេញ ៖ ក្រោយពីមាន មតិមួយចំនួនលើកឡើងថា ពលករខ្មែរធ្វើការងារ នៅក្រៅប្រទេស ដូចជាទាសករនោះ អ្នកនាំពាក្យ រាជរដ្ឋាភិបាល បានឆ្លើយតបវិញថា ពលករខ្មែរធ្វើការងារ នៅក្រៅប្រទេស គឺមិនស្ថិតនៅក្នុងស្ថានភាពជាទាសករដូចសម័យ កាលដែលប្រទេសអភិវឌ្ឍមួយចំនួន បានជួញដូរមនុស្សដើម្បី បំពេញកង្វះខាត កម្លាំងពលកម្មនោះទេ។

យោងតាមសេចក្តីថ្លែងការណ៍របស់ អ្នកនាំពាក្យរាជរដ្ឋាភិបាល នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៩ បានឲ្យដឹងថា "ពលករខ្មែរដែលធ្វើការនៅក្រៅប្រទេស គឺមិនស្ថិតនៅក្នុងស្ថានភាពជាទាសករ ដូចសម័យកាលដែលប្រទេសអភិវឌ្ឍមួយចំនួន បានជួញដូរមនុស្សដើម្បីបំពេញកង្វះខាត កម្លាំងពលកម្មមកនោះទេ។និន្នាការចំណាកស្រុកទៅកាន់បរទេស ដើម្បីការងារនឹងជីវភាពរួមជា មួយបទពិសោធ គឺជាលក្ខខណ្ឌសកល ដែលប្រជាពលរដ្ឋនៃប្រទេសមួយចំនួនធំ ក្នុងលោក កំពុងតែអនុវត្តជាក់ស្តែង"។ អ្នកនាំពាក្យបន្តថា រាជរដ្ឋាភិបាលក៏បានបង្កើត ទីភ្នាក់ងារជាតិមុខរបរ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ឲ្យស្របទៅតាមតម្រូវការទីផ្សារពលកម្មផ្ទៃក្នុង និងក្រៅប្រទេស។អ្នកនាំពាក្យថា ពលករខ្មែរដែលកំពុងបំពេញការងារនៅក្រៅប្រទេសទទួលបានផលប្រយោជន៍ ពីការអនុវត្តច្បាប់អង្គការអន្តរជាតិដូចជា ផ្នែកអន្តោប្រវេសន៍ (IOM) ,អង្គការពលកម្មអន្តរជាតិ (ILO) ,អង្គការពាណិជ្ជកម្មពិភពលោក (WTO) ក៏ដូចជាច្បាប់ និងលក្ខខណ្ឌផ្សេងៗបន្ថែមទៀត។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាល កំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការពារពលករខ្លួន ដែលមានចំនួនជាង ១,២លាននាក់ កំពុងធ្វើការនៅក្រៅប្រទេស តាមរយៈអនុស្សារនៈ នៃកិច្ចព្រមព្រៀងទ្វេភាគីរវាង រាជរដ្ឋាភិបាលកម្ពុជា ជាមួយរាជរដ្ឋាភិបាលមួយចំនួនដែលជាម្ចាស់ផ្ទះ (MoU)។

សូមរំលឹកថា ពលករខ្មែរ ដែលធ្វើការនៅ ក្រៅប្រទេស បានបញ្ជូនប្រាក់មកកាន់មាតុភូមិរបស់ខ្លួនជាង ២,៣ ពាន់លានដុល្លារ ជារៀងរាល់ឆ្នាំ ។ព្រមទាំងធ្វើឲ្យក្រុមគ្រួសារមានជីវភាព កាន់តែល្អប្រសើរ រស់នៅក្នុងបរិយាកាស មានសន្តិភាព ស្ថិរភាព សុភមង្គល និងការអភិវឌ្ឍ រួមជាមួយរាជរដ្ឋាភិបាល ដើម្បីរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ជាង៧.៥% តាមការវាយតម្លៃដោយធនាគារ ពិភពលោក ។ ដោយ ៖ អេង ប៊ូឆេង

## រដ្ឋមន្រ្តីការងារស្នើទូតចប់អាណត្តិរបស់ហ្វីលីពីន ជំរុញពលករហ្វីលីពីននៅកម្ពុជា មកធ្វើប ណ្ណការងារឱ្យបានគ្រប់គ្នា

http://www.freshnewsasia.com/index.php/ 2019-05-09

(ភ្នំពេញ)៖ ក្នុងជំនួបជាមួយលោក Christopher B.MONTERO ឯកអគ្គរដ្ឋទូតចប់អាណត្តិរបស់ហ្វីលីពីន ប្រចាំកម្ពុជា នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងការងារ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្នើដល់អគ្គរដ្ឋទូតហ្វីលីពីនជួយជំរុញដល់ពលករហ្វីលីពីន ដែលកំពុងបម្រើការនៅ កម្ពុជា សូមរួសរាន់ចុះបញ្ជីការងារជាមួយក្រសួង ការងារឱ្យបានគ្រប់គ្នា។

លោករដ្ឋមន្ត្រីបានឱ្យដឹងថា ពលករហ្វីលីពីនមួយចំនួនដែលកំពុងធ្វើការនៅកម្ពុជា មិនទាន់បានចុះបញ្ជីធ្វើប ណ្ណការងារនៅឡើយ ដូច្នេះសូមឱ្យពួកគេមកចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម របស់ក្រសួងការងារ ដើម្បីទទួលបានប័ ណ្ណការងារ និងធ្វើការដោយស្របច្បាប់។ លោក អ៊ិត សំហេង បានលើកឡើងថា តាមស្មារតីកិច្ចសហប្រតិបត្តិការទ្វេភា គីមួយនេះ បានផ្តល់សេវាដល់ពលករទាំងក្នុង និងក្រៅប្រទេសអាចប្រើប្រាស់បាន តាមរយៈស្ថានកុងស៊ុល ឬស្ថានទូត ដែលមានទីតាំងនៅប្រទេសណាមួយ។ ក្នុងន័យថា បើហ្វីលីពីនមានស្ថានកុងស៊ុល ឬស្ថានទូត ហើយកម្ពុជាមិនមាន ហ្វីលីពីនអាចជួយផ្តល់សេវាផ្សេងៗដល់ពលករកម្ពុជាបាន ផ្ទុយទៅវិញបើហ្វីលីពីនមិនមានស្ថានកុងស៊ុល ស្ថានទូត នោះទេ ហើយកម្ពុជាមាននៅក្នុងប្រទេសណាមួយ នោះស្ថានកុងស៊ុល ឬស្ថានទូតកម្ពុជានឹងជួយពលករហ្វីលីពីនវិញ ដូចគ្នាដែរ។

ជាមួយគ្នានោះ លោករដ្ឋមន្ត្រី អ៊ិត សំហេង ក៏បានលើកឡើងថា កម្ពុជា និងហ្វីលីពីនមិនទាន់មានកិច្ចសហ ប្រតិបត្តិការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅឡើយនោះទេ ដូច្នេះលោកចង់ឱ្យមានកិច្ចសហប្រតិបត្តិ ការផ្នែកបណ្តុះបណ្តាលបច្ចេកទេសនេះ ទទួលស្គាល់ជំនាញពីគ្នាទៅវិញទៅមក ដើម្បីទទួលបាននូវអត្ថប្រយោជន៍ជា ច្រើនថែមទៀត។ លោករដ្ឋមន្ត្រីបានបន្ថែមថា កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ចាប់ពីដើមរៀងមកដល់ពេល នេះ មានភាពល្អប្រសើរទាំងកិច្ចសហប្រតិបត្តិការលើកផ្នែកនយោបាយ សេដ្ឋកិច្ច និងទេសចរណ៍។ កិច្ចសហប្រតិបត្តិ ការនេះ បានធ្វើឲ្យអ្នកវិនិយោគហ្វីលីពីនមកវិនិយោគនៅកម្ពុជាកាន់តែច្រើនបន្ថែមទៀត ខណៈមានជើងហោះហើរត្រង់ រវាងប្រទេសទាំងពីរ។

ឯកអគ្គរដ្ឋទូតហ្វីលីពីនរូបនេះ បានឯកភាពនូវការលើកឡើងរបស់លោក អ៊ិត សំហេង ពាក់ព័ន្ធនឹងកិច្ចសហ ប្រតិបត្តិការរវាងប្រទេសទាំងពីរ ពិសេសក្នុងការជួយពលករ ដែលកំពុងបម្រើការងារនៅបណ្តាប្រទេសមួយចំនួន៕

## អាជ្ញាធរថៃដោះលែងអ្នកទោស២នាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៩ ម៉ោង ១១:២៤ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ ក្រុមអាជ្ញាធរថៃបានធ្វើការដោះលែងអ្នកទោសខ្មែរចំនួន២នាក់ឱ្យមានសេរីភាព និងនាំខ្លួនយកមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជាតាមមាត់ច្រកទ្វារអន្តរជាតិ កាលពីវេលាម៉ោង៣រសៀលថ្ងៃទី៩ ឧសភា ២០១៩ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

អ្នកទោសខ្មែរទាំង២នាក់ខាងលើដែលក្រុមអាជ្ញាធរថៃដោះលេងឱ្យរួចផុតពីទោស ក្នុងនោះម្នាក់ឈ្មោះ នៅ ស៊ុត ភេទប្រុស អាយុ៣៤ឆ្នាំ និងម្នាក់ទៀតឈ្មោះវ៉ាន់ ញ៉ក់ ភេទប្រុស អាយុ៣៤ឆ្នាំ ។ អ្នកទាំង២រស់នៅភូមិបន្ទាយចាស់ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាត ខេត្តឧត្តរមានជ័យ ។ អ្នកទាំង២នាក់ត្រូវបានក្រុមទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី១២ ឧសភា ២០១៦ហើយបានជាប់ពន្ធនាគារនៅខេត្តស៊ីសាកេត ប្រទេសថៃ ជាប់ចោទពីបទឆ្លងដែនដោយខុសច្បាប់កាប់ឈើគ្រញូងចូលតាមច្រកអូរខ្សាច់ ស្ថិតក្នុងភូមិសាស្រ្តខ្មែរភូមិ ចារថ្មី ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដែលស្ថិតនៅទល់មុខភូមិឃុំស្ទឹងចាន់ ស្រុកឃុនហាន ខេត្តស៊ីសាកេត ប្រទេសថៃ។

មន្រ្តីកម្ពុជាដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំបានឱ្យដឹងថា ក្រោយពីបានទទួលអ្នកទោសខ្មែរ២នាក់ពីក្រុមអាជ្ញាធរថៃរួចមកនោះ សមត្ថកិច្ចបានធ្វើការណែនាំ និងធ្វើកិច្ចសន្យាឱ្យឈប់ឆ្លងដែនបន្តទៀត បន្ទាប់មកសមត្ថកិច្ចបានឱ្យវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារក្នុងថ្ងៃដដែល៕

## ស្ត្រីប៉ាគីស្ថានរាប់រយនាក់ត្រូវបានគេលក់ដូចជាទំនិញ ឱ្យទៅជនជាតិចិនដើម្បីធ្វើជាប្រពន្ធ

https://khmernote.com/news/ May 9, 2019

ប្រទេសប៉ាគីស្ថានត្រូវបានគេរាយការណ៍ថា បានក្លាយជាទីផ្សារអាពាហ៍ពិពាហ៍ថ្មីមួយសម្រាប់បុរសជនជាតិចិន ដែលចង់ស្វែងរកកូនក្រមុំ ខណៈដែលរឿងរ៉ាវបានលេចឡើងទាក់ទងអំពីស្ត្រី និងក្មេងស្រីរាប់រយនាក់មកពីជនជាតិភាគតិច និងក្រីក្រ មកពីប្រទេសអាស៊ីខាងត្បូងមួយនេះ ត្រូវបានគេនាំយកទៅឆ្ងាយពីគ្រួសាររបស់ពួកគេ និងត្រូវបានគេជួញដូរឱ្យទៅប្រទេសចិន។ ឈ្មួញកណ្តាលត្រូវបានគេរាយការណ៍ថា ត្រូវបានជួយដោយពួកបព្វជិតគ្រិស្ទាន ដែលត្រូវគេជួលឱ្យស្វែងរកកូនក្រមុំប៉ាគីស្ថាន ដើម្បីធ្វើជាប្រពន្ធពួកបុរសជនជាតិចិន។

ពួកឈ្មួញត្រូវបានគេរាយការណ៍ថា បានចំណាយប្រាក់រាប់ពាន់ដុល្លារ និងបានសន្យាដល់គ្រួសារពួកនារីទាំងនោះថា កូនៗរបស់ពួកគេនឹងត្រូវបានរៀបការជាមួយជនជាតិចិន ដែលមានទ្រព្យសម្បត្តិ និងបានប្រែខ្លួនជាគ្រិស្តបរិស័ទ។ ប៉ុន្តែគ្រួសារខ្លះនិយាយថា ពួកគេមិនដែលទទួលបានលុយពីឈ្មួញកណ្តាលទេ។ ក៏មានរបាយការណ៍ខ្លះថា ពួកនារីត្រូវបានវាយដំធ្វើបាបដោយប្តីបរទេសរបស់ពួកគេទៀតផង។

រដ្ឋាភិបាលចិនក៏ស្ថិតនៅក្រោមការរិះគន់ផងដែរ សម្រាប់ការចេញទិដ្ឋាការទាំងមិនបានដេញដោលដជីកឱ្យច្បាស់ការដល់នារីទាំងនោះ។ យ៉ាងណាមិញតម្រូវការរបស់ចិនសម្រាប់កូនក្រមុំបរទេសនេះ ត្រូវបានផ្សារភ្ជាប់ទៅនឹងអតុល្យភាពយេនឌ័រដែលបណ្តាលមកពីគោលនយោបាយកូនតែមួយទើបតែត្រូវបានប្រទេសចិនបោះបង់ចោល។ កូនក្រមុំក៏ត្រូវបានគេនាំយកទៅប្រទេសចិនពីបណ្តាប្រទេសក្នុងអាស៊ីផ្សេងទៀតដែលរួមមានប្រទេសវៀតណាម ឡាវ និងកូរ៉េខាងជើងផងដែរ៕ អត្ថបទ៖ លីដា

# ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

## សម្តេចក្រឡាហោម ស ខេង ប្រាប់អាជ្ញាធរត្រូវទប់ស្កាត់ ការលួចឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ ដើម្បីបញ្ចៀសការប្រឈមជាមួយអាជ្ញាធរថៃ

http://freshnewsasia.com/ 2019-05-10

**(បន្ទាយមានជ័យ)៖** ថ្លែងចេញពីខេត្តបន្ទាយមានជ័យ ក្នុងពិធីប្រកាសចូលកាន់តំណែងអភិបាលខេត្ត និងអភិបាលរង នៅព្រឹកថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានណែនាំអាជ្ញាធរបង្កើនការយកចិត្តទុកដាក់ ទប់ស្កាត់ពលរដ្ឋឆ្លងដែន ចូលប្រទេសថៃខុសច្បាប់ ដើម្បីបញ្ចៀសការប្រឈមុខនឹងវិធានការពីអាជ្ញាធរថៃ និងដើម្បីកុំឲ្យពលរដ្ឋក្លាយជាជនរងគ្រោះ នៃអំពើជួញដូរមនុស្ស។ សម្តេចក្រឡាហោម ស ខេង ក៏បានក្រើនរំលឹកអាជ្ញាធរ និងសមត្ថកិច្ចទប់ស្កាត់បទល្មើសលាងសំអាតប្រាក់ ហើយត្រូវចៀសឲ្យផុតពីការជាប់ពាក់ព័ន្ធ នឹងបទល្មើសនេះ ត្រូវទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ បង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រង និងការពារសុវត្ថិភាពជនបរទេសបន្តអនុវត្តឲ្យបានល្អ នូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការងារសំខាន់ៗមួយចំនួនទៀត។

លើសពីនេះ សម្តេចប្រមុខដឹកនាំក្រសួងមហាផ្ទៃ បានផ្តល់អនុសាសន៍ឲ្យអភិបាល និងអភិបាលរងខេត្ត ដែលទើបតែងតាំង បន្តរួមគ្នាជាមួយក្រុមប្រឹក្សា មន្ត្រីរាជការ និងកម្លាំងប្រដាប់អាវុធ ខិតខំថែរក្សាសុខសន្តិភាព និងស្ថេរភាពនយោបាយ តាមរយៈការអនុវត្តច្បាប់ ការផ្សព្វផ្សាយ និងអប់រំពលរដ្ឋ អំពីផលវិបាកនៃការផ្តួលរាជរដ្ឋាភិបាលស្របច្បាប់ និងការធ្វើបដិវត្តពណ៌។ សម្តេចក្រឡាហោម បានគូសបញ្ជាក់ថា ប្រជាពលរដ្ឋកំពុងរីករាយទទួលផលពីសេចក្តីសុខ សន្តិភាព និងការអភិវឌ្ឍ ហើយកត្តានេះបានធ្វើឲ្យក្រុមប្រឆាំងខ្លះ រកវិធីអូសទាញ ពលរដ្ឋឲ្យប្តូរទស្សនៈតាមរយៈការបំផុសបំផុលឲ្យធ្វើសកម្មភាពខុសច្បាប់ផ្សេងៗ ប៉ុន្តែលទ្ធផល នៃចំនួនអ្នកបោះឆ្នោតកន្លងទៅនេះ បានបញ្ជាក់ថា ពលរដ្ឋផ្តល់យុត្តិធម៌មករាជរដ្ឋាភិបាល។ សម្តេច ស ខេង សង្កត់ធ្ងន់ទៀតថា ក្រុមប្រឆាំងបានយកពាក្យផ្លាស់ប្តូរជាវិជ្ជមាន មកប្រព្រឹត្តសកម្មភាពខុសច្បាប់ និងបិទបាំងការប៉ុនប៉ងធ្វើបដិវត្តពណ៌ ប៉ុន្តែសម្រាប់រាជរដ្ឋាភិបាលការផ្លាស់ប្តូរ គឺសំដៅដល់ការខិតខំធ្វើកំណែទម្រង់គ្រប់វិស័យ ដើម្បីផ្តល់សេចក្តីសុខជូនពលរដ្ឋ ធ្វើឲ្យប្រទេសជាតិមានសន្តិភាព និងការរីកចម្រើន។

សម្តេចក្រឡាហោម ក៏បានផ្តល់អនុសាសន៍ឲ្យអភិបាល និងអភិបាលរងថ្មីនៃខេត្តបន្ទាយមានជ័យ បង្កើនការពង្រឹងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ត្រូវលុបបំបាត់ឲ្យបានក្នុងឆ្នាំ២០១៩នេះ ចំពោះទីកំសាន្តមានគ្រឿងញៀន ទប់ស្កាត់ និងបង្ក្រាបការចែកចាយ និងប្រើប្រាស់គ្រឿងញៀន និងការព្រឹត្តបទល្មើសផ្សេងៗក្នុងសង្គម។

ទន្ទឹមនឹងការផ្លាស់ប្តូរ អភិបាលខេត្តថ្មីនេះ សម្តេចបានសម្តែងការកោតសរសើរអភិបាលខេត្តចាស់ និងអភិបាលខេត្តថ្មី ដោយបញ្ជាក់ថា ឧត្តមមន្ត្រីទាំងពីររូបនេះ សុទ្ធតែមានស្នាដៃបំពេញការងារបានយ៉ាងល្អ ហើយសម្តេចស្នើឲ្យក្រុមប្រឹក្សា និងមន្ត្រីរាជការចំណុះរដ្ឋបាលខេត្ត បន្តខិតខំរួមគ្នាអភិវឌ្ឍន៍ខេត្តបន្ទាយមានជ័យ ឲ្យកាន់តែរីកចម្រើនបន្ថែមទៀត។

ក្នុងនាមសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា, សម្តេចក្រឡាហោម ស ខេង ក៏បានថ្លែងអំណរគុណឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តបន្ទាយមានជ័យ ដែលបានផ្តល់ការគាំទ្រ ទាំងស្មារតី និងធនធាន ពិសេសក្នុងការងារជួយសង្គ្រោះពលរដ្ឋ៕

# ធ្លាប់តែពូខ្មែរយើងចាញ់បោកមេខ្យល់! ឥលូវចិន២៦នាក់ ចាញ់បោកមេខ្យល់ពីចិនមកធ្វើការនៅកំពង់សោម កំពុងដាច់បាយស្នើជំនួយពីស្ថានទូត

http://www.sharekhdaily.com/ By Admin May 11, 2019

កំពង់សោម៖ ជនជាតិចិនប្រុសស្រីចំនួន២៦នាក់ ក្នុងនោះមានស្រីម្នាក់ បាននាំគ្នាមកកាន់ស្ថានទូតចិន ដើម្បីសុំការអន្តរាគមន៍រកដំណោះស្រាយជូនពួកគាត់ ក្រោយបានចាញ់បោកមេខ្យល់ពីប្រទេសចិន មករកការងារធ្វើនៅកំពង់សោម ខេត្តព្រះសីហនុ តែបែរជាគ្មានការងារឲ្យពួកគាត់ធ្វើ ជាហេតុធ្វើឲ្យពួកគាត់គ្មានលុយសម្រាប់ទិញអាហារហូបចុកនោះទេ។

ហេតុការណ៍នេះបានកើតឡើងកាលពីវេលាម៉ោង ៨និង១៥នាទី ព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៩ នៅចំណុចស្ថានទូតចិន ដែលមានទីតាំងនៅក្នុងសង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ប្រភពព័ត៌មានបានឲ្យដឹងថា ពួកជាជនជាតិចិន មានគ្នា២៦នាក់ ក្នុងនោះមានស្រីម្នាក់ ប្រុស២៥នាក់ បានចាញ់បោកមេខ្យល់នៅប្រទេសចិនថាមករកការងារនៅកំពង់សោម ខេត្តព្រះសីហនុ តែពេលមកដល់បែរជាមិនដឹងធ្វើការអី គ្មានការងារឲ្យពួកគាត់ធ្វើទៅវិញ សូម្បីតែលុយក៏ពួកគាត់គ្មានសម្រាប់ទិញអីហូបដែរ ទើបសម្រេចចិត្តនាំគ្នាធ្វើដំណើរមកកាន់ស្ថានទូតចិន ដើម្បីសុំឲ្យខាងស្ថានទូតជួយធ្វើការដោះស្រាយជូនពួកគាត់ ។ ហើយខាងស្ថានទូតមកបានចេញមកអន្តរាគមន៍ព្យាយាមរក ដំណោះស្រាយ និងបានឲ្យថវិកាខ្លះទៅកាន់ពួកគាត់ ដើម្បីទុកទិញអាហារហូប និងឲ្យវិលត្រឡប់ទៅកំពង់សោមវិញផងដែរ៕

# បង្ក្រាបទីតាំងម៉ែសិចនៅហាងជំនោរត្រជាក់ ៦៨៦៨ ឃាត់ស្ត្រីរកស៊ីផ្លូវភេទ៩នាក់, ថៅកែស្រីរត់បាត់

https://khmeread.com/ May 11, 2019 12:50PM

សៀមរាប ៖ កម្លាំងប៉ូលិសការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចុះខេត្តសៀមរាប បានចុះបង្ក្រាបទីតាំងម៉ាស្សាយីហោ ជំនោរត្រជាក់ ៦៨៦៨ នៅភូមិស្វាយដង្គុំ សង្កាត់ស្វាយដង្គុំ ក្រុង.ខេត្តសៀមរាប កាលពីថ្ងៃទី០៩ ខែ០៥ ឆ្នាំ២០១៩ វេលាម៉ោង៩និង១៥នាទី យប់។

លោកវរសេនីយ៍ឯក ជា ហេង នាយការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានប្រាប់ឱ្យដឹងថា នៅវេលាម៉ោង៩ និង១៥នាទីយប់ កម្លាំងប៉ូលិសជំនាញបានចុះស្រាវជ្រាវ និងបង្ក្រាបទីតាំង ហាងម៉ាស្សា ដែលមានម្ចាស់ឈ្មោះ រីន ភេទ ស្រី (គេចខ្លួន) មិនស្គាល់អត្តសញ្ញាណ ហើយប្រមូលបានស្ត្រីរកស៊ីផ្លូវភេទបានចំនួន ៩ នាក់និងបានដកហូតបានស្រោមអនាម័យប្រើរួចបានមួយចំនួនធំ។

ផ្អែកតាមការសម្ភាសន៍ស្ត្រីរកស៊ីផ្លូវភេទទាំង ៩ នាក់ បានឆ្លើយថាថៅកែឈ្មោះ រីន មិនស្គាល់អសយដ្ឋាន បើកហាងម៉ាស្សាហើយរកស៊ីផ្លូវភេទ ដោយរួមភេទ ម្តង៤០០០០រៀល ទៅ ៥០០០០រៀល ហើយត្រូវថៅកែដកយកពាក់កណ្តាល។ ប៉ុន្តែពេលព្រឹកឡើង បានថៅកែទៅទូទាត់យកប្រាក់ពីពួកខ្លួន រួចថៅកែទៅផ្ទះវិញបាត់ ពេលយប់ថៅកែមិនបានមកមើលទេ។

ក្រោយពីការឃាត់ខ្លួនស្ត្រី ម៉ាស្សារួចមក កម្លាំងប៉ូលិសជំនាញបានរៀបចំបញ្ជូន ស្ត្រីរកស៊ីផ្លូវទាំង ៩ នាក់ ទៅមន្ទីរសង្គមកិច្ចខេត្តដើម្បីអប់រំកែប្រែ និងផ្តល់ជំនាញផ្សេងៗដែលពួកគាត់អាចទទួលយកបាន៕

## បង្រ្កាបទីតាំងម៉ាស្សាកោសជប់ លួចបំរើសេវាផ្លូវភេទ "សញ្ញរកម្ម" ៥ គោលដៅផ្សេងគ្នា នៅក្នុងទឹកដីស្រុកសំរោងទង

http://www.cen.com.kh/archives/ May 12, 2019

កំពង់ស្ពឺ ៖ កំលាំងអធិការដ្ឋាននគបាលស្រុកសំរោងទង សហការជាមួយកា.រិ.ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចុះបង្ក្រាបទីតាំងម៉ាស្សាកោសជប់លួចបំរើសេវាផ្លូវភេទ"សញ្ញរកម្ម" ៥គោលដៅផ្សេងគ្នា នៅរសៀលថ្ងៃសៅរ៍ ទី១១ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង ១៥និង៣០ នាទី។

កិច្ចប្រតិបត្តិការខាងលើបានការដឹកនាំនិងសម្របសម្រួលពីលោក អ៊ូ ផាត ព្រះរាជអាជ្ញា អយ្យការ អមសាលាដំបូងខេត្តកំពង់ស្ពឺ លោកស្រីឧត្តមសេនីយ៍ត្រី ងិន សុគន្ធា ស្នងការរង ទទួលយេនឌ័រសហការជាមួយកំលាំងគណៈឯកភាពស្រុកសំរោងទង និងអាជ្ញាធរ ភូមិឃុំ យុទ្ធនាការចុះធ្វើការឆែកឆេរទីតាំងម៉ាស្សា កោសជប់ចំនួន ០៥ គោលដៅ រកឃើញភាពមិនប្រក្រតី ក្នុងការប្រកបមុខរបរខាងលើនិងបានឃាត់ខ្លួនមនុស្សចំនួន ១៥នាក់ ស្រីទីតាំងទាំងអស់ស្ថិតនៅភូមិអូរក្រាំងអំបិល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

តាមការបញ្ជាក់ពីជំនាញ លោកស្រីឧត្តមសេនីយ៍ត្រី ងិន សុគន្ធា ស្នងការរង ទទួលយេនឌ័របានឲ្យ ដឹងថា ការចុះបង្ក្រាបទីតាំងបើកផ្តល់ការប្រព្រឹត្ត"សញ្ញរកម្ម"គឺទទួលបានពាក្យបណ្តឹងពីពលរដ្ឋល្អដែលបានប្តឹងថាទីតាំងខាងលើគឺកំពុងតែប្រកបមុខរបរជ្រែកក្រោមស្លាក ម៉ាស្សាកោសជប់ ប៉ុន្តែជាតុពិតគឺបំរើផ្លូវភេទផ្ទុយនិងច្បាប់ ដាក់ស្តែងកំលាំងចុះសហការស្រាវជ្រាវ ជាលទ្ធផល ទីតាំងទី០១ យីហោ ៩១៩ មាននារីជាអ្នកបំរើសេវាផ្លូវភេទ ម៉ាស្សាកោសជប់ ៥ នាក់ មាន ២បន្ទប់ ឈ្មោះ ផន សម្ផស្ស ភេទស្រី អាយុ ៣៣ឆ្នាំ (ម្ចាស់ហាង) ទីតាំងទី០២ យីហោ ៩៩ មាននារី ២ នាក់ (មាន ៣បន្ទប់)ឈ្មោះ អៀង សារឹម ភេទស្រី អាយុ២៧ឆ្នាំ(ម្ចាស់ហាង) ទីតាំងទី០៣ យីហោ តារារះ មាននារី ៥នាក់ (មាន៣បន្ទប់) ឈ្មោះ គី ស្រីល័ក្ខ ភេទស្រី អាយុ៣៨ឆ្នាំ(ម្ចាស់ហាង) ទីតាំងទី០៤ យីហោ ១៦៧ មាននារី ៣ នាក់(មាន២បន្ទប់)ឈ្មោះ ចិន រុំ ភេទស្រី អាយុ២៨ឆ្នាំ(ម្ចាស់ហាង) ទីតាំងទី០៥ យីហោ ៧៧៧ វិមានសុខ មានម្ចាស់ហាង(ប្តីប្រពន្ធ)គ្មាននារីនោះទេ ។ វត្ថុតាងរួមមានស្រោមអនាម័យ ជាច្រើនប្រអប់(មិនទាន់ប្រើការនិងប្រេ្រីរួចដែលទុកក្នុងធុងសំរាមជាច្រើន) កែវជប់ជាច្រើនឡ ប្រេងរំអិល ចំនួន ១៣ កញ្ចប់។

បច្ចុប្បន្នម្ចាស់ទីតាំងជាថៅកែហាង និងក្រុមនារីៗប្រកបមុខរបរកោសជប់ បំរើសេវាផ្លូវភេទទាំង១៥ នាក់ត្រូវបាន បញ្ជូនទៅការិយាល័យប្រឆាំងការជួញដូរនឹងការពារអនីតិជនខេត្តកំពង់ស្ពឺ ដើម្បីធ្វើការសាកសួរ កសាងសំណុំរឿង ចាត់ការតាមនីតិវិធីច្បាប់៕ ដោយ ៖ កូឡាប

## ពិធីរៀបការរវាងកូនក្រមុំខ្មែរនិងកូនកម្លោះជនបរទេសត្រូវបានសមត្ថកិច្ចបញ្ឈប់

http://khmeread.com/ May 11, 2019 11:57AM

កំពង់ស្ពឺ ៖ ពិធីរៀបមង្គលការរវាងនារីខ្មែរនិងបុរសជនបរទេស មួយត្រូវបានអាជ្ញាធរ ឃុំពោធិ៍អង្រ្កង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ធ្វើកិច្ចសន្យាបញ្ឈប់មិនឱ្យរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១៩ វេលាម៉ោង២រសៀល នៅចំណុចភូមិឃុំខាងលើ ដោយសារធ្វើខុសពីនីតិវិធីច្បាប់នៃព្រះរាជាណាកម្ពុជា។ សមត្ថកិច្ចនិយាយថា ជនបរទេសឈ្មោះ GOH HOCK LKE អាយុ៥១ឆ្នាំ សញ្ជាតិម៉ាឡេស៊ី មុខរបរប្រធានក្រុមហ៊ុនជួសជុលឡានឡារីតា (Laryta) ទីកន្លែងស្នាក់នៅផ្ទះលេខ៤១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាន់តែលិខិតឆ្លងដែនលេខ A5076 8244 ផុតកំណត់នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០២៣ និងទិដ្ឋាការប្រភេទ Aលេខ E0187 63191

សមត្ថកិច្ចនិយាយបន្តថា នៅក្នុងកិច្ចសន្យាបញ្ឈប់មិនឱ្យរៀបការទី១-បញ្ឈប់សកម្មភាពរៀបអាពាហ៍ពិពាហ៍ដោយគ្មានច្បាប់អនុញ្ញាតជាមួយឈ្មោះ សឹម សារឿន ភេទស្រី អាយុ២៧ឆ្នាំ ស្នាក់នៅភូមិពោធិ៍ធំ ឃុំពោធិ៍អង្ក្រង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ដោយយោងតាមមាត្រា ៤-៥-៦ នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិស្តីពីអន្តោប្រវេសន៍។

ទី២-បើចង់រៀបអាពាហ៍ពិពាហ៍ត្រូវអនុញ្ញាតតាមច្បាប់មាត្រាទី៦ នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិស្តីពីអន្តោប្រវេសន៍ដូចខាងក្រោម៖ -ពាក្យសុំរៀបអាពាហ៍ពិពាហ៍ឯកសារថតចម្លងលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេស, មានទិដ្ឋាការចូលប្រទេសកម្ពុជាដែលនៅមានសុពលភាព, លិខិតបញ្ជាក់ភាពនៅលីវឬពោះម៉ាយឬមេម៉ាយចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស, លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា, លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា, លិខិតបញ្ជាក់ពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេសដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសទាំងពីរ, មានឯកសារឬលិខិតឆ្លងដែននិងលិខិតបញ្ជាក់ទីលំនៅពោះម៉ាយឬម៉េម៉ាយត្រូវបានបញ្ជាក់ នីត្យានុកូលដ្ឋានពីស្ថានទូតឬស្ថានតំណាងនៃប្រទេសសាមីខ្លួនជនបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា។

ទី ៣-ត្រូវបញ្ឈប់ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងបរទេសចាប់ពីថ្ងៃទី ១០ខែឧសភាឆ្នាំ២០១៩ វេលាម៉ោង ២និង៣០នាទីរសៀលនេះតទៅនិងទី ៤-ក្នុងករណីមិនគោរពតាមកិច្ចសន្យាខាងលើសមត្ថកិច្ច បានត្រូវអនុវត្តតាមច្បាប់អន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០២នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI **May 14 at 10:48 PM**

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៧ និង៣០នាទី ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ពីភាគីថៃចំនួន០២នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ជីវិតពលករខ្មែរមួយក្រុមធ្វើការនៅលើទូកនេសាទថៃជិត២០ឆ្នាំ

https://www.rfa.org/khmer/news/ ដោយ ជី វិតា 2019-05-15

យោងតាមទិន្នន័យក្រៅផ្លូវការ ពលករខ្មែរធ្វើការនៅគ្រប់វិស័យ នៅប្រទេសថៃមានជិតលាននាក់។ ពួកគេចាកចេញឆ្ងាយពីគ្រួសារជាទីស្រឡាញ់របស់ខ្លួនដោយសាររកការងារនៅក្នុងស្រុកធ្វើមិនបាន ខ្លះទៀតថែមទាំងមានជំពាក់បំណុលគេ និងខ្លះទៀតត្រូវគេរឹបអូសយកដីស្រែ មិនអាចមានមុខរបរចិញ្ចឹមជីវិតបាន។

ពលករខ្មែរមួយក្រុមមានគ្នាចំនួន៦នាក់ ធ្វើការនៅលើទូកនេសាទថៃមួយ ខំប្រឹងធ្វើការមិនហ៊ានឈប់សម្រាក ដែលអ្នកខ្លះធ្វើជិត២០ឆ្នាំហើយ ដើម្បីរកប្រាក់ចិញ្ចឹមគ្រួសារ និងដោះបំណុល ក្នុងនោះមានពលករម្នាក់មានប្រពន្ធពោះធំជិតដល់ថ្ងៃសម្រាលកូនផង។ សម្បុរស្រអែម រាងស្គម តែមាំ ឈរនៅលើទូកនេសាទដែលកំពុងបញ្ឆេះម៉ាស៊ីន ដៃម្ខាងកាន់មួក ឯដៃម្ខាងទៀតធ្វើកាយវិការ ពលករឈ្មោះ ចាន់ សុផល រៀបរាប់ប្រាប់អាស៊ីសេរីថា លោកមានស្រុកកំណើតនៅខេត្តព្រៃវែង ហើយបានចាកចេញពីផ្ទះទៅធ្វើជាកម្មករនៅលើទូកនេសាទថៃប្រមាណ២០ឆ្នាំហើយ។ លោកថា បន្ទាប់ពីរកការងារធ្វើមិនបាននៅកម្ពុជា ក៏សម្រេចចិត្តប្រថុយផ្សងព្រេងទៅរកការងារធ្វើនៅប្រទេសជិតខាងនេះ ហើយយូរៗម្តងទើបបានទៅលេងក្រុមគ្រួសារនៅឯស្រុកកំណើត ព្រោះត្រូវខិតខំធ្វើការសន្សំលុយដែលរហូតមកដល់ពេលនេះ លោកបានសងបំណុលគេរួចហើយ។ ពលករវ័យ៤០ឆ្នាំប្លាយរូបនេះ បន្តថា បើមានការងារធ្វើនៅកម្ពុជា លោកមិនចាកចេញពីភូមិកំណើតទេ៖ «ខ្ញុំគ្មានដើមទុនរកស៊ីក៏ចងការលុយគេមករកស៊ីនៅឯថៃនេះ ហើយដោះគេរួច ហើយក៏នៅជាប់តែនឹងថៃនេះ បានជាប់ប្រពន្ធថៃនេះ។ ឱ្យតែមានការងារនៅខ្មែរ ដែលអាចធ្វើឱ្យមានជីវភាពរស់នៅ

គ្រប់គ្រាន់មិនចាំបាច់មកធ្វើការនៅថៃទេ»។ កាលពីថ្ងៃទី១០ ខែឧសភា ពលករខ្មែរទាំង៦នាក់នោះបានរៀបចំសម្ភារៈឡើងទូក រួមមានអង្ករ ប្រេងម៉ាស៊ូត ប៊ីដុងសម្រាប់ដាក់ក្លាសសេត្រីរាប់រយប៊ីដុង និងឧបករណ៍ជាច្រើនផ្សេងទៀតនៅលើទូកដែលចតនៅច្រាំងសមុទ្រ ក្នុងតំបន់បាងយ៉ាផេក ស្រុកមឿង ខេត្តសមុទ្រសាខន (Samutsakorn)ដើម្បីត្រៀមចេញដំណើរទៅសមុទ្រជាប់ប្រទេសម៉ាឡេស៊ី។ ទូកនេសាទដែលពលករខ្មែរមួយក្រុមនេះធ្វើការ មិនមែនជាទូកសម្រាប់ចាប់ត្រីផ្ទាល់ពីសមុទ្រនោះទេ ប៉ុន្តែជាទូកសម្រាប់ប្រមូលទិញផលនេសាទពីទូកនេសាទផ្សេងទៀត។

លោក ចាន់ សុផល រៀបរាប់ថា ទូករបស់លោកត្រូវចំណាយពេលធ្វើដំណើរជាច្រើនថ្ងៃទើបដល់គោលដៅ ហើយត្រូវដេករង់ចាំទូកនាំទិន្នផលនេសាទមកប្រគល់ឱ្យជាច្រើនថ្ងៃទៀត។ សម្ភារៈដែលពួកគេជញ្ជូនដាក់លើទូកដែលមានចំណុះរាប់សិបតោន និងមានកម្ពស់២ជាន់នោះ គឺមួយចំនួនសម្រាប់ប្រើប្រាស់ក្នុងពេលធ្វើដំណើរ និងមួយចំនួនទៀតជាបញ្ញើរបស់អ្នកនេសាទនៅដែនសមុទ្រប្រទេសម៉ាឡេស៊ី។ លោកថា ជើងនេះទូកនេសាទរបស់ពួកគេត្រូវចេញដំណើរនៅថ្ងៃទី១២ ខែឧសភា ហើយចំណាយពេលប្រមាណ១ខែ ទើបត្រឡប់មកដល់ដីគោកនៅខេត្តសាមុទ្រសាខនវិញ៖ «ធ្វើទៅឱ្យគេនៅលើទូកឯណោះខ្លះ ខ្លួនឯងខ្លះព្រោះអីគេផ្ដាំទិញធ្វើទៅឱ្យគេ។ ទៅច្រើនថ្ងៃចង់មួយខែ។ ធ្វើនៅទីនេះគ្មានអ្វីដែលសំខាន់ទេ គ្រាន់ដើរស្ទានត្រីយកដាក់ក្នុងហាង (បន្ទប់) ហើយដល់ពេញអស់យើងដាក់ទឹកកករួចបិទរួចហើយក៏ត្រឡប់មកវិញ ហើយប្រហែល៧ថ្ងៃនេះគឺ យើងមានធ្វើអីទេ គឺយើងសម្រាករហូតនៅលើទូកពេលមកដល់ប្រទេសថៃ ក៏ចាប់ផ្ដើមធ្វើការមួយថ្ងៃតាំងពីព្រឹករហូតយប់តែម្ដង»។ ពលកររូបនេះ មានប្រពន្ធជាជនជាតិថៃ និងបានរស់នៅជាមួយគ្នាជិត១០ឆ្នាំហើយ ប៉ុន្តែមិនទាន់មានកូនទុកជាចំណងដៃនៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយចុះ លោកនៅតែចង់ធ្វើការរស់នៅនៅប្រទេសថៃជាមួយប្រពន្ធដោយមិនចង់ត្រឡប់ទៅស្រុកកំណើតវិញទេ ព្រោះគ្មានការងារធ្វើ ។

ចំណែកពលករម្នាក់ទៀត គឺលោក ជា ខន ប្រាប់អាស៊ីសេរីថា លោកធ្វើការនៅលើទូកនេសាទថៃជិត២០ឆ្នាំហើយដែរ គឺតាំងតែពីលោកមានអាយុ១៦ឆ្នាំ មកទល់សព្វថ្ងៃលោកអាយុ៣៥ឆ្នាំហើយ។ ជាពលករលើទូកនេសាទថៃមកពីខេត្តកំពង់ធំ លោក ជា ខន និយាយថា លោករកប្រាក់មិនទាន់គ្រប់គ្រាន់សម្រាប់យកទៅធ្វើដើមទុននៅស្រុកកំណើតនៅឡើយទេ។ ទោះជាយ៉ាងណា ដោយការខិតខំធ្វើការមិនខ្លាចនឿយហត់ និងការសន្សំសំចៃក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ លោកអាចមានលទ្ធភាពរៀបអាពាហ៍ពិពាហ៍ និងសង់ផ្ទះបានមួយខ្នង៖ «តាំងពីខ្ញុំចុះទូកមកខ្ញុំទៅផ្ទះវិញខ្ញុំបានប្រាក់ធ្វើផ្ទះហើយការប្រពន្ធរួចបាននាំប្រពន្ធមករកស៊ីនៅថៃវិញ ហើយថ្មីៗនេះខ្ញុំទៅផ្ទះទិញដីទុកសម្រាប់ឱ្យកូនខ្ញុំបាន១ប្លង់ ២ប្លង់ដែរព្រោះដីស្រែដីអីរបស់ខ្ញុំគេយកអស់ហើយ គេថាយកចែកឱ្យអ្នកក្រីក្រ។ គេឈូសឆាយដីរបស់ខ្ញុំអស់ មិនមានធ្វើស្រែធ្វើអីនឹងគេឯណាកើត អ៊ីចឹងក៏រត់ទៅធ្វើការនៅថៃ»។ លោក ជា ខន ប្រាប់ថា ការចុះទូកជើងនេះលោកមិនបានចុះទៅជាមួយពលករដទៃទេ ព្រោះត្រូវនៅមើលថែទាំប្រពន្ធពោះធំជិតដល់ថ្ងៃសម្រាលកូនហើយ។ ពលករសម្បុរខ្មៅរាងក្រអាញរូបនេះបន្តថា កន្លងទៅនៅពេលចុះទូកម្ដងៗ លោកតែងព្រួយបារម្ភខ្លាំងព្រោះទុកប្រពន្ធមានផ្ទៃពោះនៅបន្ទប់ជួលក្នុងខេត្តសាមុទ្រសាខន ម្នាក់ឯង ព្រោះត្រូវធ្វើដំណើរជាច្រើនសប្ដាហ៍នៅលើផ្ទៃសមុទ្រ ដែលមិនអាចយកប្រពន្ធទៅជាមួយបាន៖ «ចេញទូកទៅបែកគ្នា ១ខែ ឬ១ខែជាងទើបជួបគ្នាម្ដង។ ជួបគ្នាបាន១អាទិត្យ ឬ១អាទិត្យជាង ក៏ចេញទៅបែកគ្នាសាថ្មីទៀត។ ពេលធ្វើការម្ដងៗនឹករលឹកដល់ការរស់នៅជាមួយប្រពន្ធកូន ប៉ុន្តែធ្វើម៉េច បើដោយសារតែភាពក្រីក្រហើយ។ ទូកគឺចុះរហូតទៅដល់ច្រាំងប្រទេសម៉ាឡេស៊ីណាបង»។ ទោះជាយ៉ាងណា ពលកររូបនេះបន្តថា ពួកគាត់សំណាងណាស់ដែលបានថៅកែជនជាតិថៃមិនធ្វើបាបពលករខ្មែរដូចនៅកន្លែងផ្សេងៗទេ ។ ការប្រឈមខ្លាំងរបស់ពួកគាត់ គឺលំបាកត្រង់ធ្វើការនៅឆ្ងាយពីគ្រួសារ។ លោកថា នឹងខំធ្វើការសន្សំប្រាក់មួយរយៈទៀតដើម្បីធ្វើដើមទុន ហើយនាំប្រពន្ធកូនត្រឡប់ទៅរស់នៅស្រុកកំណើតវិញ ព្រោះធ្វើការនៅក្នុងប្រទេសថៃហត់នឿយខ្លាំង មិនមានសេរីភាពពេញលេញ និងខ្វះភាពកក់ក្ដៅពីបងប្អូនញាតិសន្ដាននៅស្រុកខ្មែរទៀតផង។

មន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកកប្រទេសថៃ លោក ចាន់ វិសាល ប្រាប់អាស៊ីសេរីថា កន្លងមកខាងស្ថានទូតបានជួយពលករខ្មែរធ្វើការនៅលើទូកនេសាទថៃជាច្រើនករណីដែលរងគ្រោះ ប៉ុន្តែលោកមិនបានបញ្ជាក់មានករណីបែបណាខ្លះដែលពួកគេជួបប្រទះនោះទេ៖ «សាច់រឿងវាមានជាករណីៗបង អីចឹងទាល់តែខ្ញុំទៅមើលតើសាច់រឿងវាយ៉ាងមិចខ្លះ ធម្មតាយើងដោះស្រាយមានទាំងអស់នឹងបងណាស់»។

ប្រធានមូលនិធិបណ្ដាញលើកកម្ពស់គុណភាពជីវិតពលករហៅកាត់ (LPN) ប្រចាំនៅខេត្តសាមុទ្រសាខន ប្រទេសថៃ លោក សំផុង ស្រះកែវ (Sompong Srakaew) មានប្រសាសន៍ថា កន្លងទៅអង្គការរបស់លោកក៏ធ្លាប់បានសហការជាមួយស្ថានទូតខ្មែរនៅប្រទេសថៃ ដើម្បីជួយដោះស្រាយបញ្ហារបស់ពលករខ្មែរមួយចំនួនដែរ។ លោកថា ពលករខ្មែរភាគច្រើនជួបប្រទះបញ្ហា ថៅកែរំលោភសិទ្ធិការងារ មិនបើកប្រាក់ខែឱ្យ បង្ខំឱ្យធ្វើការងារលើសម៉ោង បញ្ហាលិខិតឆ្លងដែន ឬបញ្ហាក្រដាសស្នាម ជាដើម។ ប៉ុន្តែលោក សំផុង ស្រះកែវ ប្រាប់អាស៊ីសេរីតាមរយៈអ្នកបកប្រែថា ពលករខ្មែរជាទូទៅ មិនហ៊ានប្ដឹងទៅសមត្ថកិច្ចថៃ ឬទៅរកអង្គការសង្គមស៊ីវិល ដើម្បីឱ្យជួយរកយុត្តិធម៌ដល់ពួកគេនោះទេ ព្រោះខ្លាចបាត់បង់ការងារធ្វើ ខ្លាចមានបញ្ហាដល់ខ្លួន ដូច្នេះច្រើនរត់ចោលបញ្ហា ដូចជាត្រឡប់ទៅផ្ទះវិញជាដើម៖ «នេះជាបញ្ហាមួយដែលធ្វើឱ្យបងប្អូនយើងគឺមិនទទួលបានយុត្តិធម៌សម្រាប់ខ្លួនឯង អីចឹងគាត់មកធ្វើការខាតទាំងពេលវេលាខាតទាំងកម្លាំងហើយ ខាតទាំងថវិកា ចុងក្រោយគាត់មានបំណុលនៅស្រុកខ្មែរធ្វើការអត់បានកម្រៃហើយទៅវិញដៃទទេ បំណុលនៅដដែល នេះជាបញ្ហាមួយសម្រាប់ពលករខ្មែរ។ ហើយមួយទៀតពួកគាត់ភាគច្រើនអត់ដឹងថា មានអង្គការចាំជួយពួកគាត់ ហើយជាទូទៅអង្គការដែលធ្វើការសម្រាប់ជួយពលករខ្មែរនៅថៃក៏មានតិចទៅទៀត»។ លោកបញ្ជាក់ថា ប្រសិនបើពលករខ្មែរណាម្នាក់ដែលធ្វើការនៅប្រទេសថៃ ត្រូវបានថៅកែ ឬជនណាធ្វើបាបដូចជារងការរំលោភបំពានសិទ្ធិការងារ ការជួញដូរផ្លូវភេទ ឬការកេងប្រវ័ញ្ចតាមប្រការណាមួយ ពួកគេមានសិទ្ធិអាចសុំជំនួយផ្នែកច្បាប់ពីអង្គការមូលនិធិបណ្ដាញលើកកម្ពស់គុណភាពជីវិតពលករ ហៅកាត់អេលភីអេន (LPN) របស់លោក តាមរយៈលេខទូរស័ព្ទ ០៨៧ ៧៧ ០៧ ៥១៧ , ០៨៩ ៤២ ២៤ ២១៣ និង០៨៦ ១៦ ៣១ ៣៩០។

ទិន្នន័យរបស់រដ្ឋាភិបាលថៃបង្ហាញថា ពលករចំណាកស្រុក កម្ពុជា ឡាវ និងភូមា ដែលបានចុះឈ្មោះរួចរាល់គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៧ មានចំនួនជិត ២លាននាក់ (១,៧២៦,៤១៥) ក្នុងនោះពលករជិត៥ម៉ឺននាក់ (៥០.០០០) ចុះឈ្មោះធ្វើការក្នុងឧស្សាហកម្មនេសាទ។

ទោះយ៉ាងណា ក្រុមពលករខ្មែរទាំង៥នាក់នឹងត្រឡប់មកច្រាំងសមុទ្រនៅខេត្តសមុទ្រសាខន ជាប់ទីក្រុងបាងកក ប្រទេសថៃវិញ នៅក្នុងខែមិថុនា គឺបន្ទាប់ពីប្រមូលទិញផលនេសាទបានគ្រប់ចំនួននៅកណ្ដាលសមុទ្រជាប់ដែនទឹកប្រទេសម៉ាឡេស៊ី។ ប៉ុន្តែពួកគេធ្វើការមិនហ៊ានឈប់សម្រាកទេ ព្រោះប្រសិនបើសម្រាកមិនបានប្រាក់ឈ្នួលឡើយ ដូច្នេះនៅពេលទូកទៅដល់ដីគោកប្រមាណ៧ថ្ងៃ ពួកគេនឹងចេញទៅដឹកទិន្នផលនេសាទនៅកណ្ដាលសមុទ្រជាបន្តបន្ទាប់ទៀត។ ចំណែកពលករ ជា ខន ដែលមិនបានចុះទូកជើងនេះដោយសារតែប្រពន្ធជិតសម្រាលកូននោះ រំពឹងថានឹងក្លាយជាឪពុកគេនៅក្នុងខែឧសភានេះ៕

## ថៃចាប់ពលករខ្មែរ៨០នាក់ ដែលឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់

http://www.arey-news.com/archives/ (ថ្ងៃទី 15 May 2019 ម៉ោង 3:15 pm)

**ថៃ ៖** ទាហានថៃពទ្ធ័ចាប់ពលករខ្មែរ៨០នាក់ ដែលឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់ ចំណែកមេខ្យល់រត់គេចខ្លួន កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩នេះ ។ នេះបើយោងតាមការចុះផ្សាយ តាមគេហទំព័រក្នុងស្រុមរបស់ថៃ(ខាវ សុទ្ធ)កងពលទាហានទី១១ បន្ទាយសម្ដេចព្រះណាំង ក្លៅ ប្រគល់ភារកិច្ចឲ្យ កងរក្សាសន្តិសុខ របៀបរៀបរយ បើកប្រតិបត្តិការត្រួតពិនិត្យ នឹងចាប់ឃុំពលករ ដែលលបលួចចូលប្រទេសថៃ ដោយខុសច្បាប់ បន្ទាប់ពីមានមុខសញ្ញា

ពីអ្នកផ្តល់ព័ត៍មាន ថាៈ មានក្រុមពលករខ្មែរ ចូលមកស្នាក់អាស្រ័យ នៅកណ្តាលព្រៃល្បាស ខាងក្រោយបន្ទាប់ជួល លេខ៨ បន្ទប់របស់ស្ត្រីឈ្មោះ អារី ចាន់ថាវ៉ាន់ ផ្ទះលេខ227/1 ភូមិ4 ឃុំស្មេត តាយ ស្រុកបាងក្លា ខេត្តចះឆើងសៅ ។

កម្លាំងទាហាន សហការជាមួយកម្លាំងតម្រួតស្រុកបាង ក្លា មន្ត្រីស្រុកបាងក្លា នឹងអាជ្ញាធរមូលដ្ឋាន ចូលទៅត្រួតពិនិត្យឯកសារធ្វើដំណើរ របស់ពលករខាងលើ បើសិនពិនិត្យទៅឃើញថាខុសច្បាប់ ឲ្យចាប់ឃុំភ្លាមៗ។ ប៉ុន្តែនៅពេលសមត្ថកិច្ចទៅដល់ ក្រុមពលករដែលស្នាក់នៅ កណ្តាលព្រៃល្បះ ខាងក្រោយបន្ទប់ជួល តាមព័ត៍មានផ្តល់ឲ្យ ពលករទាំងនោះ នាំគ្នារត់បែកខ្ញែក ខ្លះទៅនេះ ខ្លះទៅនោះ ដែលសមត្ថកិច្ចត្រូវបំបែកកម្លាំងគ្នា ចេញតាមចាប់បានមកទាំងអស់ជិត៨០នាក់ មានទាំងប្រុសនឹងស្រី រួមទាំងក្មេងតូចទៀតផងៗចំណែកមេខ្យល់បន្ទាប់ពីប្រតិបត្តិការរបស់សមតថកិច្ចបានរត់គេចខ្លួនបាត់។

ក្រុមពលករខ្មែរដែលបានចាប់ខ្លួនរបស់សមត្ថកិច្ច បានសារភាពថា ពួកគេ ដែលចូលមកស្នាក់នៅនេះប្រាប់ថា កាលពីម៉ោង៣ទៀបភ្លឺ យប់កន្លងទៅ ដែលគ្រប់គ្នា ត្រូវមកស្នាក់នៅបរិវេណនេះ បន្ទាប់មកនឹងមានរថយន្តមកទទួលដើម្បីបន្តដំណើរទៅខេត្តផ្សេងៗ ដើម្បីរកការងារធ្វើ។

ចំពោះពលករជំហានដំបូង សមត្ថកិច្ចបានឃុំខ្លួនទាំងអស់និងបញ្ជូន ទៅសាលប្រជុំសាលាស្រុកបាង ក្លា ព្រមទាំងទាក់ទងទៅអង្គភាពពាក់ពន្ធ័ ចូលមកត្រួតពិនិត្យលម្អិតម្តងទៀត ក្រោយពីពិនិត្យជំហ៊ានដំបូង ភាគច្រើនពលកលបលួចឆ្លងដែនតាមរយៈមេខ្យចូលមកដោយខុសច្បាប់ ។

បញ្ហាពលករខ្មែរខាងលើដែលសមត្ថកិច្ចថៃចាប់ខ្លួនក្រុមអ្នកព័ត៏មានយើងមិនទាន់មានការបកស្រាយពីមន្ត្រីកម្ពុជាប្រចាំប្រទេថៃឡើយ ៕

---

## អាជ្ញាធរថៃបញ្ជូនជនក្លែងខ្លួនជាសង្ឃចំនួន៣នាក់មកកម្ពុជា

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៩ ម៉ោង ១០:២៩ យឹម ប៊ុនណាក់

ខេត្តឧត្តរមានជ័យ ៖ តាមសេចក្តីរាយការណ៍បឋមបានឱ្យដឹងថា កាលពីវេលាម៉ោង៦យប់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩ អាជ្ញាធរថៃបានបញ្ជូនជនក្លែងខ្លួនជាសង្ឃចំនួន៣នាក់មកកម្ពុជាវិញតាមច្រកអន្តរជាតិជាំ ដែលប៉ូលិសថៃចាប់ខ្លួននៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩ នៅខេត្តស៊ីសាកេត ពីបទឆ្លងដែនខុសច្បាប់ ចូលតាមច្រកទ្វារអន្តរជាតិអូរស្មាច់កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៩ ។ ជនក្លែងខ្លួនជាសង្ឃទាំង៣នាក់ខាងលើរួមមាន ១-ឈ្មោះ ទត រឿន ភេទប្រុស អាយុ៣៨ឆ្នាំ រស់ភូមិម្សាគ្រង ឃុំម្សាគ្រង ស្រុកស្ទោង ខេត្តកំពង់ធំ ២-ឈ្មោះ ប៉ក់ គេន ភេទប្រុស អាយុ ៣០ ឆ្នាំ រស់នៅភូមិឃុំជាមួយគ្នា និង៣-ឈ្មោះ សេង សុវណ្ណរិទ្ធី ភេទប្រុស អាយុ១៩ឆ្នាំ រស់នៅភូមិឃុំជាមួយគ្នា ។ បច្ចុប្បន្នជនក្លែងខ្លួនជាសង្ឃទាំង៣នាក់ត្រូវបានអាជ្ញាធរធ្វើការអប់រំឲ្យត្រឡប់ទៅកាន់លំនៅដ្ឋានវិញហើយ ។ ព័ត៌មានលម្អិតនឹងមានផ្សាយនៅលើទំព័រកាសែតកោះសន្តិភាព ៕

## ជីវិតពលករស្រុកគេ! អ្នកបម្រើស្រីម្នាក់ ត្រូវម្ចាស់ផ្ទះចាប់ចងផ្អោបនឹងដើមឈើ ទុកជាការព្រមាន ក្រោយខឹងនឹងរៀងទុកដាក់គ្រឿងសង្ហារឹមមិនត្រឹមត្រូវ!

https://www.khmerload.com/news/ 10:14 May 15, 2019

អារ៉ាប៊ី សាអូឌីតៈ អ្នកបម្រើស្រីជាពលករចំណាកស្រុកជនជាតិហ្វីលីពីនម្នាក់ ធ្វើការនៅឯប្រទេសអារ៉ាប៊ីសាអូឌីត (Saudi Arabia) បានរងការឈឺចាប់ផ្លូវចិត្តយ៉ាងខ្លាំង ក្រោយត្រូវម្ចាស់ផ្ទះជាអ្នកមានទ្រព្យ ធ្វើទារុណកម្មដោយចាប់ចងផ្អោបនឹងដើមឈើ ព្រោះតែខឹងនឹងនាងរៀងទុកដាក់គ្រឿងសង្ហារឹមមិនបានត្រឹមត្រូវ។

បើយោងតាមប្រភពសារព័ត៌មាន បានឲ្យដឹងថា នារីរងគ្រោះជាអ្នកបម្រើខាងលើនេះ ត្រូវបានគេស្គាល់ឈ្មោះថា នាង Lovely Acosta Baruelo មានអាយុ ២៦ឆ្នាំ ជាជនជាតិហ្វីលីពីន ដែលបានមកបម្រើការងារផ្ទះឲ្យគ្រួសារស្តុកស្តម្ភមួយ ក្នុងរដ្ឋធានីរីយ៉ាដ (Riyadh) ប្រទេសអារ៉ាប៊ីសាអូឌីត ដោយអស់រយៈពេលជាច្រើនខែមកហើយ។ ប៉ុន្តែជារឿងមួយដែលមិននឹកស្មានដល់នោះ កាលថ្ងៃទី៩ ឧសភា ឆ្នាំ២០១៩ កន្លងទៅនេះ នាងបានធ្វើការងារផ្ទះដូចសព្វដង ហើយក៏ពុំមានចេតនានៅក្នុងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិណាមួយ ពោលគឺនាងបានយកគ្រឿងសង្ហារឹម (ដូចជា តុ ទូ សាឡុង ជាដើម) ដែលមានតម្លៃថ្លៃ អូសចេញមកដាក់ខាងក្រៅផ្ទះ (រៀបចំ និងសម្អាត) ដែលធ្វើឲ្យរងនឹងកំដៅថ្ងៃខ្លាំង ជាហេតុងាយនឹងធ្វើឲ្យខូច។ ដោយសារតែបែបនេះហើយ ទើបបានជាធ្វើឲ្យម្ចាស់ផ្ទះខឹងសម្បាយ៉ាងខ្លាំង រហូតដល់ថ្នាក់ចាប់ចងនាងផ្អោបនឹងដើមឈើ ដើម្បីជាការព្រមានតែម្តង។

យ៉ាងណាមិញ ក្រោយឃើញសភាពដ៏ឃោរឃៅបែបនេះ មិត្តភក្តិជាជនជាតិហ្វីលីពីនដូចគ្នា ដែលធ្វើការជាមួយគ្នានៅផ្ទះនោះ ក៏បានលួចថតរូបភាពរបស់ Baruelo យកទៅបង្ហោះចែកចាយលើបណ្តាញសង្គមដើម្បីសុំជំនួយ។ ហើយគេក៏បានអះអាងដែរថា ម្ចាស់ផ្ទះនោះតែងតែធ្វើបាបកូនចៅ ឬអ្នកបម្រើខ្លួន មិនថាឡើយរាល់ពេលដែលពួកគេធ្វើការងារខុសតិចតួចក្តី។ ប្រភពដដែលបន្តថា ជាសំណាងល្អ ដែលភ្លាមៗនៃដំណឹងមួយនេះ ត្រូវបានសាយភាយ និងរហូតត្រូវបានខាងក្រសួងការបរទេសហ្វីលីពីន (The Philippines Department of Foreign Affaires ឬ "DFA") សហការជាមួយនឹងស្ថានទូតហ្វីលីពីន ប្រចាំនៅអារ៉ាប៊ីសាអូឌីត បានធ្វើការស៊ើបអង្កេត និងជួយជ្រោមជ្រែងរហូតបានបញ្ជូននារីរងគ្រោះខាងលើនេះ មកកាន់ប្រទេសហ្វីលីពីនវិញដោយសុវត្ថិភាពផងដែរ។

អ្នកនាំពាក្យខាងក្រសួងការបរទេសហ្វីលីពីន បានឲ្យដឹងថា ដោយមិនបង្អស់យូរ ពោលគឺនៅក្នុងថ្ងៃកើតហេតុដដែលនោះ (ថ្ងៃទី៩ ឧសភា) Baruelo នាងក៏ត្រូវបានជួយសង្គ្រោះ និងបញ្ជូនត្រលប់ទៅមាតុប្រទេសវិញ ដោយមកដល់ទីក្រុងម៉ានីល នៅម៉ោង ៨និង៥៥នាទីយប់ (ម៉ោងនៅក្នុងតំបន់) ក្រោយរកឃើញថា នាងពិតជាបានរងទារុណកម្មពីសំណាក់និយោជកមែន (ម្ចាស់ផ្ទះ)។

ជុំវិញនឹងករណីខាងលើនេះ ក្រោយទទួលបានការជួយសង្គ្រោះ នាង Baruelo ក៏បានថ្លែងទៅកាន់អ្នកកាសែតថា៖ «ខ្ញុំពិតជាអរគុណខ្លាំងណាស់ ដែលបានជួយសង្គ្រោះរូបខ្ញុំ។ ប៉ុន្តែខ្ញុំក៏ចង់ស្នើសុំឲ្យមានការជួយសង្គ្រោះ ដល់ជនជាតិហ្វីលីពីនជាច្រើនផ្សេងទៀត ឲ្យចេញពីទីនោះផងដែរ។ ព្រោះថាពួកគេជាមនុស្សតែម្នាក់គត់ ដែលបានជួយខ្ញុំថតរូបខ្ញុំយកទៅបង្ហោះ។ ខ្ញុំពិតជាព្រួយបារម្ភពីសុវត្ថិភាពពួកគេនៅទីនោះណាស់។ ខ្ញុំសង្ឃឹមថាពួកគេក៏នឹងត្រូវបានជួយសង្គ្រោះឲ្យត្រលប់មកវិញ ដូចជាខ្ញុំផងដែរទៅចុះ» ។

គួរឲ្យដឹងផងដែរថា បើយោងតាមរបាយការណ៍ ត្រូវបានគេប៉ាន់ប្រមាណបានថា ជនជាតិហ្វីលីពីនប្រមាណ ២,៣លាននាក់ បានចេញទៅធ្វើការនៅឯប្រទេសមជ្ឈឹមបូព៌ា និងនៅតំបន់អាហ្វ្រិក។ ក្នុងចំណោមនោះ មានស្ត្រីជាពាក់កណ្តាលឯណោះ។ ក៏មានពាក្យបណ្តឹងជាច្រើន ដែលត្រូវបានគេរាយការណ៍ថា ពួកគេត្រូវបានរងការធ្វើបាបពីសំណាក់និយោជករបស់ពួកគេផងដែរ៕

## ពលរដ្ឋ ភូមា ចំនួន២៧នាក់ ដាច់បាយ ៥ថ្ងៃ បន្ទាប់ពីចំណាកស្រុកខុសច្បាប់ចូលទៅស្វែងរកការងារធ្វើនៅបរទេស

https://www.facebook.com Prak Pheak Tra 11-05-2019

យោងតាមរបាយការណ៍ពីសមត្ថកិច្ចថៃបានអោយដឹងថា នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៩ កម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ សហការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងខេត្តសង់ក្លា ប្រទេសថៃចុះធ្វើការល្បាតព័ទ្ធព្រៃក្រោយទីតាំងវាយកូនហ្គោលមួយកន្លែងនៅក្នុងខេត្តសង់ក្លា បានរកឃើញពលករចំណាកស្រុកខុសច្បាប់ សញ្ជាតិភូមា សរុបចំនួន២៧នាក់ គណៈពេលកំពុងលាក់ខ្លួនក្នុងព្រៃក្រោយទីតាំងវាយកូហ្គោល ។ តាមការបញ្ជាក់ពីសមត្ថកិច្ច ពលរដ្ឋភូមាទាំងអស់

រស់នៅខេត្តយ៉ាងកុង ប្រទេសភូមា បានចំណាកស្រុកខុសច្បាប់ចូលប្រទេសថៃ ដើម្បីបន្តដំណើរទៅធ្វើការនៅឯប្រទេសទីបី ប៉ុន្តែត្រូវមេខ្យល់យកលាក់ទុកនៅទីតាំងលើ ។

## ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩
## អង្គការមួយនៅថៃជួយកុមារខ្មែរឱ្យរួចផុតគ្រោះភ័យបន្ទាប់ពីឪពុកម្ដាយពួកគេចាញ់បោកថៅកែថៃ

https://www.rfa.org/khmer/ ដោយ សួន អមរា 2019-05-22

អង្គការមូលនិធិបណ្ដាញលើកកម្ពស់គុណភាពជីវិតពលករ ហៅកាត់ថា LPN ដែលមានទីស្នាក់ការនៅខេត្តសាមុទ្រសាខន (Samut Sakon) ប្រទេសថៃ បានជួយទំនុកបម្រុងផ្ដល់ការស្នាក់នៅនិងការសិក្សាដល់កុមារកម្ពុជាជាច្រើននាក់ឱ្យរួចផុតពីគ្រោះភ័យនានាដែលកើតមាននៅក្នុងប្រទេសថៃ។ការជួយជ្រោមជ្រែងនេះ ដោយសារតែឪពុកម្ដាយរបស់ពួកគេធ្វើជាពលករនៅប្រទេសថៃ ហើយចាញ់បោកថៅកែថៃបានត្រឡប់ទៅធ្វើលិខិតស្នាមនៅប្រទេសកំណើតវិញ ដើម្បីបានមកធ្វើការស្របច្បាប់ជាថ្មីទៀត។ តើមូលហេតុអ្វីបានជាកុមារទាំងនេះទៅរស់នៅជាមួយអង្គការក្នុងប្រទេសថៃដោយមិនបានចូលសាលារៀននៅស្រុកកំណើតដូចកូនអ្នកស្រុកដទៃដូច្នេះ?

កុមារទាំង៣នាក់មានអាយុចន្លោះពី ៧ ទៅ ១៣ឆ្នាំ និងមានស្រុកកំណើតនៅខេត្តសៀមរាប។ កាលពីព្រឹកថ្ងៃទី១០ឧសភាពួកគេអង្គុយជជែកគ្នា និងដណ្ដើមរបស់គ្នាលេងជាមួយកុមារមកពីប្រទេសដទៃទៀត ហាក់បីដូចមិនមានទុក្ខកង្វល់អ្វីកើតឡើងចំពោះពួកគេឡើយ ខណៈពួកគេរស់នៅជាមួយអង្គការមូលនិធិបណ្ដាញលើកកម្ពស់គុណភាពជីវិតពលករហៅកាត់(LPN)នៅខេត្តសាមុទ្រសាខន(Samutshakon)ជាប់ទីក្រុងបាងកកប្រទេសថៃ។

កុមារា ម្នាក់ មានសម្បុរស្រអែម មាឌរាងមាំ មានស្រុកកំណើតនៅខេត្តសៀមរាប។ កុមារម្នាក់នេះមានឈ្មោះហៅក្រៅថាសុផល បានរៀបរាប់ប្រាប់អាស៊ីសេរីដោយសំឡេងរណ្ដឺនៗ ថា រូបគេទៅប្រទេសថៃជាមួយម្ដាយតាំងតែអាយុ៩ឆ្នាំមក ដោយមិនបាននៅរៀនសូត្រក្នុងស្រុកកំណើតដូចកូនអ្នកស្រុកដែលមានជីវភាពធូរធារនោះទេ។ កុមារសុផលបន្តដោយទឹកមុខស្រពោនថា ដំបូងរស់នៅជាមួយម្ដាយធ្វើជាពលករធ្វើការខុសច្បាប់ស៊ីឈ្នួលដកដំឡូងនៅខេត្តឈុនបុរី (Chunbori) ប្រទេសថៃមួយរយៈ ដោយសារថៅកែមិនបើកប្រាក់ឈ្នួលឱ្យជាច្រើនខែ ក្រោយមកក៏បានប្ដូរទៅធ្វើកម្មករចៀរជ័រកៅស៊ូនៅខេត្តរ៉ាក់យ៉ង (Rakyorng) ភាគខាងកើតទីក្រុងបាងកកវិញ។ កុមារសុផលបន្តទៀតថា នៅទីនោះថៅកែជនជាតិសន្យាថានឹងជួយធ្វើលិខិតស្នាមដើម្បីបានសិទ្ធិជាពលករស្របច្បាប់ឱ្យ ប៉ុន្តែដល់ពេលម្ដាយរបស់ខ្លួនខំប្រឹងធ្វើការអស់ជាច្រើនខែ ថៅកែបានប្រែក្រឡាស់ដោយមិនធ្វើលិខិតស្នាមឱ្យឡើយ ហើយបានប្រាប់ម្ដាយរបស់ខ្លួនថាចង់ទៅណាក៏ទៅៗ ស្រេចតែចិត្ត។ ក្រោយមកម្ដាយសុផលក៏បានប្ដូរទៅធ្វើការក្នុងរោងចក្រដូងប្រេងមួយកន្លែងនៅខេត្តរាជបុរី (Ratchabori) នៅខាងត្បូងទីក្រុងបាងកកវិញ ប៉ុន្តែធ្វើការនៅទីនេះក៏ត្រូវថៅកែធ្វើបាបទៀត ដោយម្ដាយធ្វើការអស់ជាច្រើនខែថៅកែមិនព្រមបើកប្រាក់ខែអោយទេ ហើយថែមទាំងយកកាំភ្លើងទៅភ្ជង់ម្ដាយរបស់ខ្លួនទៀតផង៖ «មានគេប្រាប់ថាថៅកែនឹងមនុស្សល្អ ហើយធ្វើការបានលុយច្រើន តែពេលមកនៅហើយគេអត់អោយលុយ គេអោយបាន១ពាន់បាតចែកគ្នា៤គ្រួសារ ហើយគេធ្វើបាបបើមិនធ្វើការយកកាំភ្លើងទៅភ្ជង់ប្រាប់ថាបើមិនចេញពីបន្ទប់ទេគេបាញ់ ហើយគេអោយធ្វើដល់យប់ជ្រៅ។ហើយពេលយកឥវ៉ាន់ចេញទៅកន្លែងថ្មីគេថា ចាំដឹកឥវ៉ាន់អស់ហើយ ចាំអញអោយលុយ ដល់រួចហើយគេអត់អោយលុយទេ គេកុហក ហើយដល់ពេលនៅយូរៗ ទៅគេក៏កាន់តែធ្វើបាបខ្លាំងឡើងៗ»។

កុមារសុផលបន្តទៀតថា ប៉ុន្តែសំណាងល្អដោយសារកន្លែងធ្វើការមានកម្មករជនជាតិថៃធ្វើការជាមួយដែរ ពួកគេក៏បានទៅប្ដឹងប៉ូលិស ក្រោយមកមន្ត្រីអង្គការមូលនិធិបណ្ដាញលើកកម្ពស់គុណភាពជីវិតពលករហៅកាត់(LPN)ក៏បានទៅជួយនាំម្ដាយនឹងរូបគេនិងប្អូនប្រុសរបស់សុផលទៅស្នាក់ក្នុងអង្គការមួយនេះរហូតមកទល់ថ្ងៃទី១០ខែឧសភា

គឺមានរយៈពេល៧ខែហើយ។កុមារសុផលថា ខ្លួននិងប្អូនប្រុសអាយុជាង៧ឆ្នាំ បានស្នាក់នៅជាមួយអង្គការនេះ ដោយបានរៀនសូត្រ ៣ ភាសា រួមមាន ភាសាថៃ អង់គ្លេស និង ភូមា ប៉ុន្តែមិនមានភាសាខ្មែរនោះទេ៖ «ខ្ញុំអត់ចិត្តដែលមិនបានទៅនៅផ្ទះខ្លួនឯងព្រោះមកធ្វើការហើយធ្វើអោយម៉ែឪលំបាករៀនអោយចេះដឹងអាងបានទៅធ្វើជួយរកប្រាក់ម៉ែខ្ញុំចិញ្ចឹមម៉ែចិញ្ចឹមគ្រួសារ។បើខ្ញុំមិនបានមករៀនទីនេះខ្ញុំអត់ចេះភាសាគេផ្សេងទេ យើងមកទីនេះយើងបានចេះច្រើនភាសា។ខ្ញុំចង់រកលុយអោយបានច្រើនដើម្បីត្រឡប់ទៅនៅផ្ទះស្រុកខ្មែរវិញ ព្រោះអីនៅផ្ទះខ្ញុំអត់មានអីស៊ីទេបាទហើយលុយក៏អត់មានដែរ ម៉ែខ្ញុំនិយាយថានៅថៃល្អជាង»។

នៅពេលអាស៊ីសេរីទៅសម្ភាសន៍គឺកុមារសុផលមិនបាននៅជាមួយឪពុកម្តាយនោះទេ ដោយពួកគេ២នាក់បងប្អូនរស់នៅជាមួយអង្គការ LPN ដោយសុផលប្រាប់ថា ម្តាយរបស់ខ្លួនបានចេញទៅធ្វើលិខិតឆ្លងនៅកម្ពុជាមិនទាន់ត្រឡប់មកវិញនៅឡើយ។រយៈពេល៧ខែខណៈស្នាក់នៅជាមួយអង្គការ ដោយកុមារសុផលរៀនរហូតចេះអានភាសា ថៃ អង់គ្លេស និងភាសាភូមា អាចធ្វើដំណើរតាមផ្លូវបាន ដោយមិនបាច់មានអ្នកបកប្រែនោះទេ។

ប្រធានផ្នែកកុមារនៃអង្គការមូលនិធិបណ្តាញលើកកម្ពស់គុណភាពជីវិតពលករ អ្នកស្រី ដាវ៉ាន់ ខាន់ថង (DAWAN KHONTONG) ផ្តល់សម្ភាសន៍ជាមួយអាស៊ីសេរីថា នៅក្នុងអង្គការរបស់អ្នកស្រីនៅខេត្តសាមុទ្រសាខន (Samut Sakon) មានកុមារខ្មែរចំនួន៣នាក់ ក្នុងនោះមានអាយុ១៣ឆ្នាំម្នាក់និង២នាក់ទៀតអាយុក្រោម ១០ឆ្នាំ ដែលម្តាយរបស់ពួកគេត្រូវបានថៅកែថៃបង្ខំឱ្យធ្វើការច្រើនម៉ោង ដោយមិនបើកប្រាក់ខែជូនពួកគាត់។ អ្នកស្រីបន្តតាមរយៈអ្នកបកប្រែថា តាមពិតសុផលនិងប្អូនប្រុសបានចូលរៀនសាលារដ្ឋនៅក្នុងប្រទេសហើយ ប៉ុន្តែដោយសារពួកគេនៅឆ្ងាយពីសាលារៀនដែលបានចុះឈ្មោះ ដោយក៏ខាងអង្គការរបស់អ្នកស្រីជួយផ្តល់កន្លែងស្នាក់នៅ សំលៀកបំពាក់ អាហារហូបចុក និងការអប់រំ បណ្តោះអាសន្នមុននឹងបញ្ជូនពួកគេទៅចូលរៀនក្នុងសាលារដ្ឋវិញ។អ្នកស្រីបន្តថា ក្រោយពីផ្តល់សម្ភារៈឱ្យពួកគេរស់នៅក្នុងមជ្ឈមណ្ឌលហើយ ខាងអង្គការផ្តល់ការអប់រំអោយពួកគេចេះរស់នៅរួមគ្នា ព្រោះនៅក្នុងមជ្ឈមណ្ឌលមួយនេះ មានកុមារចម្រុះជាតិសាស្ត្ររស់នៅ ដូច្នេះហើយត្រូវធ្វើយ៉ាងណាបង្រៀនពួកគាត់អោយចេះរស់នៅជុំគ្នាដោយសន្តិវិធីនិងមិនមានជម្លោះកើតឡើង៖ «ដោយសារកន្លែងដែលពួកគេរស់នៅធ្វើការវាឆ្ងាយពីអង្គការដូច្នេះយើងបានអនុញ្ញាតអោយគាត់រស់នៅក្នុងខេត្តសាមុទ្រសាខននឹង ដោយខាងអង្គការខ្ញុំបានទៅធ្វើលិខិតផ្ទេរពីសាលាខេត្តរាជបុរីអោយមករៀននៅខេត្តសមុទ្រសាខនវិញ ដើម្បីងាយស្រួលគាត់ចូលសិក្សាធម្មតា។សម្រាប់ទំនាក់ទំនងរវាងគាត់នឹងគ្រួសារគឺគាត់នៅមានទំនាក់ទំនងល្អដូចធម្មតា ដោយម្តាយរបស់ពួកគាត់បានទាក់ទងមកតាមហ្វេសប៊ុកញឹកញាប់»។

អ្នកស្រីបន្តថា ខាងអង្គការទទួលទំនុកបម្រុងកុមារទាំងនេះមួយរយៈទៀតរហូតដល់អាណាព្យាបាលរបស់ពួកគេត្រឡប់មកពីធ្វើលិខិតឆ្លងដែននៅឯស្រុកកំណើត ដើម្បីមកធ្វើការស្របច្បាប់វិញនៅប្រទេសថៃ ព្រោះម្តាយរបស់ពួកគេបានប្រាប់មកខាងអង្គការអ្នកស្រីថា ពួកគេនឹងត្រឡប់មកធ្វើការវិញក្នុងពេលឆាប់ៗ ហើយខាងអង្គការនឹងបន្តជួយតាមដានការរស់នៅដើម្បីជួយដល់ពួកគេទៀតប្រសិនបើមានបញ្ហាកើតឡើង៖ «មុននឹងបញ្ជូនទៅយើងនឹងសិក្សាវាយតម្លៃជាមុនសិនថាទីកន្លែងដែលបញ្ជូនទៅនោះមានសាលារៀនអត់ ដោយគោលបំណងរបស់អង្គការគឺចង់អោយកុមារបានរៀនសូត្របន្ត ហើយខាងអង្គការក៏នៅតែមានការជួយទំនុកបម្រុងសម្ភារៈសិក្សាដូចជាសំលៀកបំពាក់ និងសម្ភារៈផ្សេងក៏យើងនៅតែជួយពួកគាត់ដដែល ដោយគោលបំណងចង់កុមារទទួលបានសិទ្ធិការថែទាំរបស់កុមារតាមច្បាប់»។ អ្នកស្រីបន្ថែមទៀតថា ពលករមួយក្រុមនេះមានគ្នាជិត២០នាក់ ក្នុងនោះមានមនុស្សពេញវ័យចំនួន៨នាក់ និងមានកុមារ៨នាក់ ប៉ុន្តែកុមារមួយចំនួនធំបានទៅស្រុកកំណើតជាមួយអាណាព្យាបាលអស់ហើយ ដោយសារពួកគេនៅតូចមិនអាចរស់នៅក្នុងមជ្ឈមណ្ឌលបានដូចកុមារទាំង៣នាក់។

អង្គការមួយនេះមានទីតាំង៣កន្លែង គឺនៅខេត្តរ៉ាក់យ៉ង(Rakyorng) ត្រាត(Trat) និងខេត្តសាមុទ្រសាខន (Samutsakon) សម្រាប់ជួយលើកកម្ពស់ជីវិតរស់នៅរបស់កុមារកម្ពុជា លាវ និង ភូមា។របាយការណ៍របស់អង្គការ

មូលនិធិបណ្តាញលើកកម្ពស់គុណភាពជីវិតពលករ(LPN) អោយដឹងថា យ៉ាងហោចណាស់មានកុមារខ្មែរប្រមាណ ១០០នាក់ក្នុងមួយឆ្នាំ ដែលបានទៅរស់នៅតាមឪពុកម្តាយធ្វើការងារនៅប្រទេសថៃដែលជួបបញ្ហាផ្សេងៗក្នុងពេលបំពេញការងារ ដែលបានអង្គការមួយនេះជួយផ្តល់ការសិក្សាដល់ពួកគេនោះ។

ទោះបីជាយ៉ាងណាកុមារសុផលថ្លែងថា រូបគេនឹងមិនត្រូវត្រឡប់ទៅស្រុកខ្មែរវិញទេ ប្រសិនបើឪពុកម្តាយរបស់ខ្លួនមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ធ្វើដើមទុនប្រកបមុខរបរនៅស្រុកកំណើតនោះ ព្រោះនៅផ្ទះគ្មានការងារធ្វើនោះទេ ហើយម្យ៉ាងទៀតម្តាយពួកគេបានខ្ចីប្រាក់គេទាំងដើមទាំងការសរុបជាង១០ម៉ឺនបាត(១០០,០០០)ឬស្មើជាង៣ពាន់ដុល្លារហើយ មិនទាន់រកប្រាក់សងគេរួចនៅឡើយទេ ព្រោះធ្វើការកន្លងមកត្រូវបានថៅកែបោកគ្រប់កន្លែងដោយសារឪពុកម្តាយមិនមានឯកសារធ្វើការងារស្របច្បាប់៕

## សមត្ថកិច្ចបញ្ជូនជនបរទេសម្នាក់ ទៅតុលាការ ពាក់ព័ន្ធនឹងករណីរំលោភសេពសន្ថវៈលើអនីតិជន

http://nokorwatnews.com/ 22-05-2019

ខេត្តសៀមរាប៖ ទើបតែបែកធ្លាយរឿងនៅរសៀលថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងការហួសចិត្តមួយ ចេះតែធ្វល់ម៉េចបានជាជនជាតិបរទេសចូលចិត្ត ហៅកូនស្រីទាំង២ ទៅបន្ទប់គាត់ម្ល៉េះ ដល់ពេលសួរដេញដោលកូនស្រី ទើបដឹងរឿង។ ហេតុការណ៍ដ៏គួរឲ្យភ្ញាក់ផ្អើលមួយបានកើតឡើង ខណៈដែលសមត្ថកិច្ចបានឃាត់ខ្លួនបានជនបរទេសម្នាក់ភ្លាមៗ ក្រោយពីទទួលពាក្យបណ្តឹង ពីម្តាយក្មេងស្រីរងគ្រោះ ចោទប្រកាន់បុរសរូបនេះ ចាប់រំលោភលើកូនស្រីរបស់គាត់២នាក់ ដែលហេតុការណ៍ នៃការឃាត់ខ្លួននេះ បានធ្វើឡើងកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩ នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប ។

យោងតាមការឲ្យដឹងពីខាងសមត្ថកិច្ចបានបញ្ជាក់ឲ្យដឹងថា ជនសង្ស័យឈ្មោភកាមដែលត្រូវបានឃាត់ខ្លួននោះ មានឈ្មោះ CLINE RUGH JAMES ភេទប្រុស កើតថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩០ ជនជាតិសហរដ្ឋអាមេរិក កាន់លិខិតឆ្លងដែន លេខ490634082 ។ ចំណែកក្មេងស្រីរងគ្រោះទាំង២នាក់ អាយុ ១២ឆ្នាំ និង អាយុ១៤ឆ្នាំ ។

ម្តាយក្មេងស្រីរងគ្រោះនិយាយថា មុនពេលកើតហេតុ ជនសង្ស័យបានជួបកូនស្រីរបស់គាត់ នៅតំបន់ផាប់ស្ទ្រីត បន្ទាប់មក ជនសង្ស័យរូបនេះ បាននាំកូនស្រីរបសគាត់ទៅកន្លែងដែលគេរស់នៅ ហើយបានឲ្យកូនស្រីរបស់គាត់លេងប្រដាប់ភេទ រហូតចេញទឹកកាម រួចឲ្យលុយ១២០ដុល្លារ ចែកគ្នា២នាក់ ។ ទង្វើរបស់ជនសង្ស័យរូបនេះ បានធ្វើមកលើកូនស្រីរបស់គាត់ចំនួន៣ដងមកហើយ ។ ម្តាយក្មេងស្រីរងគ្រោះបានបន្តថា ដោយសារទ្រាំនឹងទង្វើជនសង្ស័យរូបនេះមិនបាន ទើបនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩ គាត់បានទៅដាក់ពាក្យបណ្តឹងនៅនាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ដើម្បីចុះអន្តរាគមន៍ ។ ក្រោយពីទទួលបានពាក្យបណ្តឹង លោកវរសេនីយ៍ឯក ជា ហេង នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានសសេររបាយការណ៍ជាលាយល័ក្ខអក្សរទៅលោកព្រះរាជអាជ្ញា ដើម្បីកោះហៅជនបរទេសមកសាកសួរ ។

នៅចំពោះមុខសមត្ថកិច្ច ជនសង្ស័យរូបនេះ បានបដិសេធថា គ្រាន់តែបានស្គាល់ក្មេងស្រីទាំង២ និង ធ្លាប់ឲ្យលុយចាយតែប៉ុណ្ណោះ ។ ក្រោយពីសាកសួរចប់ លោកកើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាប អនុញ្ញាតឲ្យឃាត់ខ្លួនជនសង្ស័យនៅវេលាម៉ោង១៦និង៣០នាទី នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១៩ តែបច្ចុប្បន្ន ក៏ស្ថិតនៅកន្លែងតុលាការដដែលមិនទាន់បញ្ជូនទៅណានៅឡើយ ៕ ប៊ុនរិទ្ធី

# ធ្លាប់រងការកេងប្រវ័ញ្ចញើសឈាមនៅថៃ អ្នកស្រី ទុំ ពៅ ខាកមកចិញ្ចឹមមាន់ ដាំបន្លែដើម្បីចិញ្ចឹមម្តាយវ័យ៨០ឆ្នាំវិញ

https://thmeythmey.com/ 22, May 2019 , 9:59 pm ដោយ: ថ្មីៗ

សៀមរាបៈ អ្នកស្រី ទុំ ពៅ បានវិលត្រឡប់មកស្រុកកំណើតដាំបន្លែ និងចិញ្ចឹមមាន់ វិញ បន្ទាប់ពីស៊ីឈ្នួលដាំដំឡូង និងសណ្តែកសៀងនៅប្រទេសថៃ អស់រយៈពេល៥ឆ្នាំ។ អ្នកស្រី ទុំ ពៅ ជាស្ត្រីមេម៉ាយ និងជាកសិករដាំបន្លែសុវត្ថិភាព-ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ដើម្បីចិញ្ចឹមម្តាយដែលមានអាយុជាង៨០ឆ្នាំ និងកូន១នាក់ រួមទាំងក្មួយកំពុងសិក្សា៤នាក់ទៀត ។ បើតាមស្ត្រីមេម៉ាយរូបនេះ របរដាំបន្លែ និងចិញ្ចឹមសត្វ បានធ្វើឲ្យអ្នកស្រីរួចផុតពីបំណុលគេ និងធ្វើឱ្យជីវភាពគ្រួសារធូរធារ មានមុខមាត់នៅក្នុងសង្គម។ រយៈពេលជាង១០ឆ្នាំហើយ ដែលអ្នកស្រី ទុំ ពៅ បានប្រកបរបរដាំបន្លែ និងចិញ្ចឹមមាន់ នៅក្នុងភូមិប្រវ៉ាល ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប។ ការត្រឡប់មកប្រកបរបរកសិកម្មលើទឹកដីកំណើតខ្លួនជាថ្មីនេះ គឺកើតឡើងក្រោយភាពឈឺចាប់ ដែលអ្នកស្រី ទុំ ពៅ បានជួបការមើលងាយ និងរងការកេងប្រវ័ញ្ចប្រាក់ការងារពីជនជាតិខ្មែរគ្នាឯង នៅក្នុងទឹកដីប្រទេសថៃ កាលពីអំឡុងឆ្នាំ២០០៥។

ក្រោយចាកចេញពីទឹកដីថៃ មករស់នៅកម្ពុជាវិញនោះ អ្នកស្រី ពៅ បានសម្លឹងឃើញរបរកសិកម្ម ដែលជាក្តីសង្ឃឹមរបស់ខ្លួន ក្នុងការចិញ្ចឹមជីវិត រួមទាំងម្តាយចាស់ជរា និងកូនក្មួយ៥នាក់ទៀតនៅក្នុងបន្ទុក។ សល់ប្រាក់បន្តិចបន្តួចពីការងារដាំដំឡូង និងសណ្តែកសៀងនៅប្រទេសថៃ អ្នកស្រី ពៅ ក៏សម្រេចយកប្រាក់ទាំងនោះ ទៅទិញពូជស្រូវពូជបន្លែ ដើម្បីដាំដុះនៅលើដីជុំវិញផ្ទះប្រហែលកន្លះហិកតា។ ប៉ុន្តែការធ្វើកសិកម្មគ្រានោះ មិនអាចជួយជីវភាពគ្រួសារអ្នកស្រី ទុំ ពៅ ឱ្យបានល្អប្រសើរទេ ព្រោះអ្នកស្រីគ្មានបច្ចេទេសដាំដុះ ដោយធ្វើស្រែ-ចម្ការអាស្រ័យផលទៅលើធម្មជាតិទាំងស្រុង ពោលគឺដាំច្រើន ប៉ុន្តែបានទទួលផលតិច។ ការដាំដុះគ្មានបច្ចេកទេស ហើយទទួលបានផលតិចនេះ បានធ្វើឲ្យអ្នកស្រី ទុំ ពៅ ជួបបញ្ហាជីវភាព ដោយបានអូសបន្លាយរហូតដល់ឆ្នាំ២០១១ ទើបអ្នកស្រី ទទួលបានការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់យកសាច់ ចិញ្ចឹមកូនមាន់ និងដាំបន្លែសុវត្ថិភាព ពីគម្រោងអភិវឌ្ឍកសិកម្មនិរន្តភាព សម្រាប់គ្រួសារកសិករក្រីក្រ របស់អង្គការGRET។ តាមរយៈការបណ្តុះបណ្តាលនោះ អ្នកស្រី ពៅ អាចដាំបន្លែចម្រុះមុខ ដូចជាក្រូចឆ្មារ ស្ពៃ ត្រប់ ដំឡូង ម្ទេសជាដើម ដោយទទួលផលបានច្រើនគ្រប់ខែ និងគ្រប់រដូវ រួមទាំងចិញ្ចឹមមាន់ ទទួលបានប្រាក់ចំណូលខ្ពស់ ក្រៅពីធ្វើស្រែចម្ការទៀតផង។ ស្ត្រីមេម៉ាយវ័យ៤៦ ឆ្នាំរូបនេះ បានសារព័ត៌មាន ThmeyThmey ដូច្នេះថា៖« ក្រៅពីចំណូលប្រចាំថ្ងៃ៤ទៅ៥ម៉ឺនរៀលពីបន្លែនៅជុំវិញផ្ទះ ខ្ញុំអាចលក់កូនមាន់បាន៣០ទៅ៤០ម៉ឺនរៀលក្នុងមួយខែៗ។ ប្រាក់ទាំងនេះ បានរ៉ាប់រងទាំងស្រុងលើការចំណាយរបស់កូនក្មួយរៀនសូត្រ, សង់ដោះបំណងគេ, ទិញថ្នាំពេទ្យ មើលជំងឺម្តាយ និងចំណាយផ្សេងៗទៀត ធ្វើឱ្យគ្រួសារ ខ្ញុំរស់នៅក្នុងជីវភាពមួយធូរធារ មានគេរាប់រកច្រើននៅក្នុងភូមិ-ស្រុក និងក្លាយជាកសិករគំរូក្នុងភូមិផងដែរ»។ បើតាមស្ត្រីមេម៉ាយរូបនេះ អ្នកស្រីអាចទទួលប្រាក់ចំណេញសុទ្ធពីមុខរបរកសិកម្មនេះ ពី៥ទៅ៦លានរៀល ក្នុងមួយឆ្នាំផងដែរ។ មែនទែនទៅ! ភាពល្អប្រសើរនៃជីវភាពគ្រួសាររបស់អ្នកស្រី ទុំ ពៅ បច្ចុប្បន្ន គឺផ្តើមចេញពីក្តីរងទុក្ខលំបាកនៅប្រទេសថៃ រយៈពេល៥ឆ្នាំ ដោយសារការកេងប្រវ័ញ្ចញើសឈាមការងារ។

មូលហេតុដែលអ្នកស្រី ពៅ ត្រូវរងការលំបាកនៅប្រទេសថៃគ្រានោះ ដោយសារតែជីវភាពគ្រួសាររបស់អ្នកស្រីជួបបញ្ហាបំណុលច្រើន បន្ទាប់ពីឪពុកបានទទួលមរណៈភាព ដោយសារជំងឺ។ ជំពាក់បំណុលគេជុំទិស រួមទាំងដីស្រែ-ចម្ការបញ្ចាំគេ ស្របពេលខ្លួនគ្មានការងារធ្វើ និងគ្មានប្រាក់ចំណូលប្រចាំថ្ងៃនោះ វាជាមូលហេតុដែលជំរុញឲ្យអ្នកស្រី ទុំ ពៅ ចំណាកស្រុកទៅស៊ីឈ្នួលគេនៅឯប្រទេសថៃ ដើម្បីដោះបំណុលគេអស់រយៈពេល៥ឆ្នាំ គឺចាប់ពីឆ្នាំ២០០០ដល់២០០៥។ មានសម្បុរខ្មៅស្រអែម សក់ព័ណ៌ក្រហម ស្ថិតក្នុងវ័យជាង៤០ឆ្នាំ ស្ត្រីមេម៉ាយរូបនេះ បានរៀបរាប់រឿងរ៉ាវអតីតកាលទាំងទឹកមុខស្រពោនដូច្នេះថា៖« បន្ទាប់ពីឪពុកខ្ញុំបានស្លាប់ គ្រួសារទាំងមូលបានជំពាក់ប្រាក់គេច្រើនបងៗ ក៏គ្មានលទ្ធភាពដោះស្រាយ។ ដូច្នេះខ្ញុំពីនាក់បងស្រីធំ បានសម្រេចចិត្តទៅស៊ីឈ្នួលនៅប្រទេសថៃ ដោយទុក

ម្ដាយនៅតែម្នាក់ឯង។ ទៅស៊ីឈ្នួលគេនៅថៃហ្នឹង ថ្ងៃខ្លះមានការងារធ្វើ...ថ្ងៃខ្លះទៀតក៏គ្មានអ្វីធ្វើ ព្រោះមេការមិនឱ្យខ្ញុំដាំ...គេឱ្យតែគ្នាគេដាំ។ ថ្ងៃណាខ្វះកម្លាំងដាំ បានមេកាខ្មែរហៅខ្ញុំទៅដាំជំឡូង។ ដាំហ្នឹងគេបាន១៥០ទៅ២០០បាត ខ្ញុំបានតែ៥០ទៅ៧០បាតប៉ុណ្ណោះ ក្នុងមួយថ្ងៃ។ ខ្ញុំគិតថាចំណូលតិចពេក ក៏ខ្ញុំសុំគេដាំគិតម៉ែត្រវិញ។ មួយថ្ងៃខ្ញុំប្រឹងដាំជំឡូងឱ្យបានមួយរ៉ៃ (ស្មើផ្ទៃដី៤០ម៉ែត្របួនជ្រុង) បានប្រាក់៣៥០បាត។ ខ្ញុំគិតថាប្រាក់នេះច្រើនណាស់សម្រាប់ខ្ញុំ ប៉ុន្តែដាក់ស្ដែងមួយរ៉ៃបាន៥០០បាត ដែលតម្លៃថៅកែថៃកំណត់ឱ្យកម្មករទូទៅ»។ ទោះបីដឹងថា កេងយកប្រាក់លើកម្លាំង ញើសឈាមរបស់ខ្លួនក៏ដោយ ក៏អ្នកស្រី ទុំ ពៅ នៅតែប្រឹងប្រែធ្វើការងារទាំងលំបាកផ្លូវចិត្ត នៅក្នុងទឹកដីប្រទេសថៃ រហូតដល់សងបំណុលគេរួច និងសន្សំប្រាក់បានមួយចំនួនត្រឡប់មកស្រុកកំណើត ដើម្បីធ្វើស្រែចម្ការរបស់ខ្លួនវិញ រហូតទទួលបានភាពប្រសើរនៃជីវិត នាពេលបច្ចុប្បន្ននេះ៕

## ប្ដីចិនចិត្តស្មោះ! មកពីស្រុកចិន តាមរកប្រពន្ធកូននៅស្រុកខ្មែរមិនឃើញ ប៉ុនប៉ងចង.ក សម្លាប់ខ្លួនឯង

https://kbn.news/archives/ May 22, 2019

**ខេត្តក្រចេះ ៖** បុរសជនជាតិចិនម្នាក់ ធ្វើដំណើរមកស្រុកខ្មែរ តាមមករកប្រពន្ធជាជនជាតិខ្មែរ និងកូនដល់ស្រុកកំណើតរបស់នាង តែរកមិនឃើញ ព្រោះនាងនាំកូនចេញទៅរកស៊ីនៅខេត្តឆ្ងាយបាត់ ទើបធ្វើឱ្យគាត់តូចចិត្ត និងបានទាញខ្សែគោ បម្រុងមកចង.កសម្លាប់ខ្លួនឯងតែម្ដង ។ ហេតុការណ៍នេះបានកើតឡើងកាលពីថ្ងៃទី២១ ឧសភា ឆ្នាំ២០១៩នេះ នៅផ្ទះឪពុកម្ដាយរបស់ប្រពន្ធ ក្នុងភូមិសណ្ដាន់ ឃុំសណ្ដាន់ ស្រុកសំបូរ។ បុរសជនជាតិចិននោះ ឈ្មោះ ផៃ ស៊ីហ្គាន់ អាយុ៤២ឆ្នាំ មានប្រពន្ធជាជនជាតិខ្មែរនិង មានកូនស្រីម្នាក់ ។ បុរសរូបនេះ ទើបធ្វើចំណើរមកដល់ប្រទេសខ្មែរកាលពីថ្ងៃទី២១ ឧសភា ឆ្នាំ២០១៩។ រីឯស្ត្រីជាប្រពន្ធ មិនបានស្គាល់ឈ្មោះទេ ព្រោះនាងបានចេញទៅធ្វើការ នៅក្រុងប៉ោយប៉ែតបាត់ហើយ។

កន្លងមក ស្រីជាប្រពន្ធខ្មែរនេះ បានចេញទៅរស់នៅប្រទេសចិន ហើយបានបុរសជនជាតិចិន ឈ្មោះ ផៃ ស៊ីហ្គាន់ ធ្វើជាប្ដី និងបានកូនស្រីម្នាក់ ។ លុះចុងក្រោយនេះ ប្រពន្ធបាននាំកូនស្រីមកស្រុកខ្មែរវិញ តែនាងមិនព្រមត្រឡប់ទៅប្រទេសចិនវិញ ទើបគាត់ធ្វើដំណើរមកស្រុកខ្មែរតាមមករកប្រពន្ធកូនដល់ស្រុកកំណើតបែបនេះ តែពេលមិនឃើញនាង ទើបធ្វើឱ្យគាត់តូចចិត្ត និងបានទាញខ្សែគោ បម្រុងមកចង.កសម្លាប់ខ្លួនឯងតែម្ដង តែត្រូវក្រុមគ្រួសារខាងប្រពន្ធមកជួយឃាត់ទាន់ ។ ក្រោយពេលកើតហេតុ កម្លាំងនគរបាលមូលដ្ឋានបានចុះទៅធ្វើការសម្របសម្រួល និងប្រាប់បុរសចិននោះថា ក្រុមគ្រួសារខាងប្រពន្ធនឹងជួយទៅតាមរកប្រពន្ធនិងកូនឱ្យមកជួបគាត់វិញ ៕

## ព្រោះតែជីវភាព! បុរសខ្មែរលួចចូលកាប់ឈើលើទឹកដីថៃ ត្រូវបានចាប់ធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ រហូតធ្លាក់ខ្លួនឈឺធ្ងន់ព្យាបាលទាំងដៃជើងនៅជាប់ច្រវាក់ដូចសត្វធាតុ

https://dara-news.com/archives/ ដោយ Mao Vibol May 21, 2019

ក្រោយរូបភាពប៉ុន្មានសន្លឹក និងវីដេអូឃ្លីបមួយត្រូវបានចែករំលែកនៅ លើបណ្ដាញ សង្គមពីមួយទៅមួយ បានធ្វើអោយមហាជនជាច្រើនផ្ទុះការចាប់អារម្មណ៍ ខណៈបុរសជនខ្មែរម្នាក់ត្រូវបានតម្រួតថៃធ្វើការចាប់ខ្លួនក្រោយធ្វើសកម្មភាពលួចចូលកាប់ឈើនៅលើទឹកដីថៃ។ បុរសជនជាតិខ្មែរដែលត្រូវតម្រួតថៃចាប់ខ្លួនមានឈ្មោះ សឿង សំអុន មានដើមកំណើតនៅភូមិសក្ការៈ ឃុំពោធិ៍ចំរើន ស្រុកបាសែត ខេត្តកំពង់ស្ពឺ ត្រូវតម្រួតថៃចាប់ខ្លួននិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងររហូតដល់ធ្លាក់ខ្លួនឈឺ ពេលនេះកំពុងតែសម្រាកព្យាបាលនៅមន្ទីរពេទ្យទាំងដៃជើងជាប់ច្រវាក់ដូចសត្វធាតុ។ នេះបើតាមប្រភពពីគណនីហ្វេសប៊ុកឈ្មោះ បងមិនអីទេ បានបង្ហោះនឹងរៀបរាប់យ៉ាងដូច្នេះថា «ដោយសារជីវភាពក្រីក្រ ខ្មែរហ៊ានប្ដូរជីវិត លួចចូលកាប់ឈើលើទឹកដីថៃ ឥឡូវត្រូវតម្រួតថៃចាប់បានដោយធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ

ហេតុធ្លាក់ខ្លួនឈឺធ្ងន់ នៅក្នុងគុក ទើបតម្រួតថៃបញ្ជូនមកព្យាបាលនៅក្រៅឃុំទាំងដៃជើងនៅជាប់ច្រវាក់ នេះគឺជាទិត្តភាពទាំងស្រុងត្រូវទទួលដោយទារុណកម្ម មកពីយើងចូលមកកាប់ឈើគ្រញូងនៅក្នុងទឹកដីគេដោយខុសច្បាប់»។

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០៥នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI May 22 at 10:48 PM

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៥និង៤០នាទី ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃ ចំនួន ០៥នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០៥នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI May 19 at 11:30 AM

ឧត្តរមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃ ចំនួន ០៥នាក់ ទៅកាប់ឈើនៅប្រទេសថៃដែលចេញតាមច្រកត្រពាំងបីស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០៤នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI May 17 at 6:59 PM

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៨និង០០នាទី ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃ ចំនួន ០៤នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ទូតខ្មែរនៅកូរ៉េ នឹងបន្តចុះផ្តល់សុពលភាព លិខិតឆ្លងដែន ដោយឥតគិតថ្លៃដល់ពលករ

https://www.dap-news.com/ ByID:114 Posted on 23 May 2019 | 13:48

ភ្នំពេញ៖ ដើម្បីចូលរួម កាត់បន្ថយការចំណាយ និងពេលវេលា ធ្វើដំណើររបស់ពលករខ្មែរ ធ្វើការនៅប្រទេសកូរ៉េខាងត្បូង ស្ថានទូតកម្ពុជាប្រចាំកូរ៉េ នឹងបន្តចុះផ្តល់សេវាសុពលភាព លើលិខិតឆ្លងដែន ដោយឥតគិតថ្លៃចំនួន៣តំបន់ ។ យោងតាម សេចក្តីប្រកាសព័ត៌មាន របស់ទូតកម្ពុជា នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ បានឲ្យដឹងថា ការធ្វើបែបនេះ ក៏ដូចជាឆ្លើយតបតាមសំណើ របស់សមាគមខ្មែរ សហគមន៍ខ្មែរ និងមជ្ឈមណ្ឌលគាំពារតាមតំបន់ ស្ថានឯកអគ្គរាជទូត បានរៀបចំកម្មវិធីផ្តល់សេវា បន្តសុពលភាពលិខិតឆ្លងដែន ដោយឥតគិតថ្លៃ នៅតំបន់ចំនួន៣រួមមាន៖

១/ ទីក្រុង ផ្សង់ថេក នៅថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០១៩ នៅមុខស្ថានីយរថភ្លើង ផ្សង់ថេក ចាប់ពីម៉ោង១៤-១៧ រសៀល។

២/ ទីក្រុងថេហ្គូ នៅថ្ងៃអាទិត្យ ទី២ ខែមិថុនា ឆ្នាំ២០១៩ នៅការិយាល័យអង្គភាព អភិវឌ្ឍន៍ធនធានមនុស្សកូរ៉េ ប្រចាំទីក្រុងថេហ្គូ ចាប់ពីម៉ោង១២-១៦ រសៀល។

៣/ ទីក្រុងក្វាងជូធំ នៅថ្ងៃអាទិត្យ ទី៩ ខែមិថុនា ឆ្នាំ២០១៩ នៅការិយាល័យ អង្គភាពអភិវឌ្ឍន៍ ធនធានមនុស្សកូរ៉េ ប្រចាំទីក្រុងក្វាងជូធំ ចាប់ពីម៉ោង ១២-១៦រសៀល៕ ដោយ៖ បាន ជារ៉ូ

## របាយការណ៍ ៖ ស្ត្រីកូរ៉េខាងជើងជាច្រើនត្រូវបានគេលក់ឲ្យធ្វើជាទាសករផ្លូវភេទ នៅចិន

http://www.cen.com.kh/archives/ May 22, 2019

ស្ត្រី និងក្មេងស្រីកូរ៉េខាងជើងរាប់ពាន់នាក់ ត្រូវបានគេជួញដូរ និងលក់ឲ្យធ្វើជាទាសករផ្លូវភេទ នៅក្នុងប្រទេសចិន ខណៈស្ត្រីជាច្រើនទៀតត្រូវគេលក់ឲ្យធ្វើជាប្រពន្ធរបស់បុរសចិន និងខ្លះទៀតត្រូវគេបង្ខំឲ្យធ្វើជាអ្នករកស៊ីផ្លូវភេទ ឬធ្វើការឡាយពីសកម្មភាពផ្លូវភេទ ដែលប្រឆាំងទៅនឹងឆន្ទៈរបស់ពួកគេ។ នេះបើតាមការអះអាងរបស់របាយការណ៍ថ្មីមួយ។ ការស៊ើបអង្កេតរបស់អង្គការចាប់ផ្តើមអនាគតកូរ៉េ (KFI) ក៏បានរៀបរាប់ពីរបាយការណ៍របស់ក្មេងស្រីជាច្រើន ដែលមានអាយុ ១២ឆ្នាំ ត្រូវបានគេចាប់រំលោភ និងស្ត្រីជាច្រើនទៀតត្រូវបានគេបង្ខំឲ្យចូលរួមសកម្មភាពរួមភេទតាមអនឡាយអស់ជាច្រើនថ្ងៃ ដោយមិនបានហូបអ្វីសោះ។

ជុំវិញរបាយការណ៍នេះដែរ ក្រសួងការបរទេសចិនមិនទាន់បានធ្វើការឆ្លើយតបភ្លាមៗនោះទេ ចំពោះការស្នើសុំធ្វើអត្ថាធិប្បាយរបស់ CNN គេមិនមានស្ថិតិផ្លូវការពីចំនួនពិតប្រាកដរបស់ប្រជាជនកូរ៉េខាងជើង ដែលបានចាកចេញពីប្រទេសនោះទេ។ ក្រុមជំនួយបានធ្វើការរាយការណ៍ថា មានប្រជាជនកូរ៉េខាងជើងរាប់ពាន់នាក់រស់នៅក្នុងប្រទេសចិន ជាជនភៀសខ្លួន។ នេះបើតាមការបញ្ជាក់របស់របាយការណ៍របស់ UN កាលពីឆ្នាំ ២០១៤។ អង្គការ KFI បានធ្វើការអះអាងថា ចំនួនអាចមានខ្ពស់រហូតដល់ ២០០.០០០នាក់។ អង្គការដដែលបានធ្វើការប្រមាណថា ស្ត្រីកូរ៉េខាងជើងចំនួន ៦០ភាគរយដែលរស់នៅប្រទេសចិនជាជនភៀសខ្លួន ត្រូវបានគេជួញដូរផ្លូវភេទ។

សូមបញ្ជាក់ថា KFI គឺជាអង្គការដែលធ្វើកិច្ចការផ្តោតសំខាន់ទៅលើស្ត្រី កុមារ និងអនិតិជនជនជាតិកូរ៉េខាងជើង ដែលជាជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស៕ អត្ថបទប្រែសម្រួលដោយ៖ សុភ័ក្រ ប្រភព៖ CNN

# ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរម្នាក់មកឲ្យកម្ពុជាវិញ ពីបទឆ្លងដែនខុសច្បាប់កាប់ឈើគ្រញូង

http://nokorwatnews.com/archives/ 24-05-2019

ខេត្តឧត្តរមានជ័យ ៖ អាជ្ញាធរថៃ បានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន១នាក់ តាមច្រកអន្តរជាតិជាំ មកប្រគល់ឲ្យកម្ពុជាវិញ កាលពីវេលាម៉ោង១៧ និង៣០នាទី ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ ស្ថិតនៅភូមិជាំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ប្រជាពលរដ្ឋខ្មែរខាងលើឈ្មោះ ភួត រិត ភេទប្រុស អាយុ៣២ឆ្នាំ រស់នៅភូមិ បឹងស្នួល ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប ។ ទាក់ទងរឿងខាងលើនោះដែរ ទាហានថៃ បានចាប់ខ្លួនពលរដ្ឋខ្មែរម្នាក់ កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ កន្លងទៅ ពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ ចូលតាមច្រកម៉ាឡៃ ជាប់គុក នៅស្រុក ខាន់ថាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ ។ បច្ចុប្បន្ន ពលរដ្ឋខ្មែរម្នាក់ ដែលអាជ្ញាធរថៃបញ្ជូនមកនោះ ត្រូវបានសមត្ថកិច្ចឲ្យវិលទៅលំនៅឋានវិញហើយ៕ ប៉ែន នួន

## តុលាការចោទបុរសអាមេរិកម្នាក់ពីបទប្រព្រឹត្តអំពើអាសប្រឆាំងអនីតិជន

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 23/05/2019

សៀមរាប ៖ តុលាការខេត្តសៀមរាបបានចោទបុរសទេសចរណ៍ជនជាតិអាមេរិកម្នាក់ឈ្មោះ Cline Rugh James ពីបទប្រព្រឹត្តិអំពើអាសប្រឆាំងអនីតិជន ហើយបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារ ។ ជនជាតិអាមេរិកកាំងម្នាក់នេះត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១៩ និងបានបញ្ជូនទៅ

តុលាការ ខណៈដែលសមត្ថកិច្ចអះអាងថា ជនបរទេសរូបនេះ បានប្រព្រឹត្តអំពើអនាចារលើអនីតិជនអាយុក្រោម ១៥ ឆ្នាំ ចំនួន ៤ នាក់។

លោក ជា ហេង ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តសៀមរាបក៏បានថ្លែងថា យោងតាមចម្លើយរបស់កុមារីរងគ្រោះ គឺជនជាតិអាមេរិករូបនេះ បានប្រព្រឹត្តបទល្មើសតាំងពីឆ្នាំ ២០១៨ នៅពេលរូបគេមកដើរទេសចរណ៍នៅកម្ពុជា។ លោកបន្តថា មានក្មេងស្រី ៤ នាក់ មានអាយុចាប់ពី ១២ ដល់ ១៤ ឆ្នាំ ដែលគាត់រំលោភបំពាន។ ទោសទណ្ឌ វាអាចជាប់ពី ១ ឆ្នាំទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀលទៅ ១០ លានរៀលផងដែរ ៕

## អ្នកជំនាញថាពលករខ្មែរធ្វើបានតែការងារពិបាក គខ្វក់និងគ្រោះថ្នាក់

https://khmer.voanews.com/ 24 ឧសភា 2019 ម៉ែន គឹមសេង

ទីផ្សារការងារដែលពលករចំណាកស្រុកខ្មែរអាចធ្វើបាននៅក្រៅប្រទេសគឺជាប្រភេទការងារពិបាក កខ្វក់ និងគ្រោះថ្នាក់ ហើយពួកគេមិនអាចធ្វើការងារបច្ចេកទេស ឬជំនាញដោយប្រើចំណេះដឹង ដែលបានសិក្សានៅកម្ពុជាបានឡើយ ដោយសារតែច្បាប់នៅប្រទេសសាមីមានការកំហិតច្បាស់លាស់។ នេះបើតាមការលើកឡើងរបស់សកម្មជនពលកម្ម។ លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) បានបញ្ជាក់ ក្នុងកម្មវិធីហេឡូវីអូអេ កាលពីថ្ងៃព្រហស្បតិ៍ថា ដោយឡែកនៅកម្ពុជាមិនទាន់មានការកំហិតប្រភេទការងារលើជនអន្តោប្រវេសន៍នៅឡើយទេដែលឱ្យពួកគេធ្វើការងារតាំងពីតូចតាចរហូតដល់ធំដុំបានដែលបានប៉ះពាល់ដល់ពលរដ្ឋកម្ពុជា។

## ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩

### អគ្គស្នងការនគរបាលជាតិចុះ MOU ជាមួយអង្គការសង្គ្រោះជោគវាសនា (DR)

http://cambodiapolice.com/policekh/ 4:14 pm 24 ឧសភា 2019

ភ្នំពេញ ៖ នៅព្រឹកថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា ជាមួយអង្គការសង្គ្រោះជោគវាសនា (DR) នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។ ពិធីនេះ មានការអញ្ជើញចូលរួមជាគណៈអធិបតីពី លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ , ប្រធាន អនុប្រធាននាយកដ្ឋាន និងលោក Todd Willim Morrison ប្រធានអង្គការសង្គ្រោះជោគវាសនា (DR) និងសហការីផងដែរ ។

តាមការឲ្យដឹងពី ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន មានប្រសាសន៍ ក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នានេះ ក្នុងគោលបំណងដើម្បីបង្កើនកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ ព្រមទាំងផ្តល់សេវាសង្គមដល់ជនរងគ្រោះ ។ ក្នុងគោលបំណងនៃ MOU នេះ បានផ្តល់ឱកាសឲ្យអង្គការ(DR) សហការជាមួយនគរបាលប្រឆាំងការជួញដូរមនុស្សដូចតទៅ ៖

១.នៅពេលដែលអង្គការ (DR) មានព័ត៌មាន ឬបណ្តឹងពីគ្រួសារ និងជនរងគ្រោះ (DR) នឹងត្រូវផ្តល់ព័ត៌មានមកនគរបាលប្រឆាំងការជួញដូរមនុស្សដើម្បីស៊ើបអង្កេតផ្ទៀងផ្ទាត់ព័ត៌មាននិងមានចំណាត់ការតាមនីតិវិធីនិងច្បាប់ ។

២.(DR) អាចផ្តល់ព័ត៌មានបន្ថែម ពីទីកន្លែងសង្ស័យប្រព្រឹត្តបទល្មើស និង ផ្តល់ភស្តុតាងផ្សេងៗទៀតមក នគរបាលប្រឆាំងការជួញដូរមនុស្ស។ (DR) ទទួលជនរងគ្រោះផ្តល់សេវាបឋម សេវាសង្គមបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តល់ទីកន្លែងសុវត្ថិភាពស្នាក់នៅសម្រាប់ជនរងគ្រោះ។

៣.(DR) បានបញ្ជាក់ថា មានមណ្ឌលផ្តល់សេវានិងគាំពារដល់ជនរងគ្រោះចំនួន៣កន្លែង ទីមួយនៅរាជធានីភ្នំពេញ ទី២នៅខេត្តសៀមរាប និងទី៣នៅខេត្តកំពង់ចាម ។ (DR) នឹងធ្វើកិច្ចសហការជាមួយនគរបាលប្រឆាំងការជួញដូរមនុស្ស ដោយគោរពទៅតាមអនុស្សារណៈនៃការយោគយល់គ្នា និងស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ជាធរមាន ៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ១០នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI May 25 at 4:31 PM

ឧត្តរមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩ បាន ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ១០នាក់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០១នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI May 24 at 5:05 PM

ឧត្តរមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ បាន ទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់ ទៅធ្វើការនៅប្រទេសថៃ តាមច្រកប៉ោយប៉ែត ខេត្ត បន្ទាយមានជ័យ៕

## ត្រូវបានអាជ្ញាធរថៃបញ្ជូនមកឲ្យកម្ពុជាវិញ ពីបទឆ្លងដែនខុសច្បាប់ចូលទៅរកទឹកឃ្មុំក្នុងដីថៃ

http://cambodiapolice.com/policekh/ 9:00 pm 24 ឧសភា 2019

ឧត្តរមានជ័យ៖ អាជ្ញាធរថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន១នាក់ទៀតហើយ មកឲ្យកម្ពុជាវិញ តាមច្រកអន្តរជាតិជាំ កាលពីវេលាម៉ោង១២និង២០នាទី ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ ស្ថិតនៅភូមិជាំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានឲ្យដឹងថា ប្រជាពលរដ្ឋខ្មែរម្នាក់ ដែលអាជ្ញាធរថៃបញ្ជូនមកឲ្យអាជ្ញាធរកម្ពុជាវិញនោះ មាន ឈ្មោះ មាំ សុខសាន្ត ភេទប្រុស អាយុ៣៥ឆ្នាំ រស់នៅភូមិប៉ុស្តិ៍ចាស់ ឃុំព្រះនេតព្រះ ស្រុកព្រះនេតព្រះ ខេត្តបន្ទាយមានជ័យ ត្រូវបានទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ដើររកទឹកឃ្មុំ ចូលតាមច្រកប៉ោយប៉ែត ជាប់គុកនៅខេត្តស៊ីសាកេត ប្រទេសថៃ។ នៅពេលបច្ចុប្បន្ន ប្រជាពលរដ្ឋខ្មែរម្នាក់ ដែលត្រូវអាជ្ញាធរបញ្ជូនមកនោះ ត្រូវបានសមត្ថកិច្ចឲ្យវិលទៅលំនៅដ្ឋានវិញហើយ៕

## ពលករនេសាទខ្មែរមួយក្រុមធ្លាប់ត្រូវថៅកែទូកចាស់អត់បើកប្រាក់ឈ្នួលអោយជាង១០ខែ

https://www.facebook.com/ Prak Pheak Tra 26-05-2019

មានពលករនេសាទខ្មែរមួយក្រុមធ្លាប់ត្រូវថៅកែទូកចាស់អត់បើកប្រាក់ឈ្នួលអោយជាង ១០ខែ សរុបជាទឹកប្រាក់ប្រមាណជាង ១លាន ២សែនបាត គាត់បានដាក់ពាក្យបណ្តឹងរហូតដល់ទទួលបានការដោះស្រាយ ដោយភាគីថៅកែ និងអជ្ញាធរពាក់ព័ន្ធក្នុងប្រទេសថៃ ដោយពួកគាត់ទទួលបានប្រាក់សំណងគ្រប់ៗគ្នា ។

ថ្ងៃនេះយើងបានជួបពួកគាត់ ពួកគាត់សប្បាយចិត្តរីករាយ ដែលយើងបានជួយពួកគាត់កន្លងទៅ យើងបានសាកសួរពួកគាត់ហេតុអ្វីពួកគាត់វិលមកចុះទូកម្តងទៀត? គាត់រៀបរាប់ប្រាប់យើងថា គាត់ត្រូវថៅកែចាស់ដដែលនេះបញ្ចុះបញ្ចូលអោយវិលត្រឡប់មកធ្វើការជាមួយម្តងទៀត ដោយសន្យានឹងបើកប្រាក់ខែរាល់ខែ លើកនេះពួកគាត់ធ្វើការអស់រយៈពេល២ខែជាង ថៅកែរូបនេះមិនព្រមបើកប្រាក់ខែអោយសោះ ចុងក្រោយពួកគាត់សម្រេចចិត្តដើរចេញពីថៅកែនោះទៅរកថៅកែថ្មី ដោយចោលប្រាក់ប្រាក់ខែទាំងនោះប្រមាណជាង២សែនបាត ពួកប្រាប់ថា គាត់មិនចង់ប្តឹងទៀតទេ ពីព្រោះរឿងនេះជាកំហុសរបស់រូបគាត់ ជឿជាក់លើថៅកែនោះខ្លាំងពេក គេបោកម្តងហើយនៅតែលង់ជឿរគេទៀត គាត់ខ្មាសអាជ្ញាធរពាក់ព័ន្ធដែលធ្លាប់ជួយពួកគាត់កន្លងទៅ ដែលបានណែនាំប្រាប់គាត់កុំលង់ជឿរថៅកែនេះទៀត ប៉ុន្តែគាត់នៅតែលង់ជឿរហូតដល់ធ្វើការអត់បានទទួលប្រាក់ដូច្នោះ។

# ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩

## ថៃស្នើកម្ពុជា ចូលរួមសហការ ទប់ស្កាត់ លើការជួញដូរមនុស្ស

https://www.dap-news.com/ ByID:112 Posted on 27 May 2019 | 14:09

ភ្នំពេញ ៖ គណៈប្រតិភូថៃ បានស្នើដល់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំង និងការជួញដូរមនុស្សកម្ពុជា ចូលរួមសហការលើចំណុចសំខាន់ៗមួយចំនួន ទាក់ទងនឹងការជួញដូរមនុស្ស។ នេះបើយោងតាមការចុះផ្សាយរបស់ក្រសួងមហាផ្ទៃ។

ក្នុងកិច្ចប្រជុំ រវាងភាគីពាក់ព័ន្ធកម្ពុជា-ថៃ ដើម្បីពង្រឹង កិច្ចសហការក្នុងការដោះស្រាយបញ្ហា ទេសន្តប្រវេសន៍ ក្រោមអធិបតីភាព លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង និងការជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា ស្ថានភាពពលរដ្ឋកម្ពុជាឆ្លងដែនចូលថៃ មានទាំងស្របច្បាប់ និងមិនស្របច្បាប់ ។ លោកស្រីថា ចំពោះការឆ្លងដែនដោយមិនស្របច្បាប់ ដោយសារពួកគាត់មានជីវភាពខ្វះខាត ហើយធ្វើការចំណាក់ស្រុកឆ្លងដែន ផ្សងព្រេងទាំងប្រថុយគ្រោះថ្នាក់ ដើម្បីចូលទៅស្វែងរកការងារធ្វើនៅថៃ។ រដ្ឋលេខាធិការឲ្យដឹងទៀតថា ចំនួនពលរដ្ឋកម្ពុជាចំណាកស្រុកចូលទៅថៃ គិតត្រឹមឆ្នាំ២០១៤មានចំនួន ១,៨៣០,០០ នាក់ ។ ដោយឡែកពីឆ្នាំ២០១៧ មកដល់បច្ចុប្បន្នកើនជាង១លាននាក់ ។ ក្នុងនោះស្របច្បាប់មាន៦០ភាគរយ និងមិនទាន់ស្របច្បាប់៧០ភាគរយ។ លោកស្រីបន្ថែមថា "ភាគីថៃក៏បានស្នើឲ្យគណៈកម្មការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សយើង ចូលរួមសហការលើចំនួនសំខាន់រួមមាន ៖ ការងារចំណាកស្រុកឆ្លងដែន និងអំពើជួញដូរមនុស្ស ការងារបណ្តុះបណ្តាលវិស័យអប់រំ និងវិស័យការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើយ៉ាងណាឲ្យមានភាពងាយស្រួលសម្រាប់យកទៅអនុវត្តបន្ត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងតំបន់ ផ្លាស់ប្តូរនូវព័ត៌មានថ្មីៗពីគ្នា ក៏ដូចជាការពង្រឹងស្ថាប័ននៃប្រទេសបញ្ជូន និងប្រទេសទទួលពលករផងដែរ"៕ ដោយៈធី លីថូ

## ពលករខ្មែរឆ្លងដែនទៅថៃមិនស្របច្បាប់មានជាង៧០ភាគរយ ខណៈពលករសរុបជាង១លាននាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៩ ម៉ោង ១៤:៥២ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃបានអះអាងពលករខ្មែរដែលលួចឆ្លងដែនទៅប្រទេសថៃដោយប្រថុយនឹងគ្រោះថ្នាក់ដោយសារពួកគាត់មានជីវភាពខ្វះខាតក្នុងនោះស្មើ៧០ភាគរយ ក្នុងចំណោមពលករសរុបជាង១លាននាក់ ។ ការលើកឡើងពីបញ្ហាឆ្លងដែនរបស់ពលករខ្មែរទៅថៃដោយខុសច្បាប់នេះត្រូវលើកឡើងក្នុងកិច្ច

ប្រជុំរវាងភាគីពាក់ព័ន្ធកម្ពុជាថៃ ដើម្បីពង្រឹងកិច្ចសហការក្នុងការដោះស្រាយបញ្ហាទេសន្តប្រវេសន៍ កាលនាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងមហាផ្ទៃ ។

លោកស្រីជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង និងការជួញដូរមនុស្ស (គ.ជ.ប.) បានលើកឡើងពីស្ថានភាពសិទ្ធសេរីភាពជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា និងអំពើជួញដូរមនុស្សនៅកម្ពុជាទៅដល់ភាគីថៃជាពិសេសការចំណាក់ស្រុកឆ្លងដែនរបស់ប្រជាពលរដ្ឋកម្ពុជាចូលទៅប្រទេសថៃនាពេលកន្លងមក និងបន្តដល់បច្ចុប្បន្នផងដែរ ។ លោកស្រីបានបញ្ជាក់ថា «ស្ថានភាពពលរដ្ឋកម្ពុជាឆ្លងដែនចូលក្នុងប្រទេសថៃមានទាំងស្របច្បាប់ និងមិនស្របច្បាប់ ហើយចំពោះការឆ្លងដែនដោយមិនស្របច្បាប់ គឺដោយសារពួកគាត់មានជីវភាពខ្វះខាត ហើយធ្វើការចំណាក់ស្រុកឆ្លងដែនផ្សងព្រេងទាំងប្រថុយគ្រោះថ្នាក់ ដើម្បីចូលទៅស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃ» ។ ជាមួយគ្នានោះដែរលោកស្រីក៏បានបន្ថែមថា ចំនួនពលរដ្ឋកម្ពុជាចំណាកស្រុកចូលទៅក្នុងប្រទេសថៃគិតត្រឹមឆ្នាំ២០១៤កន្លងទៅមានចំនួន ១,៨៣០,០០ នាក់ (មួយរយប៉ែតសិនបីពាន់នាក់) ។

ដោយឡែកពីឆ្នាំ២០១៧ មកដល់បច្ចុប្បន្នកើនចំនួនជាងមួយលាននាក់ ក្នុងនោះស្របច្បាប់មាន៦០ភាគរយ និងមិនទាន់ស្របច្បាប់៧០ភាគរយ ។ ក្នុងកិច្ចប្រជុំនោះដែរភាគីថៃបានថ្លែងការកោតសរសើរខ្ពស់ចំពោះកិច្ចសហការរបស់ភាគីកម្ពុជាកន្លងមក ហើយបានបន្តយកចិត្តទុកដាក់មកដល់បច្ចុប្បន្ន ។ ភាគីថៃក៏បានស្នើឲ្យភាគីកម្ពុជាចូលរួមសហការលើចំនួនសំខាន់ គឺការងារចំណាកស្រុកឆ្លងដែន និងអំពើជួញដូរមនុស្សការងារបណ្តុះបណ្តាលវិស័យអប់រំ និងវិស័យការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើយ៉ាងណាឲ្យមានភាពងាយស្រួលសម្រាប់យកទៅអនុវត្តបន្តក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងតំបន់ផ្លាស់ប្តូរនូវព័ត៌មានថ្មីៗពីគ្នាក៏ដូចជា ការពង្រឹងស្ថាប័ននៃប្រទេសបញ្ជូន និងប្រទេសទទួលពលករផងដែរ ។

សូមបញ្ជាក់ថា កិច្ចប្រជុំពង្រឹងកិច្ចសហការរវាងកម្ពុជា និងថៃនេះធ្វើឡើងដើម្បីបង្កើនកិច្ចសន្ទនាពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធនៃប្រទេសកម្ពុជា និងប្រទេសថៃ និងផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធ និងការអនុវត្តគោលនយោបាយទាក់ទងនឹងការលើកម្ពស់ការធ្វើចំណាកស្រុកដោយស្របច្បាប់របស់ប្រជាពលរដ្ឋកម្ពុជា ៕ កែសម្រួលដោយ ៖ សុឃាក់

## កុមារកម្ពុជាដែលតាមឪពុកម្តាយទៅរស់នៅស្រុកថៃទទួលបានការសិក្សាពីរដ្ឋាភិបាលថៃរយៈពេល១៥ឆ្នាំមិនគិតប្រាក់

http://bayontv.com.kh/ 27/05/2019

ភ្នំពេញ៖ រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលថៃ បានកំពុងបន្តពិភាក្សាគ្នាអំពីបញ្ហាកុមារកម្ពុជា ដែលបានទៅតាមឪពុកម្តាយរបស់ពួកគេរស់នៅ និងធ្វើការចំណាក់ស្រុកនៅប្រទេសថៃ ដោយការពិភាក្សានេះគឺនឹងត្រូវផ្តល់ឱកាសឲ្យកុមារកម្ពុជា ដែលកំពុងនៅទីនោះទទួលបានការសិក្សារយៈពេល១៥ឆ្នាំដោយមិនគិតប្រាក់សូម្បីតែមួយរៀល។

យោងតាមការសិក្សារបស់ភាគីកម្ពុជា និងភាគីថៃបានអះអាងថា កុមារកម្ពុជាយ៉ាងតិច ចំនួន១០ភាគរយដែលកំពុងរស់នៅជាមួយឪពុកម្តាយរបស់ពួកគេនៅប្រទេសថៃ ដោយកុមារ ទាំងនោះប្រឈមនឹងមិនចេះអក្សរ គ្មានសញ្ជាតិច្បាស់លាស់ ហើយភាគច្រើនពួកគេនឹងធ្វើការដោយមិនសូវមានជំនាញដូចឪពុកម្តាយរបស់ពួកគេយ៉ាងដូច្នេះដែរ។

ថ្លែងប្រាប់អ្នកសារព័ត៌មានក្រោយពីកិច្ចប្រជុំរវាងភាគីពាក់ព័ន្ធកម្ពុជា-ថៃ ដើម្បីពង្រឹងកិច្ចសហការក្នុងការដោះស្រាយបញ្ហាទេសន្តប្រវេសន៍នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩នេះនាទីស្តីការក្រសួងមហាផ្ទៃ លោកជំទាវ ជូ ប៊ុនអេង អនុប្រធាននអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានលើកឡើងថា រដ្ឋាភិបាលថៃនឹងផ្តល់ការសិក្សាដល់កុមារកម្ពុជារយៈពេល១៥ឆ្នាំ ប៉ុន្តែការផ្តល់នេះគឺផ្តល់

សម្រាប់កុមារណា ដែលទៅតាមឪពុកម្តាយរបស់ពួកគេដែលជាទេសន្តរប្រវេសន៍ស្របច្បាប់ ប៉ុណ្ណោះ។ លោកជំទាវបានបញ្ជាក់ឲ្យដឹងទៀតថា នាពេលបច្ចុប្បន្ននេះពលករកម្ពុជាប្រមាណជាង មួយលាននាក់កំពុងស្នាក់នៅជាទេសន្តរប្រវេសន៍នៅប្រទេសថៃ ហើយក្នុងនោះមានកុមារ ដែលកើតនិងរស់នៅជាមួយឪពុកម្តាយរបស់ពួកគេចាប់ពី៦ទៅ១០ភាគរយ ហើយភាគច្រើនពួកគេមិនចេះអក្សហើយមិនចេះនិយាយភាសាដើមកំណើតពួកគេនោះឡើយ។

ថ្លែងប្រាប់អ្នកសារព័ត៌មានក្រោយពីកិច្ចប្រជុំនោះដែរលោក ស៊ុពុង ស្រាវឿន(Sompong Sravaen)ដែលជាស្ថាបនិក និងនាយកមូលនិធិបណ្តាញជម្រុញសិទ្ធិការងាររបស់ថៃ បានឲ្យដឹងផងដែរថា ការដែលផ្តល់ឱកាសឲ្យកុមារកម្ពុជាទទួលបានការសិក្សានេះគឺក្រោយពីរដ្ឋាភិបាលថៃ បានសង្កេតឃើញកុមារកម្ពុជាជាច្រើនមិនបានទទួលការសិក្សា ហើយមិនចេះនៅភា សាដើមកំណើតខ្លួន ហើយមួយវិញទៀតដោយគ្មានការចេះដឹងនេះពួកគេទទួលរងគ្រោះពីការជួញដូរផងដែរ។

យ៉ាងណាក៏ដោយភាគីទាំងពីរមិនទាន់បានកំណត់ពេលវេលាច្បាស់លាស់ ក្នុងការចុះអនុស្សរណៈ (MOU) ជាមួយគ្នាលើគម្រោងនេះទេគ្រាន់តែអះអាងថានឹងធ្វើឡើងនាពេលឆាប់ៗខាងមុខនេះ៕

## នគរបាលជាតិកម្ពុជានិងនគរបាលជាតិបារាំង ពង្រឹងសមត្ថភាពដល់កងកម្លាំងនគរបាលជាតិកម្ពុជា

http://cambodiapolice.com/policekh/ 2:44 pm 27 ឧសភា 2019

ភ្នំពេញ ៖ នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ អគ្គស្នងការនគរបាលជាតិ និងនាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិនៃក្រសួងមហាផ្ទៃបារាំង បានបើកវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងការរំលោភបំពាន លើអនីតិជន ដើម្បីពង្រឹងសមត្ថភាពដល់កងកម្លាំងនគរបាលជាតិក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងបទល្មើសរំលោភ បំពានលើអនីតិជន ប្រកបដោយប្រសិទ្ធភាព ដែលជាចំណែកមួយក្នុងការលើកតម្កើនសុខសុវត្ថិភាពសង្គម នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។

វគ្គបណ្តុះបណ្តាលនេះ មានការអញ្ជើញចូលរួមជាអធិបតីពី ឯកឧត្តម ឧត្តមសេនីយ៍ឯក ខេង លីដា អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ដែលតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ។ គ្រូបង្គោលជនជាតិបារាំងលោក SEBASTIEN WONG, វរសេនីយ៍ត្រីបារាំង លោកOlivier LEFEBVRE និងមន្ត្រីជាន់ខ្ពស់នគរបាលជាតិជាច្រើននាក់ រួមទាំងស្នងការ និងស្នងការរងតាមបណ្តាខេត្តមួយចំនួនទៀតផងដែរ។

មានមតិសំណេះសំណាលក្នុងនាឱកាសនោះ លោក OLIVIER LEFEBVRE អនុព័ន្ធសន្តិសុខបារាំងប្រចាំទីក្រុង ហាណូយ បានថ្លែងបង្ហាញចំណាប់អារម្មណ៍ឆ្លុះបញ្ចាំងអំពីកិច្ចសហប្រតិបត្តិការរវាងមន្ត្រីអនុវត្តច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបារាំង ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ខេង លីដា អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ បានមានប្រសាសន៍ ផ្តាំផ្ញើដល់សិក្ខាកាមទាំងអស់ ត្រូវយកចិត្តទុកដាក់ ត្រង់ត្រាប់ស្តាប់គ្រូឧទ្ទេសនាម និងយកចំណេះជំនាញដែលទទួលបាន ទៅបង្ហាត់បង្រៀនបន្តដល់មន្ត្រីនគរបាលជំនាញតាមបណ្តាខេត្តរបស់ខ្លួន ។ វគ្គបណ្តុះបណ្តាលរយៈពេល៥ថ្ងៃនេះ មានសិក្ខាកាមចូលរួមក្នុងចំនួន២០រូប មកពីមន្ត្រីនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន៥រូប, ពីស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញចំនួន៥រូប, ពីស្នងការដ្ឋាននគរបាលខេត្តកណ្តាល២រូប, ពីស្នងការដ្ឋាននគរបាលខេត្តសៀមរាប២រូប, ពីស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ២រូប, ពីស្នងការដ្ឋាននគរបាលខេត្តកំពត២រូប និងពីស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ២រូប៕

## លោកជំទាវ ប៉ាល់ យឿន អភិបាលរងខេត្តកំពង់ឆ្នាំង អញ្ជើញជាអធិបតីភាពក្នុងវេទិការសាធារណៈ ស្តីពីការផ្សព្វផ្សាយទប់ស្កាត់អំពើជួញដូរមនុស្ស និងទេសន្តប្រវេសន៍ នៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

http://gdlf-kh.com/ 27/05/2019 Sek Samnang កំពង់ឆ្នាំង

ខេត្តកំពង់ឆ្នាំង៖ នៅព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ នៅសាលាបុណ្យស្រែវាល ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានបើកវេទិការសាធារណៈ ស្តីពីការផ្សព្វផ្សាយទប់ស្កាត់អំពើជួញដូរមនុស្ស និងទេសន្តប្រវេសន៍ រៀបចំដោយ គ ខ ប ជ គាំទ្រដោយរដ្ឋបាលខេត្តកំពង់ឆ្នាំង។ ពិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាពលោកជំទាវ **ប៉ាល់ យឿន** អភិបាលរងខេត្តកំពង់ឆ្នាំង លោកស្រី **មាស សុមាលី** ស្នងការរងនគរបាលខេត្តកំពង់ឆ្នាំង លោកស្រី **ឈឹម សុផល** អភិបាលស្រុករលាប្អៀរ ព្រមទាំងមានការចូលរួមពីលោកក្រុមប្រឹក្សាឃុំ រួមទាំងប្រជាពលរដ្ឋ សរុបអ្នកចូលរួមមានចំនួន ១០៧នាក់៕

# ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩

## ថៃបញ្ជូនពលករខ្មែរ ឆ្លងដែនខុសច្បាប់ ១០នាក់ ឲ្យមកកម្ពុជាវិញ តាមច្រកចាំយាម

https://www.dap-news.com/archives/ ByID:030 28 May 2019 | 20:20

ភ្នំពេញ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែន អន្តរជាតិចាំយាម នាវេលាម៉ោង ១៨និង០០នាទី ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីភាគីថៃ ចំនួន ១០នាក់ក្រោយកម្លាំង នគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំពួកគាត់រួចក៏អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញនេះបើយោងតាមអគ្គនាយកដ្ឋានអន្តោប្រវេសន៍៕

## ភិបាលរងខេត្តណែនាំឲ្យសមត្ថកិច្ចឈរជើងតាមព្រំដែនទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់

http://www.rasmeinews.com/ May 30, 2019, 11:40 AM

*ដោយៈគ្រញូង/បាត់ដំបង* ៖នៅរសៀលថ្ងៃទី២៩ខែឧសភាឆ្នាំ២០១៩លោកហឿង សុគន្ធ អភិបាលរងតំណាងលោក ងួន រតនៈ អភិបាលខេត្តបាត់ដំបងនិងសហការីមួយចំនួនបានអញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរស្រុក និងសមត្ថកិច្ចគ្រប់ផ្នែកឈរជើងក្នុងភូមិសាស្ត្រស្រុក សំពៅលូន ខេត្តបាត់ដំបង ដោយបានណែនាំឱ្យបន្តការយកចិត្តទុកដាក់ បន្ថែមទៀតថែរក្សាសន្តិសុខសណ្តាប់សាធារណៈ ពិសេសយកចិត្តទុកដាក់អប់រំពលករឆ្លងដែនខុសច្បាប់ចូលទៅធ្វើការនៅប្រទេសថៃឱ្យពួកគាត់ បំពេញបែបបទត្រឹមត្រូវ ដើម្បីឆ្លងដែនតាមនិនច្បាប់ទើបទទួលបានសុវត្ថិភាព។

លោកអភិបាលរងខេត្តបានសំណូមពរដល់សមត្ថកិច្ចគ្រប់ថ្នាក់បន្តយកចិត្តទុកដាក់ទំនាក់ទំនង សហការល្អជាមួយភាគីថៃ ដើម្បីរួមគ្នាថែរក្សាព្រំដែនប្រកបដោយសន្តិភាព សុវត្ថិភាព ស្ថិរភាពនិងកិច្ចសហប្រតិបត្តិការល្អ បង្កលក្ខណៈអោយប្រជាពលរដ្ឋនៃប្រទេសទាំងពីរចេញចូលប្រកបមុខរបររកស៊ីទទួលទាន បង្កើនជីវភាព របស់ពួកគាត់ឱ្យមានជីវភាពកាន់តែប្រសើរឡើងថែមទៀត៕B/

## ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩
## រដ្ឋាភិបាលដាក់ចេញយុទ្ធសាស្រ្ត៨ចំណុចដើម្បីការពារកុមារ

http://bayontv.com.kh/ 30/05/2019

ភ្នំពេញ៖ មានយុទ្ធសាស្រ្តចំនួន៨ចំណុចដែលត្រូវរាជរដ្ឋាភិបាលកម្ពុជាដាក់ចេញ ដើម្បីការពារកុមារ។ នេះបើតាមសារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តី ចេញនៅថ្ងៃទី២៩ ខែឧសភា ក្នុងឱកាសខួបលើកទី៧០ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៨ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៩។

យុទ្ធសាស្រ្តទាំង៨ចំណុចនោះរួមមាន៖ ទី១.ពង្រឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ, ២.បង្កើតយុទ្ធសាស្រ្តផ្លាស់ប្តូរឥរិយាបទសង្គមតាមរយៈការអប់រំកុមារបែបវិជ្ជមាន, ៣. កសាងច្បាប់គោលនយោបាយពាក់ព័ន្ធដល់ការរស់នៅរបស់កុមារ តម្រូវការ បញ្ហាប្រឈម និងការ ព្រួយបារម្ភរបស់កុមារ, ៤.ទប់ស្កាត់ហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះជាកុមារ, ៥.ចូលរួមអនុវត្ត គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងចាត់វិធានការការពារកុមារគ្រប់រូបភាព, ៦.បន្តអនុវត្តអនុ សញ្ញាស្នូលនៃអង្គការអន្តរជាតិខាងការងារដើម្បីលុបបំបាត់គ្រប់ទម្រង់នៃពលកម្មកុមារ, ៧.គ្រប់ប្រព័ន្ធ ផ្សព្វផ្សាយបន្តផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការការពារកុមារពីអំពើហិង្សា និងពលកម្មកុមារគ្រប់ រូបភាព និងទី៨.បង្កើនកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរ ដើម្បីទប់ស្កាត់អំពើហិង្សាលើ កុមារគ្រប់រូបភាព និងលុបបំបាត់ពលកម្មកុមារនៅកម្ពុជា។

សារលិខិតរបស់សម្តេចប្រមុខរាជរដ្ឋាភិបាលកម្ពុជាដដែលក៏បានចាត់ទុកកុមារថា ជាធនធានមនុស្ស ដែលមិនអាចខ្វះបានសម្រាប់អភិវឌ្ឍប្រទេសជាតិនាពេលអនាគតផងដែរ។ ទិវាកុមារកម្ពុជា និងទិវាកុមារអន្តរជាតិ ១ មិថុនានៅឆ្នាំ២០១៩ ធ្វើឡើងក្រោមប្រធានបទលើកកម្ពស់ សិទ្ធិកុមារតាមរយៈការលុបបំបាត់អំពើហិង្សាលើកុមារគ្រប់រូបភាព៕

## ជម្រះក្តីស្ត្រីជាប់ចោទនាំនារីទៅរៀបការនៅចិន តែមេធាវីថាកូនក្តីខ្លួនគ្រាន់តែផ្តល់ព័ត៌មាន

https://m.postkhmer.com/ 30 May 2019 | 09:00 ICT គីម សារុំ

**ភ្នំពេញៈ** តុលាការកំពូលពីម្សិលមិញបានជំនុំជម្រះស្រ្តីជាប់ចោទម្នាក់ពាក់ព័ន្ធនាំនារីខ្មែរ ២ នាក់ ទៅរៀបការប្តីនៅប្រទេស ចិន ដែលប្រព្រឹត្តនៅខេត្តបន្ទាយមានជ័យកាលពីឆ្នាំ ២០១៥ ដែលស្រ្តីជាប់ចោទត្រូវសាលាដំបូងខេត្តនេះផ្តន្ទាទោសដាក់ពន្ធនាគារ ១៥ ឆ្នាំ ប៉ុន្តែមេធាវីការពារស្រ្តីជាប់ចោទថា កូនក្តីខ្លួនមិនបាននាំទៅរៀបការទេ គ្រាន់តែបានផ្តល់ព័ត៌មានសម្រាប់ជនរងគ្រោះប៉ុណ្ណោះ។

នៅក្នុងបន្ទប់សវនាការពីម្សិលមិញស្រ្តីជាប់ចោទឈ្មោះ ជិន ពន្លឺ ហៅ នន អាយុ ៣៣ឆ្នាំ បានប្រាប់ចៅក្រមថាប្រការដែលនាំឲ្យគាត់ជាប់ពាក់ព័ន្ធក្នុងរឿងនេះ មុនដំបូងមានស្រ្តីម្នាក់ឈ្មោះ សាន មកអង្គុយលេងនៅផ្ទះរបស់គាត់។ ខណៈនោះបងថ្លៃជីដូនមួយរបស់គាត់បានទូរស័ព្ទមកពីប្រទេស ចិន ក្នុងន័យសួរសុខទុក្ខគាត់។ ពេលនោះស្រ្តីឈ្មោះ សាន បាននិយាយថា បើមានបងប្អូននៅប្រទេស ចិន ជួយកូនស្រីរបស់ស្រ្តីឈ្មោះភាព ២ នាក់ ឲ្យបានទៅធ្វើការនៅប្រទេស ចិន ផងទៅ។ ស្រ្តីជាប់ចោទប្រាប់ចៅក្រមថា៖ «ខ្ញុំប្រាប់មីង សាន ថា នៅស្រុកចិនគេមិនយកមនុស្សធ្វើការទេ ហើយបើចង់ដឹងច្បាស់យ៉ាងម៉េចខ្ញុំឲ្យលេខទូរស័ព្ទបងរបស់ខ្ញុំ»។ ស្រ្តីជាប់ចោទបន្តថា បន្ទាប់ពីគាត់ឲ្យលេខទូរស័ព្ទទៅស្រ្តីឈ្មោះ សាន ហើយ ពួកគេក៏ទំនាក់ទំនងគ្នាជាមួយបងស្រីជីដូនមួយគាត់នៅប្រទេស ចិន។ ពេលនោះស្រ្តីឈ្មោះភាព ដែលជាម្តាយរបស់នារីរងគ្រោះឈ្មោះ ប៉ាង ស្រីពៅ អាយុ ១៧ ឆ្នាំ និងឈ្មោះ ប៉ាង ណារី អាយុ ២៦ ឆ្នាំ បានឲ្យគាត់ជូនមករាជធានីភ្នំពេញដើម្បីធ្វើលិខិតឆ្លងដែន។

ប៉ុន្តែមន្រ្តីធ្វើលិខិតឆ្លងដែនមិនធ្វើឲ្យទេ ព្រោះពួកគេទាំង ២ នាក់ ធ្លាប់ធ្វើលិខិតឆ្លងដែនម្តងរួចទៅហើយ (ធ្លាប់ទៅធ្វើការនៅប្រទេស ម៉ាឡេស៊ី) ហើយស្រ្តីឈ្មោះ ភាព បានទាក់ទងបងស្រីជីដូនមួយរបស់គាត់នៅប្រទេសចិនប្រាប់ឲ្យគាត់និងម្តាយនារីរងគ្រោះនាំពួកគេធ្វើដំណើរមករាជធានីភ្នំពេញ ដើម្បីជិះយន្តហោះទៅប្រទេស ចិន។

ស្រ្តីជាប់ចោទបន្តថា៖ «មុនសម្រេចចិត្តទៅប្រទេសចិននារីរងគ្រោះបានឆាតទូរស័ព្ទឃើញមុខគ្នាជាមួយបុរសជនជាតិចិនរួចហើយបានពួកគេទៅ។ ខ្ញុំសូមតុលាការដោះលែងខ្ញុំវិញព្រោះខ្ញុំមានជំងឺមហារីកក ហើយមានកូនតូច ៤

នាក់ផង»។ ស្ត្រីជាប់ចោទបញ្ជាក់ថា នារីរងគ្រោះជាប្អូនទៅប្រទេសចិនបាន ១០ ខែ ក្នុងឆ្នាំ ២០១៦ ក៏មកប្រទេសកម្ពុជាវិញ ហើយពេលនោះស្ត្រីឈ្មោះភាព ដែលជាម្ដាយនារីរងគ្រោះគ្មានលុយធ្វើដំណើរមកទទួលយកកូនក៏ប្រាប់ទៅអង្គការមួយនៅក្នុងឃុំឲ្យជួយមកទទួលនារីរងគ្រោះហើយពេលមកដល់ផ្ទះស្រាប់តែអង្គការនោះប្ដឹងគាត់តែម្ដង។ ឯស្ត្រីឈ្មោះសាន ក៏បានទទួលលុយ ២ ពាន់ដុល្លារដែរ តែគាត់ (ស្ត្រីជាប់ចោទ) មិនបានលុយក្នុងរឿងនេះទេ។ ស្ត្រីជាប់ចោទថា គាត់ត្រូវបានសាលាដំបូងខេត្តបន្ទាយមានជ័យប្រកាសសាលក្រមនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៧ ផ្ដន្ទាទោស ១៥ ឆ្នាំ និងសងទៅនារីរងគ្រោះម្នាក់ ៥ លានរៀល។ បន្ទាប់មកគាត់ប្ដឹងមកសាលាឧទ្ធរណ៍ហើយក៏ត្រូវសាលាឧទ្ធរណ៍ប្រកាសសាលដីកានៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៨ តម្កល់ទោស ១៥ ឆ្នាំដដែល។

លោកព្រះរាជអាជ្ញា ជុំ សំបាន តំណាងមហាអយ្យការសន្និដ្ឋានថាតាមចម្លើយរបស់នារីរងគ្រោះកាលពីនៅដំណាក់កាលនគរបាលយុត្តិធម៌ថា ស្ត្រីជាប់ចោទបានទទួលលុយចំនួន ២ ពាន់ដុល្លារ ពីបងស្រីរបស់គាត់នៅប្រទេសចិននិងលុយ ៣០០ ដុល្លារ ឲ្យគាត់ព្យាបាលសុខភាព។ ឯស្ត្រីជាប់ចោទក៏ទទួលស្គាល់កាលពីនៅតុលាការថ្នាក់ក្រោមដែរ។ លោកថា៖ «ដូច្នេះគួរក្រុមប្រឹក្សាជំនុំជម្រះពិនិត្យលើចម្លើយរបស់គាត់ទៅតាមច្បាប់»។

ទោះយ៉ាងណាលោកស្រី លុយ សុធី មេធាវីការពារសិទ្ធិឲ្យស្ត្រីជាប់ចោទសន្និដ្ឋានថាកូនក្ដីរបស់លោកស្រីគ្រាន់តែផ្ដល់ព័ត៌មានឲ្យម្ដាយនារីរងគ្រោះប៉ុណ្ណោះ។ ជាមួយគ្នានេះនារីរងគ្រោះនិងបុរសជនជាតិចិននោះក៏ធ្លាប់បាននិយាយឃើញមុខគ្នាផង។ លោកស្រីមេធាវីថា៖ «កូនក្ដីរបស់ខ្ញុំមិនបានប្រគល់នារីរងគ្រោះទៅឲ្យនរណាម្នាក់ទេហើយពេលទៅដល់ប្រទេស ចិន នារីរងគ្រោះក៏បានប្រាប់មកម្ដាយថាពួកគេបានប្ដីចិនទៀតផង។ ចុះហេតុអ្វីមិនប្ដឹងពីពេលនោះមក។ ខ្ញុំសូមតុលាការដោះលែងកូនក្ដីខ្ញុំវិញផង»។ ក្រោយជំនុំជម្រះលោកចៅក្រម គង់ ស្រុ៊ម ថ្លែងថាសាលដីកានេះនឹងប្រកាសនៅ ថ្ងៃទី ៥ ខែ មិថុនា៕

## កម្លាំងការពារព្រំដែនកម្ពុជានិងថៃសហការទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 31/05/2019

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងទាហានឈុតខ្មៅថៃ១ក្រុមនៃកងអនុសេនាធំលេខ១២.០៦ ឈរជើងនៅជួរមុខខ្សែ បន្ទាត់ព្រំដែនស្ថិតក្នុងភូមិសាស្ត្រភូមិបាណូនសាវអេ ឃុំផានសឹក ស្រុកអារញ្ញ ខេត្តស្រះកែវប្រទេសថៃ បានអញ្ជើញចូលមកសំណេះសំណាលនិងពិភាក្សាជាមួយកងកម្លាំងនគរបាលការពារព្រំដែន កម្ពុជា នៅចំណុចប៉ុស្តិ៍ដើមត្រសេក នៃវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ស្ថិតនៅចំណុច ភូមិបឹងរាំង ឃុំអូរស្រឡៅ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដើម្បីសហការគ្នាចាត់វិធានការបង្ការទប់ ស្កាត់និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទខុសច្បាប់។

គ្រាដែលមានសេចក្តីរាយការណ៍ឱ្យដឹងថា កងកម្លាំង ជួរមុខរវាងកម្ពុជា-ថៃ ដែលមានឈរជើងនៅក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងភូមិសាស្ត្រស្រុអារញ្ញ ខេត្តស្រះកែវ កន្លងមកបានសហការគ្នាហើយបង្ក្រាបបទល្មើសឆ្លងដែនជួញដូរអាវុធខុសច្បាប់និងបទល្មើសឆ្លងដែនមួយចំនួនទៀតផងដែរ។កិច្ចសំណេះសំណាលបានធ្វើឡើងនៅព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ក្រោមការដឹកនាំដោយ នាយប៉ុស្តិ៍នគរបាលការពារព្រំដែនដើមត្រសេកនៃវរៈសេនាតូច៨១៥លោកអនុសេនីយ៍ឯកណុប អឿន ចំណែកទាហានឈុតខ្មៅថៃដឹកនាំដោយលោកអនុសេនីយ៍ទោ អាត់ដួង ភីឡា មេបញ្ជាការនៃកងអនុសេនាធំលេខ១២.០៦។

ក្នុងកិច្ចពិភាក្សានោះផងដែរកងកម្លាំងជួរមុខការពារព្រំដែនទាំង២ ក៏បានជម្រុញការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទៅវិញទៅមកឱ្យកាន់តែស្និតស្នាលរឹងមាំ និងមានបញ្ហាអ្វីកើតឡើងនៅតាមបន្ទាត់ព្រំដែនត្រូវជូនដំណឹងគ្នាដើម្បីពិភាក្សាដោះស្រាយឈរលើស្មារតីយោគយល់បញ្ចៀសបញ្ហាប្រឈមមុខតានតឹងដាក់គ្នា។

សេចក្តីរាយការណ៍ឱ្យដឹងទៀតថា ពាក់ព័ន្ធនិងកងកម្លាំងជួរមុខរវាងកម្ពុជានិងថៃក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងភូមិសាស្ត្រស្រុកអារញ្ញ ខេត្តស្រះកែវ កន្លងមករហូតដល់បច្ចុប្បន្នបានទំនាក់ទំនងគ្នាបានល្អមិនតែប៉ុណ្ណោះបានសម្របសម្រួលឱ្យប្រជាជននៃប្រទេសទាំង២ធ្វើដំណើរឆ្លងដែនប្រកបមុខរបររកស៊ីនិងធ្វើការងារបានល្អផងដែរ៕

## ៤ចំណុចត្រូវរដ្ឋបាលស្រុកថ្មពួក(កម្ពុជា)និងស្រុកតាប្រាយ៉ា(ថៃ)ពិភាក្សាគ្នា

http://www.rasmeinews.com/ May 29, 2019, 5:43 PM

ដោយៈភ្នំស្វាយ/ស្រះកែវ-ថៃៈ៤ចំណុច ត្រូវរដ្ឋបាលស្រុកថ្មពួកខេត្តបន្ទាយមានជ័យប្រទេសកម្ពុជានិងរដ្ឋបាលស្រុកតាប្រាយ៉ាខេត្តស្រះកែវប្រទេសថៃពិភាក្សាគ្នា។ក្នុងជំនួបកិច្ចប្រជុំកាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ ដឹកនាំដោយលោក ឡៅប ឈួន អភិបាលស្រុកថ្មពួកនិងសមភាគីលោក អារីយ៉ាន់ថាយ៉ៃអភិបាលស្រុកតាប្រ៉ាយ៉ា។នេះបើយោងមន្ត្រីផ្នែករដ្ឋបាលនៃសាលាស្រុកថ្មពួកឱ្យកាសែតរស្មីកម្ពុជាដឹងកាលពីថ្ងៃទី២៩ខែឧសភា ។ លោកបានបន្តថា : ភាគីថ្នាក់ស្រុកទាំង២បានពិភាក្សាលើរបៀបវារៈសំខាន់ចំនួន៤ រួមមាន : ១- បញ្ហារោគជំងឺឆ្លងរុក្ខជាតិដើមដំឡូងមី។ ២បញ្ហាគ្រឿងញៀនឆ្លងដែន។៣ការកាប់ឈើនៅតាមតំបន់ព្រំដែនស្រុកជាប់ព្រំដែនទាំងពីរ(ស្រុកតាប្រ៉ាយ៉ា និងស្រុកថ្មពួក។៤-អំពីពលករការឆ្លងដែនខុសច្បាប់ និងការឆ្លងដែនរបស់មន្ត្រីរាជការ និងពលរដ្ឋឆ្លងដែន ។

អង្គប្រជុំពង្រឹងសម្ព័ន្ធមេត្រីភាពស្រុកជាប់ព្រំដែនទាំងពីរ ដែលមានសមាសភាព២៥នាក់មកពីភាគីនិមួយៗ បានលើកពីបញ្ហាប្រឈមមួយចំនួនតូច ដែលនៅសេសសល់បន្តដោះស្រាយគ្នា។ រាយការណ៍ពីលទ្ធផលល្អក្នុងកិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរសមត្ថកិច្ចពាក់ព័ន្ធកន្លងមក។ ប្រធាននិងស្មារតីអង្គប្រជុំទាំង២បានឯកភាពគ្នាទៅវិញទៅមកលើទិសដៅក្នុងការបន្តកិច្ចសហការពាក់ព័ន្ធនឹងរបៀបវារៈខាងលើ ៕S/

## តុលាការ បើកសវនាការសំណុំរឿងការផលិតភាពយន្តរឿង «ម្ដាយខ្ញុំលក់ខ្ញុំ»

https://www.postkhmer.com/ គឹម សារុំ | Publication date 31 May 2019 | 09:13 ICT

**ភ្នំពេញៈ** សាលាដំបូងរាជធានីកាលពីម្សិលមិញ បានបើកសវនាការជំនុំជម្រះសំណុំរឿងលោក រ៉ាត់ វ័ន្ថមុនី ពាក់ព័ន្ធករណីថតភាពយន្តឯកសារដ៏ចម្រូងចម្រាសរឿង «ម្ដាយខ្ញុំលក់ខ្ញុំ» ដែលត្រូវបានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៥ នាក់ទាមទារសំណងជំងឺចិត្តម្នាក់ៗពី ៥ ពាន់ទៅ ១ ម៉ឺនដុល្លារ ខណៈដែលជននេះអះអាងថា ខ្លួនគ្រាន់តែជាអ្នកបកប្រែភាសាឲ្យជនបរទេសប៉ុណ្ណោះ។

ក្នុងសវនាការជំនុំជម្រះដែលមានសមាសភាពលោកចៅក្រម កូយ សៅ និងមានលោកព្រះរាជអាជ្ញារង វង្ស ប៊ុនវិសុទ្ធ ជាតំណាងមហាអយ្យការ ដែលអវត្តមានជនរងគ្រោះ ដែលជាដើមបណ្ដឹងរដ្ឋប្បវេណីផងនោះបានប្រាប់ជនត្រូវចោទលោក រ៉ាត់ វ័ន្ថមុនីថា ផ្ដើមឲ្យមានការចោទប្រកាន់មកលើលោក រ៉ាត់ វ័ន្ថមុនី នេះឡើង គឺដោយសារមានការផ្សព្វផ្សាយតាមគណនីយហ្វេសប៊ុកចំនួន ២ ដែល និយាយពីស្ត្រីកម្ពុជា យកកូនស្រីទៅលក់ព្រហ្មចារីយ៍ ហើយសមត្ថកិច្ចកម្ពុជាបានស្រាវជ្រាវផ្ដល់ព័ត៌មាន ដល់អាជ្ញាធរថៃ ក៏បានចាប់ខ្លួនលោក រ៉ាត់ វ័ន្ថមុនី បញ្ជូនមកកម្ពុជាវិញ។ លោក កូយ សៅ ថា៖ «ការបង្ហោះវីដេអូឃ្លីបនោះ ជាការផ្សព្វផ្សាយពាណិជ្ជកម្ម និងជាការមាក់ងាយដល់ស្ត្រីខ្មែរ។ នេះជាមូលហេតុនៃការចោទប្រកាន់ និងនាំឲ្យមានការចាប់ខ្លួនលោក រ៉ាត់ វ័ន្ថមុនី»។ លោកបានបន្តថា មុននឹងដំណើរការថតវីដេអូនោះ ជនត្រូវចោទ វ័ន្ថមុនី បានរត់ការធ្វើលិខិតសុំការអនុញ្ញាត ពីក្រសួងព័ត៌មាន ដោយប្រាប់ថា សុំផលិតខ្សែវីដេអូស្ដីពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ក្រោយរបបខ្មែរក្រហម ហើយក្រសួងព័ត៌មាន ក៏បានយល់ព្រម និងសុំទីតាំងថតមានខេត្តសៀមរាប ព្រះសីហនុ ភ្នំពេញ ហើយខាងក្រសួង ក៏បានជូនដំណឹងដល់សាមីខេត្តទាំងនោះផងដែរ។ ប៉ុន្តែដល់ពេលផលិតឃ្លីបវីដេអូទៅជារឿងផ្សេងទៅវិញ។

ដោយសារតែអវត្តមានជនរងគ្រោះផង លោកចៅក្រម កូយ សៅ បានអានចម្លើយរបស់ជនរងគ្រោះថា នៅក្នុងសំណុំរឿងនេះ ស្ត្រីជាជនរងគ្រោះមានឈ្មោះ យៀង ស្រីម៉ុច, លឹម ស្រីទី, អៀក សាលិន, កែវ ម៉ាឡៃ និងឈ្មោះ អ៊ុន ស្រីពេជ្រ បាននិយាយប្រហាក់ប្រហែលគ្នាថា ពួកគេត្រូវបានឈ្មោះ វ័ន្ថមុនី ជាអ្នកលួងលោមឲ្យថតជាវីដេអូ ដោយប្រាប់ថា វីដេអូនិយាយរៀបរាប់ពីខ្សែជីវិតគ្រួសារក្រីក្រនៅកម្ពុជា ដើម្បីឲ្យជនជាតិរុស្ស៊ីយកទៅផ្សព្វផ្សាយក្នុងប្រទេសរបស់គេ។ លោកចៅក្រម បានអានកំណត់ហេតុបន្តថា ក្នុងការលួងលោមនោះ វ័ន្ថមុនី បានសន្យាជាមួយស្ត្រីរងគ្រោះថានឹងជួយដោះស្រាយដីបឹងកក់ឲ្យ ប្រសិនបើយល់ព្រមថតវីដេអូឃ្លីបឲ្យជនជាតិរុស្ស៊ី ហើយអ្នកខ្លះទៀតសន្យាថា នឹង

ផ្តល់ទុនដើម្បីឲ្យបើកហាងអ៊ុតសក់ដើម្បីប្រកបរបរកស៊ីចិញ្ចឹមជីវិត។ លោកថា៖ «កាលពីនៅថៅក្រមស៊ើបសួរ យុវតីម្នាក់រៀននៅថ្នាក់ទី ១១ នៅសាលាឥន្ទ្រទេវី ថា ប្រសិនបើយកនាងទៅថតកាឡែជារឿងផ្សេង នាងមិនថតទេ ព្រោះឥឡូវនេះ គ្រួសារនាងពិសេសនាងខ្មាសគេពេញសាលារៀន»។

ប៉ុន្តែលោក រ័ត្នមុនី បានថ្លែងនៅក្នុងសវនាការថា លោកគ្រាន់តែជាអ្នកបកប្រែភាសាឲ្យជនជាតិរុស្ស៊ី ដែលជាអ្នកផលិតភាពយន្តឯកសារនេះតែប៉ុណ្ណោះ។ លោកបញ្ជាក់ថា៖ «ចំពោះការចោទប្រកាន់ពីការល្បួងលោមក្មេងស្រីអី ខ្ញុំអត់បានធ្វើទេ អត់ទេ ខ្ញុំគ្រាន់តែជាអ្នកបកប្រែភាសាទេ»។

ជាមួយគ្នានេះ លោក ឡោ ជុនធី និងលោក សំ ទិត្យសីហា ជាមេធាវីការពារសិទ្ធិឲ្យលោក រ័ត្នមុនី បានប្រាប់ថៅក្រមថាការជំនុំជម្រះនេះ គឺដើម្បីស្វែងរកការពិត ដល់ភាគីទាំងសងខាង ប៉ុន្តែពេលនេះអវត្តមានជនរងគ្រោះទាំងអស់ដូច្នេះដើម្បីមានការកាត់ក្តីឲ្យបានត្រឹមត្រូវមួយ ត្រូវតែមានវត្តមានជនរងគ្រោះ។ លោក ជុនធី ថ្លែងថា៖ «ខ្ញុំស្នើសុំដល់តុលាការ ឲ្យកោះហៅជនរងគ្រោះមកចោទឆ្លើយតទល់គ្នាដើម្បីឲ្យដឹងច្បាស់លាស់»។ ដោយសារតែមានការទាមទារពីមេធាវីរបស់ជនត្រូវចោទលោកថៅក្រមបានលើកពេលបើកសវនាការទៅថ្ងៃទី ១២ ខែ មិថុនា បន្តទៀត។

អ្នកស្រី ឡុង គឹមហ៊ាង ដែលជាភរិយាលោក រ័ត្នមុនី បានថ្លែងនៅសាលាឧទ្ធរណ៍កាលពីពេលកន្លងមកថាទាក់ទងនឹងរឿង «ម្តាយខ្ញុំលក់ខ្ញុំ» ត្រូវអ្នកផលិតភាពយន្តនៅប្រទេស រុស្ស៊ី យកខ្សែភាពយន្តនោះទៅបញ្ចាំងតាមផ្កាយរណបហើយត្រូវបកប្រែប្រមាណ ១០ ភាសាហើយបន្ទាប់មកអ្នកនៅកម្ពុជា បាននាំគ្នាចែករំលែកបន្តទើបនាំឲ្យភាពយន្តនេះល្បី។ អ្នកស្រីថា៖ «ខ្ញុំនិងប្តីបន្ទាប់ពីមើលឃើញចំណងជើងភាពយន្តនេះ ក៏បារម្ភនិងគិតថា អាចនឹងមានបញ្ហា ហើយបានទូរស័ព្ទប្រាប់អ្នកផលិតភាពយន្តនោះ ហើយត្រូវគេប្រាប់ថា បើមានបញ្ហា គេនឹងផ្តល់មេធាវី ដើម្បីជួយផ្នែកផ្លូវច្បាប់។ ប៉ុន្តែក្រោយពីប្តីខ្ញុំត្រូវបានចាប់ខ្លួនខាងអ្នកផលិតភាពយន្ត មិនបានផ្តល់មេធាវីឲ្យទេ ព្រោះថាយើងរកមេធាវីបាននៅក្នុងប្រទេសហើយ»។ អ្នកស្រីរំឭកថា នៅមុនខែ ធ្នូ ឆ្នាំ ២០១៨ អ្នកស្រី និងប្តីបានទៅប្រទេសថៃ ក្នុងបំណងពិនិត្យមើលពីស្ថានភាពរស់នៅរបស់កម្មករខ្មែរនៅទីនោះ ដើម្បីថតភាពយន្តនិយាយអំពីជីវិតកម្មករខ្មែរធ្វើការនៅថៃ។ គាប់ជួនពេលនោះក៏មានមិត្តភក្តិប្តីអ្នកស្រីម្នាក់ នៅប្រទេស នូវែលសេឡង់ បានអញ្ជើញប្តីអ្នកស្រីទៅចូលរួមបុណ្យគ្រិស្តស្មាស់នៅប្រទេសនោះ។ ប៉ុន្តែនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨ ខណៈអ្នកស្រី និងប្តីទៅសុំទិដ្ឋាការនៅស្ថានទូតនូវែលសេឡង់ក្នុងក្រុងបាងកកក៏ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនប្តីអ្នកស្រីតែម្តង បន្ទាប់មកក៏បញ្ជូនមកកម្ពុជា៕

## អគ្គស្នងការដ្ឋាននគរបាលជាតិបិទវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងការរំលោភលើអនីតិជន

http://cambodiapolice.com/policekh/ 11:50 am 31 ឧសភា 2019

ភ្នំពេញ ៖ វគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងការរំលោភបំពានលើអនីតិជន ក្រោមកិច្ចសហការជាមួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ(DCI) ក្រសួងមហាផ្ទៃ នៃសាធារណរដ្ឋបារាំង ដែលមានរយៈពេល៥ថ្ងៃត្រូវបានធ្វើពិធីបិទនៅព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩នេះ ។

ពិធីនេះស្ថិតក្រោមអធិបតីភាព លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ តំណាងឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេតសាវឿន អគ្គស្នងការនគរបាលជាតិ និងលោក វ៉ាំងសង់ វ៉ង់ណែប(Vincent Vanherpe) ប្រធានគម្រោងសហប្រតិបត្តិការជាមួយកងរាជអាវុធហត្ថនៃព្រះរាជាណាចក្រកម្ពុជា ជាតំណាងស្ថានទូតសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា ៕